**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics

## សារណាបញ្ចប់ការសិក្សា

# របបគតិយុត្តនៃកិច្ចសន្យាលក់ ទិញ អចលនវត្ថុនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី២៣ ខែ មីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **ឈួន ចរិយា**

លោក **ឆិ ណារ៉ាក់**

សាស្ត្រាចារ្យណែនាំ

លោក **ជិន វណ្ណារ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ **ឃួន ចរិយា** និង លោក **ឆិ ណារ៉ាក់** ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ សូមសម្តែងនូវគារវកិច្ចដល់ខ្ពង់ខ្ពស់ និង សូមគោរពនូវការដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះ

អ្នកមានគុណនាងខ្ញុំ **លោកឪពុក ឃួន ម៉ុនធី និង អ្នកម្តាយ ឌី សុខហ៊ាង**

អ្នកមានគុណខ្ញុំបាទ **លោកឪពុក លុយ តុងតេ និង អ្នកម្តាយ យិន យឿង**

ដែលលោកបានផ្តល់កំណើត និងផ្តល់ការអប់រំ ណែនាំ ប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងបានជួយឧបត្ថម្ភ គាំទ្រលើគ្រប់តម្រូវការទាំងជីវភាពរស់នៅ និង ការសិក្សាតាំងពីបឋមសិក្សារហូតមកទល់នឹងបច្ចុប្បន្ននេះ។

**ឯកឧត្តមសាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង រួមទាំងគណៈគ្រប់គ្រងទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលផ្តល់ការអនុញ្ញាត និង ការយកចិត្តទុកដាក់ឱ្យយើងខ្ញុំបានសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹង និង បទពិសោធន៍ជាច្រើនអំពីការសិក្សារបស់យើងខ្ញុំកន្លងមក។

លោកសាស្ត្រាចារ្យ **ខិន វណ្ណារ៉ា** ដែលលោកគឺជាសាស្ត្រាចារ្យដឹកនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ ហើយបានធ្វើការពន្យល់ណែនាំ កែតម្រូវ ព្រមទាំងមានការលើទឹកចិត្តខិតខំបង្ហាត់បង្រៀនដោយមិនខ្លាចនឹងការហត់នឿយឡើយដើម្បីឱ្យយើងខ្ញុំទទួលបាននូវភាពច្បាស់លាស់ និង ចំណេះដឹងចំពោះសមិទ្ធិផលមួយនេះ។

**លោក លោកស្រី សាស្ត្រាចារ្យទាំងអស់ និងបុគ្គលិកគ្រប់ជាន់ថ្នាក់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានខិតខំយ៉ាងមុតមាំក្នុងតួនាទីដើម្បីជួយសម្រួលដល់ការសិក្សាដើម្បីឱ្យយើងខ្ញុំទទួលបានចំណេះដឹងបទពិសោធន៍យ៉ាងច្រើនដើម្បីធ្វើជាស្ពានឈានទៅដល់ថ្ងៃអនាគតដ៏ភ្លឺស្វាង។

សូមអរគុណយ៉ាងជ្រាលជ្រៅជូនចំពោះម្ចាស់ស្នាដៃគ្រប់ការតាក់តែង ការរៀបរៀង និង ចង់ក្រងឡើងបង្កើតបានជាឯកសារដ៏មានតម្លៃសម្រាប់ជាជំនួយក្នុងការសិក្សាស្រាវជ្រាវកន្លងមក។

ជាទីបញ្ចប់យើងខ្ញុំសូមគោរពជូនពរដល់ លោកឪពុក អ្នកម្តាយជាទីគោរពស្រឡាញ់ និង អស់លោក លោកស្រី អ្នកនាង កញ្ញា និងមិត្តជាទីរាប់អានទាំងអស់ សូមឱ្យបានជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀង ឃ្លាតឡើយ៕

# អារម្ភកថា

សៀវភៅសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រក្រោមប្រធានបទស្តីអំពី **របបគតិយុត្ត នៃកិច្ចសន្យាលក់ទិញអចលនវត្ថុនៅកម្ពុជា** គឺជាឯកសារចង់ក្រងបានសម្រេចមួយ ដែលកើតចេញពីការខិតខំរៀនសូត្ររយៈពេលបួនឆ្នាំកន្លងមកនេះ ហើយជាការសិក្សាស្រាវជ្រាវមួយដែលបានចំណាយពេលវេលាព្រមទាំងចំណាយកម្លាំងកាយកម្លាំងចិត្ត ដោយធ្វើយ៉ាងណាឱ្យអត្ថបទមានតម្លៃទាំងខ្លឹមសារ និង អត្ថន័យ ទៅលើគ្រប់ចំណុចទាំងអស់នៃកិច្ចសន្យាលក់ទិញអចលនវត្ថុ ដើម្បីជាប្រយោជន៍សម្រាប់ប្រជាពលរដ្ឋខ្មែរទូទៅ ពិសេសគឺអ្នកសិក្សាស្រាវជ្រាវបន្តដើម្បី ឱ្យស្របទៅនឹងប្រទេសកម្ពុជាដែលមានភាពរីកចម្រើនខ្លាំងលើវិស័យអចលនវត្ថុនេះ ដូច្នេះការយល់ដឹងអំពីការបង្កើតកិច្ចសន្យា ការស្គាល់ពីសិទ្ធិ និង ករណីយកិច្ចក្នុងនាមជាអ្នកលក់ និង អ្នកទិញគឺជាប្រការសំខាន់ក្នុងការធានាដល់សុពលភាពនិងអានុភាពនៃកិច្ចសន្យា ក៏ដូចជាជៀសវាងនូវការកើតមាននូវវិវាទផងដែរ។

ដូច្នេះទោះបីជាសៀវភៅសារណាមួយនេះបានលេចចេញជារូបរាងហើយស្អាត ដោយមានការផ្ចិតផ្ចង់យ៉ាងណាក៏ដោយ ក៏នៅតែមានការសាងឡើងនូវកំហុសដោយអចេតនាទៅលើពាក្យពេចន៍ អក្ខរាវិរុទ្ធ ឃ្លោងឃ្លា និងចំណុចខ្វះខាតដោយប្រការណាមួយជាក់ជាមិនខាន។ ដូច្នេះយើងខ្ញុំសូមទទួលការខន្តី អភ័យទោសពីសំណាក់បណ្ដាអ្នកអាន អ្នកសិក្សា សាស្រាចារ្យ និងបណ្ដាប្រជាពលរដ្ឋខ្មែរទាំងឡាយដែលមានចំណេះដឹងជ្រៅជ្រះ ហើយយើងខ្ញុំព្រមទទួល និងសូមស្វាគមន៍ដោយសេចក្តីរីករាយនូវរាល់មតិរិះគន់ក្នុងន័យស្ថាបនា ដើម្បីជាការកែតម្រូវដ៏ប្រសើរឡើង។

ជាចុងក្រោយក្នុងនាមយើងខ្ញុំទាំងពីររូបជានិស្សិតដែលកំពុងសរសេរសារណានេះឡើង យើងខ្ញុំសង្ឃឹមថាអត្ថបទចងក្រងមួយនេះនឹងអាចជាប្រយោជន៍សម្រាប់ធ្វើជាមូលដ្ឋានក្នុងការយល់ដឹងក៏ដូចជាអាចបម្រើដល់ជីវភាពរបស់ប្រជាពលរដ្ឋខ្មែរអំពីលក់ទិញអចលនវត្ថុឱ្យមានភាពស្របច្បាប់នៅកម្ពុជា។ ហើយឆ្លៀតក្នុងឱកាសនេះយើងខ្ញុំសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅជូនចំពោះអស់លោកអ្នកជាអ្នកអាន អ្នកស្រាវជ្រាវបន្តមកលើសារណាមួយនេះដោយការយកចិត្តទុកដាក់ និង សូមឱ្យអស់លោកជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀង ឃ្លាតឡើយ៕

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១
## ការបង្កើតកិច្ចសន្យាលក់ ទិញអចលនវត្ថុ

**១.១. លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាលក់ទិញអចលនវត្ថុ** ........ ៤

**១.១.១. លក្ខខណ្ឌគ្រឹះ** ........ ៤

១.១.១.១. ការព្រមព្រៀង ........ ៥

១.១.១.២. សមត្ថភាពភាគីនៃកិច្ចសន្យា ........ ១០

១.១.១.៣. កម្មវត្ថុនៃកិច្ចសន្យា ........ ១៤

**១.១.២. លក្ខខណ្ឌទម្រង់** ........ ១៨

១.១.២.១. លិខិតឯកជន ........ ១៩

១.១.២.២. លិខិតយថាភូត ........ ១៩

**១.២. វិការៈនៃកិច្ចសន្យា** ........ ២១

**១.២.១.ករណីដែលចាត់ទុកថាមានវិការៈក្នុងកិច្ចសន្យា** ........ ២១

១.២.១.១. ការភាន់ច្រឡំ ........ ២២

១.២.១.២. ការឆបោក ........ ២៣

១.២.១.៣. ការគម្រាមកំហែង ........ ២៤

១.២.១.៤. ព័ត៌មានមិនពិត ........ ២៥

១.២.១.៥. ការរំលោភបំពានលើស្ថានភាព ........ ២៦

១.២.១.៦. អំពើកេងយកចំណេញហួសហេតុ ........ ២៦

១.២.១.៧. ការបង្ហាញឆន្ទៈមិនពិត ........ ២៧

**១.២.២. ការលុបចោលកិច្ចសន្យា** ........ ២៧

១.២.២.១. មូលហេតុនៃការលុបចោលកិច្ចសន្យា ........ ២៨

១.២.២.២. សិទ្ធិលុបចោលកិច្ចសន្យា ........ ២៨

# ជំពូកទី២
# អានុភាពនៃកិច្ចសន្យាលក់ និញអចលនវត្ថុ

**២.១. សិទ្ធិ និងករណីយកិច្ចរបស់ភាគីនៃកិច្ចសន្យា**.............................................................៣០

**២.១.១. សិទ្ធិរបស់ភាគីអ្នកលក់**.............................................................................................៣០

២.១.១.១. សិទ្ធិទាមទារឱ្យប្រគល់ថ្លៃទិញអចលនវត្ថុ ........................................................................៣១

២.១.១.២. សិទ្ធិជួសជុលរបស់អ្នកលក់.......................................................................................៣១

២.១.១.៣. សិទ្ធិតវ៉ារបស់អ្នកលក់ .............................................................................................៣២

២.១.១.៤. សិទ្ធិទទួលផលរបស់អ្នកលក់.....................................................................................៣៣

**២.១.២. ករណីយកិច្ចរបស់អ្នកលក់**.........................................................................................៣៣

២.១.២.១. ករណីយកិច្ចត្រូវពន្យល់ ឬ ការផ្តល់ព័ត៌មាន..................................................................៣៣

២.១.២.២. ករណីយកិច្ចប្រគល់អចលនវត្ថុ...................................................................................៣៤

២.១.២.៣. ករណីយកិច្ចក្នុងការផ្ទេរសិទ្ធិ........................................................................................៣៥

២.១.២.៤. ករណីយកិច្ចក្នុងការធានាចំពោះកម្មវត្ថុ .........................................................................៣៥

**២.១.៣. សិទ្ធិរបស់អ្នកទិញ** .....................................................................................................៣៧

២.១.៣.១. សិទ្ធិទាមទារឱ្យអនុវត្តពេញលេញ..................................................................................៣៧

២.១.៣.២. សិទ្ធិបដិសេធមិនបង់ថ្លៃទិញ .......................................................................................៣៨

២.១.៣.៣. សិទ្ធិទាមទារឱ្យបន្ថយថ្លៃទិញ .......................................................................................៣៨

២.១.៣.៤. សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា និង សិទ្ធិតវ៉ាដោយមានការបារម្ភ ...................................................៣៨

**២.១.៤. ករណីយកិច្ចរបស់អ្នកទិញ** ..........................................................................................៣៩

២.១.៤.១. ករណីយកិច្ចបង់ថ្លៃទិញ .............................................................................................៣៩

២.១.៤.២. ករណីយកិច្ចទទួលវត្ថុដែលបានទិញ.............................................................................៣៩

**២.២. ការផ្ទេរកម្មសិទ្ធិតាមរយៈកិច្ចសន្យាលក់ទិញអចលនវត្ថុ**...........................................................៤០

**២.២.១. នីតិវិធីនៃការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ** .........................................................................៤០

២.២.១.១. ការដាក់ពាក្យសុំចុះបញ្ជី...........................................................................................៤០

២.២.១.២. ការចូលរួមដោយអាជ្ញាធរមូលដ្ឋាន ..............................................................................៤៥

២.២.១.៣. ស្ថាប័នមានសមត្ថកិច្ចក្នុងការចុះបញ្ជីផ្ទេរកម្មសិទ្ធិ ........ ៤៥

២.២.១.៤. ការបង់ពន្ធប្រថាប់ត្រា ........ ៤៧

២.២.១.៥. ការប្រគល់ប័ណ្ណកម្មសិទ្ធិ ........ ៤៨

**២.២.២. ការផ្ទេរសិទ្ធិលើចំណែកឯកជននៃអាគារសហកម្មសិទ្ធិ ........ ៤៨**

**២.៣. ការរំលាយកិច្ចសន្យាលក់ទិញអចលនវត្ថុ ........ ៥០**

**២.៣.១. ប្រភពនៃការរំលាយកិច្ចសន្យា ........ ៥០**

២.៣.១.១. សិទ្ធិរំលាយដែលបានកំណត់នៅក្នុងច្បាប់ ........ ៥១

២.៣.១.២. សិទ្ធិរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងកិច្ចសន្យា ........ ៥១

២.៣.១.៣. សិទ្ធិរំលាយកិច្ចសន្យាតាមការព្រមព្រៀងរបស់ភាគី ........ ៥១

**២.៣.២. ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ........ ៥២**

២.៣.២.១. អនុវត្តយឺតយ៉ាវជាមួយនឹងការដាស់តឿន ........ ៥២

២.៣.២.២. អនុវត្តយឺតយ៉ាវចំពោះសកម្មភាពដែលមានកំណត់ពេលវេលា ........ ៥៣

២.៣.២.៣. អលទ្ធភាពនៃការអនុវត្តកាតព្វកិច្ច ........ ៥៤

២.៣.២.៤. ការបាត់បង់នូវទំនុកចិត្តរវាងគ្នា ........ ៥៤

**២.៣.៣. ការបង្ហាញឆន្ទៈរំលាយ ........ ៥៤**

**២.៣.៤. អានុភាពនៃការរំលាយកិច្ចសន្យា ........ ៥៥**

**២.៣.៥. អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យា ........ ៥៥**

**សេចក្តីសន្និដ្ឋាន ........ ៥៦**

**អនុសាសន៍ ........ ៥៨**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

ប្រទេសកម្ពុជាជាប្រទេសដែលធ្លាប់ឆ្លងកាត់នូវសង្គ្រាមយ៉ាងរាំរ៉ៃ បើទោះបីជាសង្គ្រាមត្រូវបានបញ្ចប់ជាស្ថាពរក៏ដោយក៏ការរីកចម្រើននៅមានលក្ខណៈទាបនៅឡើយស្ទើរគ្រប់វិស័យ សេដ្ឋកិច្ចជាតិក៏នៅមានលក្ខណៈទន់ខ្សោយការបង្កើតច្បាប់ជាតិនៅមានកម្រិត។វាខុសប្លែកពីបច្ចុប្បន្នភាពនៅប្រទេសកម្ពុជាដែលកំពុងរីកចម្រើននឹងបន្តដំណើរទៅមុខឥតឈប់ឈរដោយសារមានការចូលរួមចំណែកលើគ្រប់វិស័យទាំងវិស័យនយោបាយនិងវិស័យសេដ្ឋកិច្ច។ នៅក្នុងវិស័យសេដ្ឋកិច្ចនាពេលបច្ចុប្បន្ននេះកម្ពុជាមានលក្ខណៈល្អប្រសើរជាងមុនបើធៀបទៅនឹងអតីតកាលភាពរីកចម្រើននៃសេដ្ឋកិច្ចជាតិបានចូលរួមលើគ្រប់វិស័យក្នុងនោះក៏មានវិស័យអចលនវត្ថុផងដែរ ដែលមានសន្ទុះតាមរយៈការវិនិយោគពីបរទេសការកកើតនូវហេដ្ឋារចនាសម្ព័ន្ធគ្រប់ទីកន្លែងរួមទាំងកំណើនប្រជាជនដែលត្រូវការជាចាំបាច់នូវដី លំនៅឋាន ហើយក៏មានផងដែលនូវការប្រកួតប្រជែងក្នុងការធ្វើជំនួញលើវិស័យដែលទាក់ទងនឹងអចលនវត្ថុនេះជាដើម កត្តាអស់នេះហើយដែលធ្វើឱ្យតម្លៃនៃអចលនវត្ថុនៅកម្ពុជាមានការកើនឡើង និង មានការរីកសាយលើសកម្មភាពលក់ទិញអចលនវត្ថុគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា។ ចំពោះកិច្ចសន្យាលក់ទិញអចលនវត្ថុបច្ចុប្បន្ននៅកម្ពុជាដែលបានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានធ្វើឱ្យច្បាប់ភូមិបាលឆ្នាំ ២០០១ លើចំណុចខ្លះ និងច្បាប់ស្តីពីកិច្ចសន្យាឆ្នាំ ១៩៨៨ លែងមានអានុភាពបន្តទៀត។ ប៉ុន្តែដោយសារប្រទេសជាតិមានការអភិវឌ្ឍន៍ទៅមុខ ដូច្នេះក្រមរដ្ឋប្បវេណីចែងពីកិច្ចសន្យាលក់ទិញអចលនវត្ថុក៏ត្រូវបន្ថែមទៅលើលិខិតបទដ្ឋានគតិយុត្តនានានៃក្រសួងពាក់ព័ន្ធដើម្បីឱ្យការបង្កើត និងការអនុវត្តកិច្ចសន្យាលក់ទិញអចលនវត្ថុកាន់តែមានប្រសិទ្ធិភាពនិងភាពយុត្តិធម៌។ នៅក្នុងរូបភាពបច្ចុប្បន្ននេះកិច្ចសន្យាលក់ទិញលើអចលនវត្ថុមិនមែនដូចគោលបំណងរបស់ច្បាប់ទេសកម្មភាពខ្លះភាគីមិនយល់ពីគ្នានាំឱ្យមានការបំពានធ្ងន់ធ្ងរកើតជាវិការៈនៃកិច្ចសន្យានោះ និង ភាពអយុត្តិធម៌ទៅលើប្រជាជនស្លូតត្រង់និងគ្មានចំណេះដឹងជ្រៅជ្រះទាក់ទង់ទៅនឹងវិស័យមួយនេះដោយសារការមិនយល់នូវច្បាប់។ ដូច្នេះដើម្បីឱ្យការធ្វើកិច្ចសន្យាលក់ទិញអចលនវត្ថុរវាងអ្នកលក់ និង អ្នកទិញរក្សាបាននូវផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមកជៀសវាងនូវភាពអយុត្តិធម៌តាមរយៈការបន្លំបោកប្រាសនិងដើម្បីកុំឱ្យកើតមាននូវវិវាទខាតពេលវេលានាថ្ងៃខាងមុខរបស់ប្រជាពលរដ្ឋខ្មែរទូទៅទើប យើងខ្ញុំសូមរំលេចនូវប្រធានបទមួយស្តីអំពី« **របបគតិយុត្តនៃកិច្ចសន្យាលក់ទិញអចលនវត្ថុនៅកម្ពុជា** » មកធ្វើជាសារណាបញ្ចប់ការសិក្សានាពេលនេះ។

ការយល់ដឹងអំពីអ្វីជាកិច្ចសន្យាលក់ទិញ និង អ្វីជាអចនវត្ថុគឺជាចំណុចចាប់ផ្តើមដែលអាចឈានទៅដល់ការបកស្រាយមួយប្រកបដោយភាពក្បោះក្បាយ និង មានទទ្បីករណ៍ច្បាស់លាស់ចាប់ពីដំណើរនៃការបង្កើតកិច្ចសន្យារហូតដល់កិច្ចសន្យាត្រូវបានបញ្ចប់ក្នុងការលក់ទិញអចលនវត្ថុ។ ដូចនេះក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានកំណត់អំពីកិច្ចសន្យាលក់ទិញថា គឺជាកិច្ចសន្យាអញ្ញមញ្ញ ដែលក្នុងកិច្ចសន្យា

ភាគីមានបន្ទុកបំពេញកាតព្វកិច្ចជាតាវកាលិកឱ្យគ្នាទៅវិញទៅមក។ ក្នុងនោះមានភាគីម្ខាង ហៅថា "អ្នកលក់" មានករណីយកិច្ចត្រូវប្រគល់ ឬ ផ្ទេរកម្មសិទ្ធិលើវត្ថុណាមួយទៅឱ្យភាគីម្ខាងទៀត ហៅថា"អ្នកទិញ" ហើយអ្នកទិញនេះ មានករណីយកិច្ចត្រូវចេញថ្លៃជាប្រាក់ទៅឱ្យអ្នកលក់។ ចំណែកឯអចលនវត្ថុដោយយោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ អចលនវត្ថុត្រូវបានបែងចែកជា០៣ (បី)ប្រភេទ ដូចជា៖ ១. អចលនវត្ថុពីកំណើត ( អចលនវត្ថុពីកំណើតមួយដែលមានលក្ខណៈស្ថិតស្ថេរ និងជាក់លាក់ជាងគេ ដោយសារវាសំដៅទៅលើ ប្រភេទជា ដីធ្លី គេហដ្ឋានដែលសង់លើគ្រឹ...ហើយមិនអាចរំកិល ឬ ផ្លាស់ប្តូរកន្លែងបាន) ២. អចលនវត្ថុតាមភ័ព្វព្រេងវាសនា (អចលនវត្ថុពីភ័ព្វវាសនាគឺជាវត្ថុទាំងពួងដែលមានដើមកំណើតជាចលនវត្ថុ ប៉ុន្តែត្រូវបានគេចាត់ទុកជាអចលនវត្ថុ ព្រោះវាជាបរិវារនៃអចលនវត្ថុត្រូវនៅជាប់នឹងអចលនវត្ថុហើយជារបស់កើតឡើងពីអចលនវត្ថុ) និង ៣.អចលនវត្ថុតាមការកំណត់របស់ច្បាប់(ជាសិទ្ធិប្រត្យក្សឬសិទ្ធិភណ្ឌិកលើអចលនវត្ថុ និង ចលនវត្ថុដែលត្រូវបានច្បាប់កំណត់ជាអចលនវត្ថុ ប៉ុន្តែ ច្បាប់ភូមិបាលមិនបានកំណត់ថាចលនវត្ថុណាខ្លះត្រូវបានចាត់ទុកជាអចលនវត្ថុតាមការកំណត់របស់ច្បាប់នោះទេ)។ រួមមកវិញប្រតិបត្តិការនៃការលក់ទិញអចលនវត្ថុទាំងអស់សុទ្ធតែអាចកើតឡើងបាន ប៉ុន្តែដូចជាប្រភេទនៃអចលនវត្ថុតាមភ័ព្វវាសនាគឺមានការភ្ជាប់ខ្លួនទៅនឹងអចលនវត្ថុ ដូចជា ផ្ទះ អាគារសហកម្មសិទ្ធិ ដីធ្លីជាដើម ដូច្នេះនៅពេលប្រគល់ និងផ្ទេរកម្មសិទ្ធិតាមគោលបំណងនៃកិច្ចសន្យាគឺវាទៅទាំងព្រម។ ចំណែកឯប្រភេទនៃអចលនវត្ថុតាមការកំណត់ដោយច្បាប់វាក៏អាចជាកម្មវត្ថុលក់ទិញបានដែរ ប៉ុន្តែវាជារូបភាពមួយដ៏កម្រកើតមានដែលយើងមិនបានលើកមកបកស្រាយក្នុងសារណានេះឡើយ យើងនឹងលើកយកតែអចលនវត្ថុពីកំណើតដូចះ ដីធ្លី សំណង់ អាគារ ផ្ទះសម្បែងជាអាទិ៍ ដែលជាអចលនវត្ថុងាយក្នុងការលក់ទិញនឹងស្របតាមការបកស្រាយទាក់ទង់ទៅនឹងប្រភេទអចលនវត្ថុ ដែលកំណត់នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ កិច្ចសន្យាលក់ទិញអចលនវត្ថុមាននីតិវិធីស្មុគស្មាញចាប់តាំងពីដំណាក់កាលចុះកិច្ចសន្យាដំណាក់កាលអនុវត្តកិច្ចសន្យា និង នីតិវិធីក្នុងការបញ្ចប់កិច្ចសន្យាដោយសារមានលក្ខខណ្ឌតម្រូវដែលភាគីចាំបាច់ត្រូវតែបំពេញ។

ដូច្នេះដើម្បីអាចបង្កើតកិច្ចសន្យាលក់ទិញអចលនវត្ថុដូចជាដីធ្លី ផ្ទះ អាគារ បុរី ខុនដូរ ជាអាទិ៍ តើប្រជាពលរដ្ឋដែលជាគូភាគីនៃកិច្ចសន្យានោះត្រូវធ្វើដូចម្តេចដើម្បីឱ្យមានភាពងាយស្រួល និង មានភាពឆាប់រហ័សហើយអាចធានាបានថាមានអានុភាពទៅតាមបទបញ្ញត្តិច្បាប់ជាធរមាន? ដើម្បីអាចឈានទៅដល់អានុភាពនៃកិច្ចសន្យាលក់ទិញអចលនវត្ថុ តើគូភាគីនៃកិច្ចសន្យាត្រូវបំពេញលក្ខខណ្ឌបែបណាដើម្បីឱ្យកិច្ចសន្យាមានសុពលភាព? នៅពេលកិច្ចសន្យាមានសុពលភាពហើយតើគូភាគីត្រូវអនុវត្តទៅលើកិច្ចសន្យាតាមរយៈសិទ្ធិ និង ករណីយកិច្ចបែបណាទើបអាចឱ្យកិច្ចសន្យាមាននូវអានុភាពរហូតដល់ការផ្ទេរកម្មសិទ្ធិ? ដំណាក់កាលនៃការផ្ទេរ

កម្មសិទ្ធិជាដំណាក់កាលបញ្ចប់កិច្ចសន្យា ដូចនេះតើការផ្ទេរកម្មសិទ្ធិមាននីតិវិធីបែបណាទើបអាចផ្ទេរកម្មសិទ្ធិពីអ្នកលក់ទៅអ្នកទិញបានដោយស្ថាពរ ?

ដោយឡែកនៅកម្ពុជាការកាន់កាប់ចំពោះអចលនវត្ថុមានខ្លះដោយស្របច្បាប់ហើយខ្លះក៏មិនស្របច្បាប់ អចលនវត្ថុខ្លះមានប្លង់ និងខ្លះទៀតគ្មានប្លង់។ ភាពស្រពិចស្រពិលទាំងនេះអាចបង្កឱ្យមានវិវាទនៅពេលការលក់ទិញអចលនវត្ថុបានកើតឡើង។ ដូចនេះទំរាំតែដល់នីតិវិធីប្រគល់ឬផ្ទេរ វាឆ្លងកាត់ជាច្រើនដំណាក់កាលហើយដំណាក់កាលនីមួយៗសុទ្ធតែកំណត់ដោយច្បាប់ ដូច្នេះបើដំណាក់កាលណាមួយ ឬ ចំណុចណាមួយដែលប្រាស់ចាកពីច្បាប់កិច្ចសន្យានឹងត្រូវចាត់ទុកជាមោឃៈភាពឬលុបចោល។ ដើម្បីបញ្ចៀសនូវបញ្ហាចម្រូងចម្រាស់នានាដែលអាចកើតមានទាំងពេលចុះកិច្ចសន្យា និង ក្រោយពេលបញ្ចប់កិច្ចសន្យាដើម្បីជាការឆ្លើយតបទៅនឹងការចង់យល់ដឹង ការការពារសិទ្ធិ ភាពងាយស្រួល ឆាប់រហ័ស និង មិនមានការបំពានក្នុងករណីណាមួយ ពោលគឺដើម្បីយុត្តិធម៌និងផលប្រយោជន៍របស់ប្រជាពលរដ្ឋខ្មែរទូទៅដោយស្របទៅនឹងបរិបទនៃសង្គមដែលរីកចម្រើនលើវិស័យអចលនវត្ថុនេះដោយមានការបង្កើតនូវបទបញ្ញត្តិនានាដែលទើបតែបង្កើតថ្មីដូចជា ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសក្រសួង អន្តរក្រសួង សុទ្ធតែមានការវិវត្តន៍ និង ការកែតម្រូវ ។

ចំពោះគោលបំណងនៅក្នុងការស្រាវជ្រាវនេះមិនបានប្រាស់ចាកពីបទបញ្ញត្តិច្បាប់ទាំងអស់នោះឡើយ។ ដូចនេះការពាំនាំនេះអាចជាមូលដ្ឋានក្នុងការយកទៅអនុវត្តបានប្រកបដោយប្រសិទ្ធិភាព ទៅលើកិច្ចសន្យាលក់ទិញអចលនវត្ថុគ្រប់ប្រភេទដែលអាចលក់ទិញបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការលក់ទិញអចលនវត្ថុតាមរយៈកិច្ចសន្យាកម្ពុជាពីឆ្នាំ១៩៩៣ ដល់បច្ចុប្បន្នត្រូវបានអនុញ្ញាត និងស្ថិតក្រោមការគ្រប់គ្រងដោយក្រមរដ្ឋប្បវេណី និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។ នូវរាល់បទបញ្ញត្តិដែលពាក់ព័ន្ធទៅនឹងកិច្ចសន្យាលក់ទិញអចលនវត្ថុត្រូវបានលើកឡើងមកទៅតាមលំដាប់លំដោយនៃលក្ខខណ្ឌ និង នីតិវិធីដោយរួមផ្សំទៅនឹងការប្រមូលគំនិតរួមនឹងការបកស្រាយខ្លះៗតាមគោលបំណងនៃច្បាប់ដើម្បីជាការងាយអានងាយយល់ និង ងាយអនុវត្តន៍។ ដូច្នេះរាល់ចម្ងល់ដែលទាក់ទងទៅនឹងរបបគតិយុត្តនៃកិច្ចសន្យាលក់ទិញអចលនវត្ថុនៅកម្ពុជានឹងត្រូវបកស្រាយនៅក្នុងសៀវភៅសារណានេះដែលបានធ្វើការបែងចែករចនាសម្ព័ន្ធតាមរយៈការស្រាវជ្រាវដើម្បីឱ្យមានភាពច្បាស់លាស់ និងប្រាកដទៅលើច្បាប់ យើងខ្ញុំបានបែងចែកជា២ជំពូក។ ជំពូកទី១ ស្តីអំពីការបង្កើតកិច្ចសន្យាលក់ ទិញអចលនវត្ថុ ដែលត្រូវបែងចែកជាពីរចំណុចធំៗ។ ១.១ អំពីលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាលក់ទិញអចលនវត្ថុ និង ១.២ អំពីមូលហេតុនៃវិការៈក្នុងការបង្កើតកិច្ចសន្យា។ រីឯជំពូកទី២ ស្តីអំពីអានុភាពនៃកិច្ចសន្យាលក់ ទិញអចលនវត្ថុដែលត្រូវបែងចែកជាបីចំណុចធំៗ ។ ២.១ អំពីសិទ្ធិ និងករណីយកិច្ចរបស់ភាគីនៃកិច្ចសន្យា ២.២ អំពីអានុភាពនៃការផ្ទេរកម្មសិទ្ធិនៅក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុនិង ២.៣ អំពីការរំលាយកិច្ចសន្យាលក់ទិញអចលនវត្ថុ។

# ជំពូកទី១
# ការបង្កើតកិច្ចសន្យាលក់ ទិញ
# អចលនវត្ថុ

# ជំពូកទី១

# ការបង្កើតកិច្ចសន្យាលក់ ទិញអចលនវត្ថុ

ការលក់ទិញអចលនវត្ថុអាចកើតឡើងបាន លុះត្រាតែមានការបង្កើតកិច្ចសន្យា។ នៅក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុ ការបង្កើតកិច្ចសន្យាជាលាយលក្ខណ៍អក្សរតាមទម្រង់ជាលិខិតយថាភូតគឺជាការសំខាន់ចាំបាច់ វាផ្សេងពីកិច្ចសន្យាលក់ទិញទូទៅដោយមិនតម្រូវថាត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរនោះទេ។ ដូច្នេះចំពោះការបង្កើតកិច្ចសន្យា គឺមានគោលបំណងសំដៅដល់ការធ្វើយ៉ាងណាឱ្យកិច្ចសន្យានោះមាននូវសុពលភាព (១.១) និង ត្រូវជៀសវាងនូវការបង្កើតកិច្ចសន្យាដោយសកម្មភាពណាដែលបង្កឱ្យមាននូវវិការៈក្នុងកិច្ចសន្យា (១.២) ដែលទាំងនេះត្រូវបានច្បាប់ចាត់ទុកជាចំណុចសំខាន់ក្នុងការបង្កើតកិច្ចសន្យាលក់ទិញអចលនវត្ថុ។

## ១.១. លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាលក់ទិញអចលនវត្ថុ

ជាទូទៅការបង្កើតកិច្ចសន្យាលក់ទិញអចលនវត្ថុមានច្រើនបែបច្រើនទម្រង់ ចំពោះកិច្ចសន្យាខ្លះមានខ្លឹមសារវែង និង លក្ខខណ្ឌសម្រាប់ចង់កាតព្វកិច្ចរបស់គូភាគីមានច្រើន ចំណែកឯកិច្ចសន្យាលក់ទិញអចលនវត្ថុខ្លះទៀតមានខ្លឹមសារ និង លក្ខខណ្ឌសម្រាប់ចង់កាតព្វកិច្ចរបស់គូភាគីតិច ដែលទាំងនេះគឺវាអាស្រ័យទៅតាមការចរចារនិងការព្រមព្រៀងរវាងគូភាគី (អ្នកលក់ និង អ្នកទិញ) ឬ អាស្រ័យទៅលើអ្នកតាក់តែងកិច្ចសន្យា (មេធាវី)នោះផងដែរ។ ប៉ុន្តែការគោរពនូវលក្ខខណ្ឌសុពលភាព និង ទាមទារឱ្យមានសុពលភាពនៃកិច្ចសន្យាលក់ទិញអចលនវត្ថុគឺមិនគិតទៅលើកិច្ចសន្យានោះវែង ឬ ខ្លី តិច ឬ ច្រើននោះទេ គឺច្បាប់ផ្តោតសំខាន់ទៅលើការបង្ហាញឆន្ទៈត្រូវគ្នារវាងបុគ្គលពីរនាក់គឺអ្នកលក់ និង អ្នកទិញដែលត្រូវមានការគោរពនូវ០២(ពីរ)លក្ខខណ្ឌដើម្បីសុពលភាពនៃកិច្ចសន្យានោះរួមមាន៖ លក្ខខណ្ឌគ្រឹះ (១.១.១) និង លក្ខខណ្ឌទម្រង់ (១.១.២) ។

### ១.១.១. លក្ខខណ្ឌគ្រឹះ

លក្ខខណ្ឌគ្រឹះ គឺជាលក្ខខណ្ឌដើមដំបូងក្នុងការបង្កើតកិច្ចសន្យាដែលធ្វើឱ្យកិច្ចសន្យាមានសុពលភាពបាន គឺកើតឡើងតាមរយៈការព្រមព្រៀងរបស់គូភាគីបន្ទាប់ពីមានការព្រមព្រៀងរួចហើយមិនមែនមានន័យថាគ្រប់បុគ្គលទាំងឡាយសុទ្ធតែមានសមត្ថភាពក្នុងការធ្វើកិច្ចសន្យានោះទេ គឺគេត្រូវពិនិត្យទៅលើសមត្ថភាពរបស់បុគ្គលជាភាគី និង ដើម្បីដឹងអំពីវត្ថុបំណងក្នុងកិច្ចសន្យាលក់ទិញគេត្រូវពិនិត្យទៅលើខ្លឹមសារដែលជាកម្មវត្ថុនៃកិច្ចសន្យា។ ដូចនេះនៅក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុភាគីត្រូវមានលក្ខខណ្ឌចំនួន០៣(បី) ជាចម្បងគឺការព្រមព្រៀង(១.១.១.១)សមត្ថភាពភាគីនៃកិច្ចសន្យា(១.១.១.២) និង កម្មវត្ថុនៃកិច្ចសន្យា(១.១.១.៣)។

### **១.១.១.១. ការព្រមព្រៀង**

ជាគោលការណ៍ការព្រមព្រៀងគឺជាការបង្ហាញឆន្ទៈរួមគ្នារបស់គូភាគីដែលមានសិទ្ធិ និង កាតព្វកិច្ចនៅក្នុងកិច្ចសន្យាដែលបានសម្តែងនូវបំណងនោះចេញមកក្រៅ។ ការព្រមព្រៀងដោយឆន្ទៈជាការព្រមព្រៀងដោយពិតប្រាកដហើយសំដៅដល់ពេលដែលសំណើ និង ស្វីការបានជួបគ្នាដោយលក្ខណៈពេញលេញត្រឹមត្រូវតាមច្បាប់។

**ក. សំណើ**

ការបង្កើតកិច្ចសន្យាផ្តើមចេញពីការដាក់សំណើហើយសំណើនេះទៀតសោត គឺជាសំណើដែលមានអានុភាព និង គោរពតាមលក្ខខណ្ឌនៃអំឡុងពេលនៃសំណើរបស់ភាគីម្ខាងទៅភាគីម្ខាងទៀត។

ដូចនេះសំណើ គឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ។[1] មានន័យថាសកម្មភាពនៅក្នុងការលក់ទិញអចលនវត្ថុភាគីម្ខាងជាអ្នកទិញបានប្រាប់ពីគោលបំណងរបស់ខ្លួនទៅភាគីម្ខាងទៀតជាអ្នកលក់ថាត្រូវការទិញពីអ្នកលក់។ ក្នុងករណីនេះនៅពេលអ្នកទិញបានប្រាប់ទៅអ្នកលក់វាជាការបង្ហាញឆន្ទៈ នៅពេលដែលអ្នកលក់បានឆ្លើយតបចំពោះសំណើនោះវាគឺជាស្វីការ។ ពេលដែលសំណើត្រូវបានឆ្លើយតបដោយស្វីការទាំងស្រុងនោះចំណងគតិយុត្តក្នុងការបង្កើតកិច្ចសន្យាបានកើតឡើងតាមរយៈឆន្ទៈរបស់អ្នកទិញ។ ត្រង់នេះវាគឺជាបំណងភ្ជាប់ឆន្ទៈរបស់អ្នកទិញជាមួយចំណងគតិយុត្តតាមរយៈការបង្កើតកិច្ចសន្យា នៅពេលដែលស្វីការបានកើតឡើងចំពោះសំណើនោះ។ការធ្វើសំណើអាចមានជាការអញ្ជើញឱ្យធ្វើសំណើបាន ការអញ្ជើញឱ្យធ្វើសំណើដែលមិនមែនក្លាយជាសំណើតែម្តងនោះទេគឺជាការទាក់ទាញឱ្យអ្នកដទៃមកធ្វើសំណើវិញ។[2] ដូច្នេះការអញ្ជើញឱ្យធ្វើសំណើចាប់ផ្តើមមានអានុភាពនៅពេលដែលភាគីជាអ្នកដាក់សំណើ បានបង្ហាញឆន្ទៈរបស់ខ្លួនទៅភាគីដែលជាអ្នកអញ្ជើញឱ្យធ្វើសំណើមិនមែនការអញ្ជើញឱ្យនរណាម្នាក់មកបង្ហាញឆន្ទៈហើយគេចាត់ទុកថាមានអានុភាពនោះទេ។

អានុភាពនៃសំណើមានការចាប់ផ្តើម គឺនៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត[3]មានន័យថាក្នុងករណីដែលសំណើបានទៅដល់ភាគីម្ខាងទៀតជាអ្នកទទួលសំណើតាមរយៈមធ្យោបាយណាក៏ដោយ ដែល

---

[1] មាត្រា ៣៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ។

[2] បញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី របស់ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិសាស្ត្រាចារ្យ Fukuoka Fumie និង Umemoto Yumi ។

[3] មាត្រា ៣៣៧ កថាខណ្ឌទី២ វាក្យខណ្ឌ១ នៃក្រមរដ្ឋប្បវេណីដដែល ។

អ្នកទទួលសំណើបានដឹង បានអាន ឬ ក្នុងករណីដែលសំណើបានទៅដល់ហើយ តែអ្នកទទួលមិនបានដឹងដែល បណ្តាលមកពីកំហុសខ្លួន នោះគេក៏ចាត់ទុកថាសំណើនោះមានអានុភាពដែរ។ចំពោះការអនុវត្តសំណើអាចមាន ការបែងចែកជាពីរលក្ខខណ្ឌគឺសំណើដែលអាចមាន និង គ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ។

**ក.១. សំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្វីការ និង ការដកសំណើនោះ**

សំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្វីការមាន ន័យថាអ្នកដាក់សំណើអាចកំណត់អំឡុង ពេលសម្រាប់ការផ្តល់ស្វីការហើយរយៈពេលនៃការធ្វើសំណើ គឺចាប់គិតពីថ្ងៃជូនដំណឹងអំពីសំណើនោះក្នុង ករណីដែលអ្នកស្នើមិនបានកំណត់ពេលផ្សេង ករណីនេះអំឡុងពេលកំណត់សម្រាប់ស្វីការហាក់មានភាព មិនច្បាស់លាស់នៅក្នុងច្បាប់ដោយសារការអនុវត្តជាក់ស្តែងវាមានច្រើនករណីផ្សេងៗគ្នា។ សំណើដែល មានអំឡុងពេលសម្រាប់ធ្វើស្វីការមានគោលបំណងដើម្បីការពារផលប្រយោជន៍របស់អ្នកស្នើ ព្រោះថាអ្នកស្នើ អាចធ្វើសំណើទៅបុគ្គលផ្សេងទៀតនៅពេលដល់កាលកំណត់នៃសំណើ។

ចំពោះការដកសំណើគឺអ្នកស្នើមិនអាចដកសំណើនោះមកវិញបានទេដោយសារនៅពេល ដែលអ្នកដាក់ សំណើចង់ដកដោយចិត្តឯង មិនបានឯកភាពគ្នាជាមួយអ្នកទទួលសំណើវាអាចជាការខូចបង់នូវផលប្រយោជន៍ របស់អ្នកទទួលសំណើដែលមិនអាចរំពឹងទុកជាមុនបានទេ។[4]សំណើនោះនឹងផុតរលត់ដោយស្វ័យប្រវត្តិ ប្រសិនបើ ផុតកំណត់រយៈពេលដែលបានកំណត់សម្រាប់ធ្វើស្វីការ។ការបដិសេធសំណើក៏ជាប្រការមួយនៃការធ្វើឱ្យសំណើ អស់អានុភាពដែល គឺនៅពេលដែលសំណើនោះបានកំណត់អំឡុងពេលហើយអ្នកទទួលសំណើបានជូន ដំណឹងអំពីការបដិសេធនេះក្នុងអំឡុងពេលសម្រាប់ស្វីការនោះសំណើក៏ត្រូវបាត់បងអានុភាពដែរ។

**ក.២.សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការនិងការដកសំណើនោះ**

ចំពោះសំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ រវាងគូភាគីដែលកំពុងនិយាយគ្នានៅក្នុង ស្ថានភាពដែលអាចឆ្លើយតបភ្លាមៗបានសំណើនោះនឹងបាត់បង់អានុភាពប្រសិនបើអ្នកធ្វើស្វីការ មិនបាន ឆ្លើយភ្លាមៗទេនោះ។ ចំពោះការដកសំណើគ្មានកំណតអំឡុងពេលសម្រាប់ស្វីការមានអានុភាពលុះត្រាតែការ ជូនដំណឹងអំពីការដកសំណើនោះបានមកដល់ភាគីម្ខាងទៀតមុនពេលភាគីម្ខាងទៀតជូនដំណឹងអំពីស្វីការ។[5] ប៉ុន្តែប្រសិនបើសំណើនោះមិនមែនធ្វើឡើងក្នុងស្ថានភាពដែលភាគីមិនអាចឆ្លើយតបបានភ្លាមៗទេ នោះអ្នកស្នើ មិនអាចដកសំណើនោះដោយមិនទុកអំឡុងពេលសមរម្យ (សំដៅលើអំឡុងពេលមួយសម្រាប់វិនិច្ឆ័យថាទទួល

[4] មាត្រា ៣៣៨ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧ ។

[5] មាត្រា៣៣៩-១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីដដែល ។

យក ឬ បដិសេធហើយអំឡុងពេលសមរម្យនេះគឺផ្អែកតាមខ្លឹមសារនៃកិច្ចសន្យា និងទំហំនៃវត្ថុដែលអ្នកទទួលសំណើត្រូវគិតពិចារណានិងវិនិច្ឆ័យចំពោះសំណើនោះ)[6] បានទេ។ ប៉ុន្តែប្រសិនបើដំណឹងអំពីការដកសំណើវិញដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នានឹងពេលសំណើដល់ ឬ មុនពេលសំណើដល់នោះអានុភាពសំណើមិនត្រូវកើតឡើងឡើយ។ ចំណុចនេះគឺមានន័យថាការដកសំណើមានសុពលភាព ក្នុងករណីដែលការដកសំណើនេះមិនបានធ្វើឱ្យភាគីណាម្ខាងមានការខាតបង់នូវផលប្រយោជន៍ដែលបណ្តាលមកពីការទទួលសំណើនោះទេ។

**ខ. ស្វីការ**

ស្វីការ គឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ។[7] ការយល់ព្រមនេះត្រូវធ្វើឡើងដោយឆន្ទៈពិតប្រាកដគឺគ្មានការបង្ខិតបង្ខំពីអ្នកផ្តល់សំណើ ឬ តតិយជនឡើយ។ ជាគោលការណ៍កិច្ចសន្យាចាប់ផ្តើមបង្កើតឡើងដោយសារមានអានុភាពរបស់ស្វីការហើយស្វីការអាចកើតឡើងបាន ដោយសារមានអានុភាពរបស់សំណើ។ នៅក្នុងករណីដែលមានការបង្ហាញឆន្ទៈចំពោះការជូនដំណឹងទៅលើអ្វីមួយដែលមិនទាន់មានអត្ថិភាពនៃសំណើ វាមិនមែនជាស្វីការទេប៉ុន្តែវាគឺជាសំណើ។

ស្វីការដែលមានអានុភាព គឺនៅពេលដែលស្វីការនោះបានដល់អ្នកស្នើ។ ប៉ុន្តែប្រសិនបើដំណឹងអំពីការដកស្វីការដល់អ្នកស្នើនៅពេលព្រមគ្នានឹងពេលស្វីការដល់ ឬ មុនពេលស្វីការដល់នោះអានុភាពនៃស្វីការមិនត្រូវកើតឡើយ។[8] នៅត្រង់ចំណុចនេះវាមិនមានភាពខុសប្លែកគ្នាជាមួយនឹងអានុភាពរបស់សំណើទេ នៅពេលដែលសំណើបានមកដល់នោះអ្នកទទួលសំណើបានធ្វើការវិនិច្ឆ័យ(ចំពោះលក្ខខណ្ឌនានាដែលបានកំណត់ក្នុងសំណើ) ទៅលើសំណើដែលខ្លួនបានទទួលទោះដោយមធ្យោបាយណាក៏ដោយ។ ក្នុងករណីនេះប្រសិនបើអ្នកទទួលសំណើបានយល់ព្រមនោះ មានន័យថាអត្ថិភាពនៃស្វីការបានកើតឡើងតាមរយៈលក្ខខណ្ឌដែលឆ្លើយតបទៅសំណើវិញ។ នៅពេលដែលលក្ខខណ្ឌរបស់សំណើត្រូវគ្នា និង លក្ខខណ្ឌរបស់ស្វីការវាចាប់ផ្តើមធ្វើឱ្យស្វីការមានអានុភាពនិងឆ្ពោះទៅការបង្កើតកិច្ចសន្យាដែលមានសុពលភាព (មាត្រា៣៣៦-១នៃក្រមរដ្ឋប្បវេណី)។ ដោយឡែកក្នុងជូនដំណឹងអំពីស្វីការទៅអ្នកផ្តល់សំណើ គឺអាចធ្វើបានតាមរយៈមធ្យោបាយដោយសេរីដូចជា ការជួបផ្ទាល់មាត់ ឬ ការសរសេរជាលាយលក្ខលក្ខណ៍អក្សរ ការផ្តាំផ្ញើរ ឬ តាមសារអេឡិចត្រូនិចផ្សេងទៀតដែលអាចធានាថាអ្នកផ្តល់សំណើបានទទួលដឹង។ ដូចនេះស្វីការសំខាន់គឺការយល់ព្រមហើយការយល់ព្រមនេះទៀត

---

[6] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ២ គន្ថីទី៤ មាត្រា៣៣៩ (ភ្នំពេញ៖ ក្រសួងយុត្តិធម៌,២០១០)។

[7] មាត្រា ៣៣៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ។

[8] មាត្រា ៣៣៧ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណីដែរ។

សោតសំដៅលើគ្រប់លក្ខខណ្ឌនានាដែលបានផ្តល់ដោយសំណើមិនមានការកែប្រែ ឬ មានការបន្ថែមទៅលើលក្ខខណ្ឌដែលសំណើបានផ្តល់ឱ្យនោះឡើយ។

**ខ.១.ការមកដល់យឺតយ៉ាវរបស់ស្វីការ**

ការមកដល់យឺតយ៉ាវរបស់ស្វីការ អាចអនុវត្តបានចំពោះតែសំណើមានអំឡុងពេលសម្រាប់ស្វីការតែប៉ុណ្ណោះ។[9] នេះក៏ដោយសារតែវាបានកំណត់ច្បាស់លាស់ទាក់ទងទៅនឹងពេលវេលានៃការមកដល់នៃសំណើ និង ពេលវេលាដែលត្រូវផ្តល់សំណើចំណែកសំណើដែលគ្មានអំឡុងពេលវិញគឺអ្នកស្នើត្រូវទុកអំឡុងពេលសមរម្យដែលមិនមានភាពច្បាស់លាស់ហើយអាចបាត់បងអានុភាពទៅបានលុះតែមានការដកសំណើនោះ។ ក្នុងករណីនេះប្រសិនបើការជូនដំណឹងអំពីស្វីការរបស់ភាគីម្ខាង ទៅភាគីម្ខាងទៀតដែលស្ថិតក្នុងអំឡុងពេលដែលបានកំណត់នោះកិច្ចសន្យាត្រូវបានបង្កើតឡើងជាធម្មតា ប៉ុន្តែក្នុងករណីដែលការជូនដំណឹងនោះក្រោយអំឡុងពេលដែលបានកំណត់នោះសុពលភាពនៃស្វីការមិនអាចកើតឡើងបានឡើយ។ ការជូនដំណឹងមានភាពសំខាន់ណាស់ពីអ្នកស្នើទៅកាន់ភាគីម្ខាងទៀតជាអ្នកទទួលសំណើ អំពីភាពយឺតយ៉ាវនៅក្នុងការមកដល់នូវស្វីការរួមជាមួយ និង ការខកខានក្នុងការបង្កើតកិច្ចសន្យានោះទៅកាន់អ្នកធ្វើស្វីការដោយគ្មានការយឺតយ៉ាវដើម្បីជៀសវាងពីការយល់ខុសរបស់អ្នកជូនដំណឹងអំពីស្វីការថាស្វីការដែលខ្លួនបានផ្តល់ទៅឱ្យគឺមានអានុភាព។ ការជូនដំណឹងអំពីការយឺតយ៉ាវនេះជាករណីយកិច្ចរបស់អ្នកស្នើ ពីព្រោះការចរចារនៃកិច្ចសន្យាត្រូវអនុវត្តដោយភាពស្មោះត្រង់។ ក្នុងន័យនេះប្រសិនជាអ្នកស្នើមានការខកខានក្នុងការជូនដំណឹងអំពីការមកដល់យឺតយ៉ាវរបស់ស្វីការ នោះស្វីការដែលមកដល់យឺតយ៉ាវត្រូវចាត់ទុកថាមានអានុភាពវិញ។ [10]

ការជូនដំណឹងយឺតយ៉ាវចំពោះស្វីការទៅកាន់អ្នកស្នើ គឺអ្នកស្នើអាចចាត់ទុកថាស្វីការដែលបានមកដល់អ្នកស្នើក្រោយពេលផុតអំឡុងពេលសម្រាប់ស្វីការជាសំណើថ្មី។[11] ត្រង់នេះវាខុសពីការដកសំណើចំពោះស្វីការដែលគ្មានអំឡុងពេលកំណត់សម្រាប់ស្វីការ គឺមិនអាចចាត់ទុកថាជាសំណើថ្មីបានទេដោយសារតែអ្នកស្នើមានសិទ្ធិដកសំណើនោះបាននៅពេលដែលអ្នកស្នើគិតថាអំឡុងពេលសមរម្យបានកន្លងហួសទៅយូរហើយ កាលណាមានការដកសំណើជាមុន នោះជាធម្មតាអ្នកស្នើគាត់គិតថាការផ្តល់ស្វីការរបស់ខ្លួនមិនមានអានុភាពក្នុងការបង្កើតកិច្ចសន្យានោះទេ។

---

[9] មាត្រា ៣៤១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ។

[10] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ២ គន្លីទី៤ មាត្រា៣៤១ (ភ្នំពេញ៖ ក្រសួងយុត្តិធម៌,២០១០)។

[11] មាត្រា ៣៤១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីដដែល ។

ដូច្នេះក្នុងករណីមានការយឺតយ៉ាវនេះអ្នកធ្វើសំណើត្រូវជូនដំណឹងទៅអ្នកផ្តល់ស្ទីការដោយគ្មានការយឺតយ៉ាវទើបអាចចាត់ទុកថាស្ទីការដែលបានមកដល់យឺតយ៉ាវនោះគ្មានសុពលភាព ហើយអ្នកធ្វើសំណើអាចចាត់ទុកថាការផ្តល់ស្ទីការដោយការយឺតយ៉ាវនេះជាការផ្តល់សំណើជាថ្មីមកខ្លួន។ ប៉ុន្តែក្នុងពេលដែលការយឺតយ៉ាវនោះមិនបានជូនដំណឹងទៅអ្នកផ្តល់ស្ទីការទេនោះស្ទីការដែលមកដល់យឺតយ៉ាវគឺចាត់ទុកថាមានសុពលភាព។

**ខ.២. ស្ទីការដោយមានការបន្ថែម ការកែប្រែ**

ស្ទីការដោយមានការបន្ថែម ការកែប្រែសារធាតុចំពោះសំណើ មិនត្រូវក្លាយជាស្ទីការសុពលភាពទេ តែស្ទីការនោះមានអានុភាពជាសំណើថ្មី។[12]កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលអ្នកធ្វើសំណើដើមធ្វើស្ទីការចំពោះសំណើថ្មីនោះ។ ប្រសិនបើលក្ខខណ្ឌ ឬ ការកែប្រែដែលភ្ជាប់ជាមួយនឹងស្ទីការមិនធ្វើឱ្យមានការកែប្រែសារធាតុនៃសំណើទេស្ទីការនោះមានសុពលភាពលុះត្រាតែអ្នកស្នើមិនតវ៉ាភ្លាម។ អត្ថន័យនៃកិច្ចសន្យាដែលត្រូវកើតឡើងដោយស្ទីការនោះត្រូវទៅតាមអត្ថន័យនៃស្ទីការលុះត្រាតែអ្នកស្នើដែលបានទទួលស្ទីការមិនតវ៉ាភ្លាមៗទេ។[13]

សកម្មភាពមួយចំនួនក៏ត្រូវបានចាត់ទុកជាស្ទីការ ក្នុងករណីមិនចាំបាច់ឱ្យមានដំណឹងអំពីស្ទីការដោយសារឆន្ទៈរបស់អ្នកស្នើ ឬដោយសារទំនៀមទម្លាប់នៃកិច្ចការជំនួញ។[14] ប្រសិនបើសំណើនោះធ្វើឡើងជាសាធារណៈដោយមិនបានកំណត់ទៅលើបុគ្គលណាមួយទេការដកសំណើនោះក៏ធ្វើឡើងជាសាធារណៈដូចគ្នាដែរ។[15] ជាទូទៅចំពោះកិច្ចសន្យាចាប់ផ្តើមមានអានុភាពនៅពេលសំណើនិងស្ទីការត្រូវគ្នា។ ប៉ុន្តែចំពោះកិច្ចសន្យាលក់ទិញអចលនវត្ថុខុសពីកិច្ចសន្យាទូទៅ និង កិច្ចសន្យាលក់ទិញធម្មតាត្រង់ថាកិច្ចសន្យាលក់ទិញអចលនវត្ថុគឺចាំបាច់ត្រូវមានការប្រគល់ និង ការផ្ទេរកម្មសិទ្ធិទៅឱ្យភាគីម្ខាងទៀត។ ដូចនេះទោះបីជាសំណើ និង ស្ទីការត្រូវគ្នាក៏ដោយក៏កិច្ចសន្យានោះមិនទាន់មានអានុភាពនៅឡើយដែរ គឺស្ថិតក្នុងដំណាក់កាលជាសុពលភាពនៃកិច្ចសន្យាតែប៉ុណ្ណោះ ទាល់តែការលក់ទិញអចលនវត្ថុនោះធ្វើឡើងជាកិច្ចសន្យាតាមទម្រង់លិខិតយថាភូតទើបកិច្ចសន្យានោះមានអានុភាពតាមផ្លូវគតិយុត្ត។[16]

---

[12] ក្រុមការងារក្រសួងយុត្តិធម៌, មេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១, បោះពុម្ពលើកទី១ (ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការរបស់ក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន, ២០១៥) ទំព័រ១៩។

[13] មាត្រា ៣៤២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ។

[14] មាត្រា ៣៤៣ នៃក្រមរដ្ឋប្បវេណីដដែល ។

[15] មាត្រា ៣៤៤ នៃក្រមរដ្ឋប្បវេណីដដែរ។

[16] មាត្រា ៣៣៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី និង មាត្រា ៩ នៃច្បាប់ស្តីពីការអនុវត្តក្រម។

### ១.១.១.២. សមត្ថភាពភាគីនៃកិច្ចសន្យា

សមត្ថភាពភាគីសំដៅដល់លក្ខណៈសម្បត្តិរបស់ភាគីនៃកិច្ចសន្យា ឬ ក៏លទ្ធភាពក្នុងការចុះកិច្ចសន្យាដែលតម្រូវឱ្យមានដើម្បីអាចក្លាយជាម្ចាស់សិទ្ធិ និង កាតព្វកិច្ចហើយអាចយល់ដឹងអាចវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួននឹងដែលអាចធ្វើឱ្យសកម្មភាពរបស់ខ្លួនមានអានុភាពតាមផ្លូវច្បាប់។[17] តាមន័យនេះការសម្តែងឆន្ទៈដែលកើតចេញពីជនមានសមត្ថភាពក្នុងការធ្វើកិច្ចសន្យាគឺជាលក្ខខណ្ឌចាំបាច់មួយសម្រាប់ធ្វើឱ្យកិច្ចសន្យាមានសុពលភាពនឹងមិនអាចលុបកិច្ចសន្យានោះចោលបាន។ ក្នុងករណីបើកិច្ចសន្យាដែលពិនិត្យឃើញថាភាគីណាម្ខាងដែលគ្មានសមត្ថភាពគ្រប់គ្រាន់ ហើយត្រូវបានព្រមព្រៀងក្នុងការបង្កើតកិច្ចសន្យានោះកិច្ចសន្យានឹងចាត់ទុកថាគ្មានសុពលភាព។ ការចែងបែបនេះគឺក្នុងគោលបំណងដើម្បីការពារកុំឱ្យមានការខូចប្រយោជន៍ដល់កិច្ចការជំនួញរបស់ជនទាំងឡាយដែលបណ្តាលមកពីកង្វះសមត្ថភាពក្នុងការបង្កើតកិច្ចសន្យា ។

ដូច្នេះលក្ខខណ្ឌទូទៅទាក់ទងនឹងសមត្ថភាពភាគីដែលចែងក្នុងក្រមរដ្ឋប្បវេណីមាន០៣(បី)យ៉ាងគឺៈ សមត្ថភាពទទួលសិទ្ធិ សមត្ថភាពខាងឆន្ទៈ និង សមត្ថភាពក្នុងការធ្វើសកម្មភាព។ សមត្ថភាពទាំងនេះបានកំណត់អំពីភាគីនៃកិច្ចសន្យា ថាស្ថិតក្នុងលក្ខខណ្ឌបែបណាដែលអាចមាន ឬ គ្មានសិទ្ធិ ក្នុងការបង្កើតកិច្ចសន្យាឱ្យមានសុពលភាពបាន។

#### ក. សមត្ថភាពទទួលសិទ្ធិ

សមត្ថភាពទទួលសិទ្ធិ គឺភាគីនៅក្នុងការទទួលបាននូវសិទ្ធិ ដូចជាសិទ្ធិក្នុងបង្កើតកិច្ចសន្យា សិទ្ធិទទួលបានមរតក សិទ្ធិទាមទារសំណងការខូចខាតជាដើម ដែលកំណត់ក្នុងក្រមរដ្ឋប្បវេណីហើយទាមទារឱ្យមាននូវលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលអាចក្លាយជាម្ចាស់សិទ្ធិនិងកាតព្វកិច្ច។ វាជាសមត្ថភាពផ្នែកសិទ្ធិដែលរូបវន្តបុគ្គលម្នាក់ៗសុទ្ធតែទទួលបានដោយមិនអាចលើកលែងបាន។[18] ជាគោលការណ៍គ្រប់រូបវន្តបុគ្គលទាំងអស់មិនថាជនជាតិខ្មែរ ឬ ជនបរទេសអាចទទួលបាននូវសិទ្ធិបុគ្គលដូចគ្នា និង សុទ្ធតែមានសមត្ថភាពខាងអាស្រ័យផលពីសិទ្ធិរបស់ខ្លួនតាមការកំណត់របស់ច្បាប់។ រូបវន្តបុគ្គលម្នាក់ៗមានសមត្ថភាពទទួលសិទ្ធិនៅពេលចាប់កំណើត និង បាត់បងនូវសមត្ថភាពទទួលសិទ្ធិនោះនៅពេលមរណភាព។[19]

[17] សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ចំណុចលេខ ១៤៦ ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យ ច្បាប់ និង បោះផ្សាយ ដោយ ទីស្តីការគណៈរដ្ឋមន្ត្រី នៅឆ្នាំ២០០៧ ។

[18] មាត្រា ៦ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

[19] មាត្រា ៨ និង មាត្រា ៦ នៃក្រមរដ្ឋប្បវេណីដដែល ។

**ខ. សមត្ថភាពក្នុងការបង្ហាញឆន្ទៈ**

សមត្ថភាពខាងឆន្ទៈសំដៅលើភាគីដែលមានសមត្ថភាពអាចយល់ដឹង និង វិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនបើមិនដូច្នោះទេសកម្មភាពនោះអាចនឹងត្រូវលុបចោលបាន។ មានន័យថានៅក្នុងការបង្កើតកិច្ចសន្យា ភាគីនៃកិច្ចសន្យាត្រូវមានសមត្ថភាពពេញលេញក្នុងការបង្ហាញឆន្ទៈរបស់ខ្លួន គឺមិនមែនជាសមត្ថភាពរបស់ភាគីដែលស្ថិតក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធភាពតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនទេ។[20] ហើយសកម្មភាពដែលចាត់ទុកថាមិនអាចវិនិច្ឆ័យតាមផ្លូវច្បាប់បានសំដៅដល់សកម្មភាពណាដែលស្ថិតក្នុងស្ថានភាពថមថយយ៉ាងខ្លាំង ដូចជាស្ថានភាពស្រវឹង ការប្រើប្រាស់សារធាតុញៀន ឬការប្រប្រាស់ថ្នាំដែលប៉ះពាល់ដល់សតិជាដើម គឺអាចលុបចោលកិច្ចសន្យានោះបាន។ ក្នុងករណីដែលភាគីណាម្ខាងគ្មានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ ហើយមិនអាចលុបចោលបានដោយសារចាត់ទុកថាគឺជាការព្រមព្រៀងពិតប្រាកដរវាងគូភាគីដែលធ្វើឱ្យកិច្ចសន្យាមានសុពលភាពនោះវានឹងធ្វើឱ្យភាគីខ្វះសមត្ថភាពខាងឆន្ទៈកើតមាននូវហានិភ័យ។ ដូច្នេះបញ្ញត្តិច្បាប់ដែលបានចែងក្នុងក្រមរដ្ឋប្បវេណីអំពីសមត្ថភាពខាងឆន្ទៈគឺដើម្បីការពារជនដែលកង្វះសមត្ថភាពកុំឱ្យខាតបង់នូវផលប្រយោជន៍ ហើយសមត្ថភាពក្នុងការវិនិច្ឆ័យដោយកង្វះឆន្ទៈនេះត្រូវច្បាប់ចាត់ទុកថាជាការបង្ហាញឆន្ទៈមានវិការៈតាមផ្លូវច្បាប់ ។

**គ.សមត្ថភាពក្នុងការធ្វើសកម្មភាព**

សមត្ថភាពក្នុងការធ្វើសកម្មភាព គឺជាសម្បទាឬអំណាចដែលអនុញ្ញាតឱ្យបុគ្គលម្នាក់អាចអនុវត្តន៍ដោយខ្លួនឯងនូវសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួន។[21] ច្បាប់បានកម្រិតនូវការធ្វើសកម្មភាពមួយចំនួនដែលមិនអាចអនុញ្ញាតឱ្យបុគ្គលធ្វើសកម្មភាពដើម្បីជារនាំងការពារពីការខូតខាតជាយថាហេតុដែលកើតឡើងដោយសារជនដែលមានសមត្ថភាពពុំគ្រប់គ្រាន់ក្នុងការទទួលបាននូវសិទ្ធិធ្វើកិច្ចសន្យាលក់ទិញជាអចលនវត្ថុណាមួយ តួយ៉ាងដូចជាជនជនបរទេស ឬ ក៏ជាជនដែលច្បាប់បានសន្មត់ថាជាជនខ្វះសមត្ថភាពដោយសារកម្រិតនៃការវិនិច្ឆ័យរបស់ជននោះដែលវាអាចជាមូលហេតុធ្វើឱ្យកិច្ចសន្យានោះមានវិការៈជាដើម។

**គ.១. ជនបរទេស**

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៤៤ កថាខណ្ឌទី១ បានចែងថា មានតែរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានសញ្ជាតិខ្មែរទេទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។ ក្នុងន័យនេះច្បាប់មិនបានកំណត់អំពីសិទ្ធិទទួលបានក្នុងការទិញលក់អចលនវត្ថុដែលកម្មវត្ថុជាដីរបស់ជនបរទេសនៅកម្ពុជាបានឡើយ ដូចនេះជន

---

[20] តាមមាត្រា ១៤ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧ ។

[21] សៀវភៅនីតិកាតព្វកិច្ច រៀបរៀងដោយសាស្ត្រាចារ្យ មេធាវី ហេង បូរ៉ា ឆ្នាំសិក្សា២០២០-២០២១,ទំព័រទី៧៤ ។

បរទេសណាក៏ដោយក៏មិនអាចទិញដីនៅកម្ពុជាបានដែរ លុះត្រាតែទទួលបាននូវសញ្ជាតិខ្មែរដោយគោរពតាមលក្ខខណ្ឌនៃការទទួលបានសញ្ជាតិខ្មែរជាមុនសិន (បញ្ញត្តិក្នុងច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨) ទើបអាចទិញបាន ប៉ុន្តែក្នុងករណីដែលកម្មវត្ថុនៃអចលនវត្ថុនោះជាអាគារសហកម្មសិទ្ធិ គឺជនបរទេសមានសិទ្ធិទិញចាប់ពីជាន់ទី១ឡើងទៅ។ ជាន់ផ្ទាល់ដី និង ជាន់ក្រោមដីមិនត្រូវបានអនុញ្ញាតឱ្យជនបរទេសមានសិទ្ធិកម្មសិទ្ធិឡើយ។[22]

**ក.២.ជនដែលត្រូវបានកម្រិតសមត្ថភាព**

ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព សំដៅដល់រូបវន្តបុគ្គលទាំងឡាយណាដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យពីសកម្មភាពតាមផ្លូវច្បាប់របស់ខ្លួនបានដោយមូលហេតុ អាយុ សតិ និង បញ្ញាស្មារតីរបស់ជននោះ។ ពាក្យថាសកម្មភាពនៅទីនេះគឺសំដៅការបង្ហាញឆន្ទៈតាមរយៈកិច្ចសន្យាដែលបានធ្វើឡើងដោយជនមួយចំនួនទៀតត្រូវបានច្បាប់មិនទទួលស្គាល់ថាមានសុពលភាព ឬ តម្រូវឱ្យមានការយល់ព្រមដោយជនដែលមានផលប្រយោជន៍ផ្សេងទៀត ដើម្បីឱ្យមានសុពលភាពលើសកម្មភាពទាំងនោះជាអាទិ៍។ ជនដែលត្រូវបានកម្រិតសមត្ថភាពមាន០៣(បី)ប្រភេទគឺ អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ។[23]

**ចំពោះអនីតិជន៖** ជនទាំងឡាយណាដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំច្បាប់បានកំណត់ថាជាអនីតិជន។[24] នៅក្នុងការបង្កើតកិច្ចសន្យាលក់ទិញធម្មតាដែលបម្រើឱ្យជីវភាពរស់នៅ អនីតិជនមានសកម្មភាពច្រើនដែលអាចធ្វើដោយខ្លួនឯងបានដែលច្បាប់បានអនុញ្ញាតនូវសកម្មភាពទាំងនោះ។ ប៉ុន្តែចំពោះសកម្មភាពនៃការលក់ទិញមួយចំនួនដូចជាចលនវត្ថុដែលកម្មវត្ថុនោះមានតម្លៃថ្លៃ ឬ ជាអចលនវត្ថុតែម្តងគឺអនីតិជនគ្មានសិទ្ធិក្នុងការបង្កើតកិច្ចសន្យាលក់ទិញជាមួយបុគ្គលណាបានឡើយ។ ដូច្នេះរាល់កិច្ចសន្យាលក់ទិញទាំងឡាយដែលអនីតិជនបានបង្កើតឡើងគឺត្រូវទទួលស្គាល់និងជំនួយដោយអ្នកអាណាព្យាបាល ឬ ដោយអំណាចមេបា(ឪពុក ឬ ម្តាយ) ដែលមានសិទ្ធិ និង ករណីយកិច្ចបីបាច់រក្សារូបកាយរបស់កូនដែលជាអនីតិជន តែបើក្នុងករណីអនីតិជនគ្មានឪពុក ឬ ម្តាយ នោះទេគេត្រូវបង្កើតរបបអាណាព្យាបាលសម្រាប់អនីតិជនដើម្បីជ្រើសតាំងបុគ្គលណាម្នាក់ដើម្បីគ្រប់គ្រងអនីតិជនដែលមានសិទ្ធិ និង ករណីយកិច្ចដូចអ្នកមានអំណាចមេបាដែរ។ ប៉ុន្តែអនីតិជនគ្រប់

---

[22] មាត្រា ៦ នៃច្បាប់ស្តីពីការផ្តល់ សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអាគារ សហកម្មសិទ្ធិ ដល់ ជនបរទេសដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/០៥១០/០០៦ ចុះថ្ងៃទី២២ខែឧសភា ឆ្នាំ២០១០។

[23] មាត្រា ១៦ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧ ។

[24] មាត្រា ១៧ នៃក្រមរដ្ឋប្បវេណីដដែរ។

រូបមិនមែនសុទ្ធតែត្រូវបានកម្រិតសមត្ថភាពនោះទេ តួយ៉ាងដូចជាអនីតិជនដែលទទួលបានអត្តាធិនភាព គឺមិនត្រូវមានការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពឡើយ និង ត្រូវចាត់ទុកថាបានដល់វ័យនីតិភាព ។[25]

ជាគោលការណ៍សកម្មភាពដែលអនីតិជនបានធ្វើដោយគ្មានការយល់ព្រមពីឪពុកម្ដាយសកម្មភាពនោះនឹងត្រូវបានលុបចោលដោយឪពុកម្ដាយរបស់អនីតិជន។ ប៉ុន្តែសកម្មភាពខ្លះគឺមិនអាចលុបចោលបានទេដូចជាការទទួលយកប្រទានកម្ម ការចុះកិច្ចសន្យាដោយរួចផុតពីកាតព្វកិច្ច ការលក់ទិញរបស់ប្រើប្រាស់ប្រចាំថ្ងៃ ការចាត់ចែងទ្រព្យសម្បត្តិដោយមានការអនុញ្ញាតពីឪពុកម្ដាយ ការប្រកបអាជីវកម្មត្រឹមការអនុញ្ញាតរបស់ឪពុកម្ដាយ។

**ចំពោះជនក្រោមអាណាព្យាបាលទូទៅ៖** ជនដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យជាអចិន្ត្រៃយ៍ដោយសារខ្លួនមានបញ្ហាស្មារតីហើយមានអាយុចាប់ពី ១៥ (ដបប្រាំ)ឆ្នាំឡើងទៅនោះតុលាការអាចប្រកាសចាប់ផ្ដើមរបបអាណាព្យាបាលទូទៅតាមរយៈពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតក្នុង ៤ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ឬចៅសង្កាត់ ឬតំណាងអយ្យការ ហើយតុលាការជ្រើសតាំងអ្នកអាណាព្យាបាលដោយឆន្ទានុសិទ្ធិ។[26] ប៉ុន្តែដើម្បីកំណត់អំពីស្ថានភាពជានិរន្តរ៍ក្នុងការខ្វះសមត្ថភាពយល់ដឹង និង វិនិច្ឆ័យដែលអាចបញ្ជាក់បានថាជននោះពិតជាត្រូវការអាណាព្យាបាលទូទៅនោះតុលាការត្រូវពិនិត្យភស្តុតាងដែលចេញដោយវេជ្ជបណ្ឌិត និង ផ្ដល់ឱកាសឱ្យសាមីខ្លួនធ្វើសេចក្ដីថ្លែងការណ៍ និង ធ្វើការដើម្បីពិចារណា ។

ជាគោលការណ៍សកម្មភាពរបស់ជនក្រោមអាណាព្យាបាលទូទៅ អាចលុបចោលបានរាល់សកម្មភាពដែលកើតចេញពីជននៅក្រោមអាណាព្យាបាលទូទៅ ច្បាប់បានកំណត់ថាគ្មានសុពលភាពអាចលុបចោលបានទោះបីក្នុងទំហំមានការអនុញ្ញាតពីអាណាព្យាបាលទូទៅក៏ដោយលើកលែងតែសកម្មភាពទាក់ទង និង ជីវភាពរស់នៅប្រចាំថ្ងៃ[27]ដូចជាការទិញបាយ ម្ហូប របស់ប្រើប្រាស់ប្រចាំថ្ងៃជាដើម ។

**ចំពោះជននៅក្រោមហិតូបត្ថម្ភ៖** ក្នុងករណីបុគ្គលដែលមានសមត្ថភាពតិចតួចពេក ក្នុងការយល់ដឹង និង វិនិច្ឆ័យដោយសារបញ្ហាស្មារតីតុលាការអាចប្រកាសចាប់ផ្ដើមហិតូបត្ថម្ភតាមរយៈពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតក្នុង ៤ ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអាណាព្យាបាលទូទៅ មេឃុំ ឬចៅសង្កាត់ ឬតំណាងអយ្យការ ដែលតុលាការត្រូវជ្រើសតាំងហិតូបត្ថម្ភកៈដោយឆន្ទានុសិទ្ធិ(ចំណែកឯនីតិវិធីនៃការជ្រើសតាំងហិតូបត្ថម្ភកៈត្រូវអនុវត្តដូចការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ)។ ហិតូបត្ថម្ភកៈជាអ្នកមានតួ

---

[25] មាត្រា ២១ និងមាត្រា ២២ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ។

[26] មាត្រា ២៤ នៃក្រមរដ្ឋប្បវេណីដដែល ។

[27] មាត្រា ២៦ នៃក្រមរដ្ឋប្បវេណីដដែរ។

នាទីត្រួតពិនិត្យ និង ថែរក្សាជនស្ថិតក្រោមហិតូបត្ថម្ភ។ មុនពេលប្រកាសរបបនេះតុលាការត្រូវស្តាប់មតិយោបល់របស់វេជ្ជបណ្ឌិតនឹងផ្តល់ឱកាសឱ្យសាមីខ្លួនធ្វើសេចក្តីថ្លែងការណ៍ ដើម្បីពិចារណាថាសាមីខ្លួនពិតជាមានបញ្ហាផ្នែកស្មារតី និង មានការយល់ដឹងតិចតួចពិតប្រាកដមែន។[28]

ជាគោលការណ៍សកម្មភាពរបស់ជននៅក្រោមហិតូបត្ថម្ភដែលមិនមានការយល់ព្រមពីហិតូបត្ថម្ភកៈត្រូវមានការលុបចោលលុះត្រាតែសកម្មភាពនោះជាសកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ។ ប៉ុន្តែក្នុងករណីមានការយល់ព្រមពីហិតូបត្ថម្ភកៈសាមីខ្លួនអាចធ្វើសកម្មភាពដូចជា៖ ការទទួល ឬ ការប្រើប្រាស់ទុនការខ្ចីទ្រព្យ ឬ ការធានាការធ្វើសកម្មភាពដែលមានគោលបំណងទទួលបានឬធ្វើឱ្យបាត់បង់សិទ្ធិដែលទាក់ទងនឹងអចលវត្ថុ ឬ ទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀត ការធ្វើសកម្មភាពបណ្តឹងការធ្វើប្រទានកម្មឬធ្វើកិច្ចសន្យាស្រុះស្រួល ឬ កិច្ចសន្យាមជ្ឈត្តកម្ម ការទទួលស្គាល់នូវសន្តតិកម្ម ឬ ការបោះបង់ចោលនូវសន្តតិកម្ម ឬ ការបែងចែកមត៌កការប្រកែកមិនទទួលប្រទានកម្ម ឬអច្ច័យទាន ឬ ការយល់ព្រមទទួលនូវប្រទានកម្ម ឬ អច្ច័យទានដែលភ្ជាប់បន្ទុក ការសាងសង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬ ការជួសជុលធំ, ការធ្វើភតិសន្យា ដែលមានអំឡុងពេលលើសពី ៣ (បី) ឆ្នាំ ចំពោះដីធ្លីលើសពី ២ (ពីរ) ឆ្នាំ ចំពោះអាគារលើសពី ៦ (ប្រាំមួយ) ខែចំពោះអចលនវត្ថុ និង សកម្មភាពដែលតុលាការប្រកាសជាពិសេសថាចាំបាច់ត្រូវមានការយល់ព្រមពីហតូបត្ថម្ភកៈ ។[29]

**១.១.១.៣. កម្មវត្ថុនៃកិច្ចសន្យា**

ចំពោះការផ្តល់និយមន័យឱ្យកម្មវត្ថុនៃកិច្ចសន្យាគឺជាកម្មវត្ថុនៃកាតព្វកិច្ចដែលជាតាវកាលិក និង កម្មវត្ថុនៃតាវកាលិកជាវត្ថុដែលជាប់នឹងតាវកាលិកនោះ។ ប៉ុន្តែការផ្តល់និយមន័យមួយទៀតថាកម្មវត្ថុនៃកិច្ចសន្យាសំដៅទៅលើកាតព្វកិច្ចគតិយុត្តដែលស្វែងរក ដែលចង់បានដោយគូភាគី។[30] លើសពីនេះទៅទៀតសិទ្ធិប្រត្យក្សក៏អាចជាកម្មវត្ថុនៃការលក់បានដែរតាមរយៈការធ្វើលទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ។ ដូច្នេះកម្មវត្ថុនៃកិច្ចសន្យាជាទូទៅមិនថាជាវត្ថុ ឬ សិទ្ធិទាំងឡាយណាដែលទោះបីជាកើតមានឡើងនាពេលអនាគតក៏ដោយ ក៏អាចយកទៅធ្វើជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញបានដែរ លែងលែងតែវត្ថុ ឬ សិទ្ធិនោះមិនអាចក្នុងការធ្វើអនុប្បទាន ឬ ក៏ច្បាប់ហាមឃាត់មិនឱ្យធ្វើអានុប្បទាន។[31] ប៉ុន្តែចំពោះកម្មវត្ថុក្នុងកិច្ចសន្យាលក់ទិញអចលវត្ថុដាច់ខាតត្រូវតែជាកម្មវត្ថុដែលមានភាពជាក់លាក់ហើយកម្មវត្ថុនោះត្រូវមានខ្លឹមសារស្របច្បាប់ និង ត្រូវមានការកំណត់ថ្លៃលក់ទិញ

---

[28] មាត្រា ២៨ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧ ។

[29] មាត្រា ៣០ នៃក្រមរដ្ឋប្បវេណីដដែល ។

[30] សៀវភៅមេរៀន នីតិកិច្ចសន្យា ផ្នែកទី៣ កម្មវត្ថុជំពូកទី១ (បោះពុម្ពឆ្នាំ២០១៣ ដោយលោកសាស្ត្រាចារ្យ ជិន វណ្ណារ៉ា )។

[31] មាត្រា ៥២៧ នៃក្រមរដ្ឋប្បវេណីដដែរ។ ។

អចលនវត្ថុឱ្យមានភាពច្បាស់លាស់ផងដែរ។

**ក.កម្មវត្ថុជាក់លាក់**

កម្មវត្ថុក្នុងកិច្ចសន្យាលក់ទិញត្រូវតែមានភាពជាក់លាក់តាមការសន្យារវាងភាគីតាមរយៈសំណើនិងស្ទីការប៉ុន្តែក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យានោះជាតាវកាលិកផ្សេងៗ ដែលកើតចេញអំពីអំពើរបស់មនុស្សនោះភាគីនៃកិច្ចសន្យាត្រូវតែយល់ច្បាស់ពីអ្វីដែលខ្លួនបានសន្យា។

កម្មវត្ថុជាក់លាក់មានន័យថាកម្មវត្ថុត្រូវតែមាននៅពេលបច្ចុប្បន្ន។ ប្រសិនបើកម្មវត្ថុមិនមាននៅពេលចុះកិច្ចសន្យាដោយសារវត្ថុនោះបានបាត់បង់កិច្ចសន្យានឹងពុំមានសុពលភាពឡើយ។ សំដៅដល់ក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុភាគីអាចកំណត់កម្មវត្ថុ ដែលអាចកើតមាននាពេលអនាគតបានតាមរយៈលទ្ធភាពក្នុងការធ្វើលទ្ធកម្ម ឬ ភាគីមានភាពច្បាស់លាស់ថាកម្មវត្ថុនោះនឹងកើតមានឡើងយ៉ាងពិតប្រាកដ។ ហើយកម្មវត្ថុជាអចលនវត្ថុចំពោះការលក់ទិញនៅកម្ពុជាភាគច្រើនទៅមិនឆ្ងាយពីកម្មវត្ថុ ជាដី ជាផ្ទះ ឬ ជាប្រភេទអាគារសហាមម្មសិទ្ធិជាអាទិ៍ នោះទេ។

**ក.១.កម្មវត្ថុនៃអចលនវត្ថុជាដី**

ដើម្បីច្បាស់ថាកម្មវត្ថុនៃកិច្ចសន្យាជាដីទោះបីជាដីទំនេរ ឬ ដីមានសំណង់ក្ដីត្រូវបញ្ជាក់ពីភាពស្របច្បាប់ហើយអាចលក់ទិញបានដោយមិនមានបញ្ហា ឬ វិវាទផ្លូវច្បាប់ណាមួយនោះទេភាគីម្ខាងទៀតនៃកិច្ចសន្យាចាំបាច់ត្រូវមានការស្រាវជ្រាវពីអត្តសញ្ញាណរបស់ម្ចាស់អចលនវត្ថុដែលលក់បន្តនោះអំពីកម្មសិទ្ធិករ ឬ អ្នកកាន់កាប់ថាតើគាត់ពិតជាម្ចាស់ពិតប្រាកដនិងជាម្ចាស់ស្របច្បាប់ដែរឬទេ? និងត្រូវសិក្សាពីប្រវត្តិនៃការកាន់កាប់ តាំងពីម្ចាស់ដើមដំបូងរហូតដល់ម្ចាស់ដែលលក់បន្តនេះ។ សម្រាប់ឯកសារកាន់កាប់អចលនទ្រព្យនោះ ឬ ឯកសារបញ្ជាក់ពីកម្មសិទ្ធិស្របច្បាប់នៃអចលនទ្រព្យដែលលក់បន្តនោះមានដូចជាប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬ ឯកសារប្លង់ទន់ មានដូចជា លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និង ផ្ទះសម្បែងជាអាទិ៍ ព្រមទាំងឯកសារទិញលក់ និង ឯកសារផ្ទេរសិទ្ធិផ្សេងៗដែលអ្នកលក់បន្តបានទិញពីម្ចាស់អចលនទ្រព្យដើម ឬ ម្ចាស់គម្រោងណាមួយបូករួមនឹងឯកសារបញ្ជាក់ពីការបង់ពន្ធអចលនវត្ថុ (ពន្ធប្រថាប់ត្រា ឬពន្ធលើការផ្ទេរសិទ្ធិអចលនទ្រព្យ) ពីម្ចាស់ដើមមកអ្នកលក់បន្តនេះ។ ឧទាហរណ៍៖ ការលក់ទិញដីដែលជាដីទំនេរហើយកាន់កាប់ដោយភោគៈ ដែលដីនោះទទួលបានរបបតាមរយៈដែលរដ្ឋចែកឱ្យដែលបច្ចុប្បន្នដីនោះកំពុងអាស្រ័យផល។ដូច្នេះដីដែលមានដំណាំអាស្រ័យផងត្រូវចាត់ទុកថាជាកម្មវត្ថុជាក់លាក់។

**ក.២.កម្មវត្ថុនៃអចលនវត្ថុជាផ្ទះឬអាគារសហកម្មសិទ្ធិ**

ចំពោះការលក់ទិញផ្ទះមានលក្ខណៈងាយស្រួលជាងការលក់ទិញដីដោយសារងាយមានការដឹងច្បាស់

ពីប្រភពនៃផ្ទះនោះដោយបញ្ជាក់ពីអាជ្ញាធរឃុំ សង្កាត់។ អាគារសហកម្មសិទ្ធិគឺសំដៅដល់អាគារ ឬ សំណង់ដែលមានកម្មសិទ្ធិករច្រើននាក់រស់នៅ ប៉ុន្តែមានចំណែកខ្លះជាកម្មសិទ្ធិផ្តាច់មុខរបស់សហកម្មសិទ្ធិករនីមួយៗហៅថា «ចំណែកឯកជន» និង មានចំណែកខ្លះដែលជាលំហរួមសម្រាប់ការប្រើប្រាស់រួមរបស់សហកម្មសិទ្ធិករទាំងអស់នោះហៅថា«ចំណែករួម»។[32] ប្រភេទនៃអាគារសហកម្មសិទ្ធិទាំងនោះមានដូចជា ផ្ទះល្វែងដែលមានច្រើនល្វែង និង ច្រើនជាន់ជាប់គ្នា ខុនដូ ប្រភេទផ្ទះផ្សេងទៀត ដែលមានរចនាសម្ព័ន្ធជាប់គ្នា។ សហកម្មសិទ្ធិករនីមួយៗមានសិទ្ធិពេញលេញក្នុងការចាត់ចែងលើចំណែកឯកជនរបស់ខ្លួនដូចជា ការលក់ការដូរ ការជួលប្រទានកម្ម បន្តមរតក ការជួលអចិន្ត្រៃយ៍ បង្កើតជាផលុបភោគ រៀបចំសិទ្ធិប្រើប្រាស់អាស្រ័យនៅ ដាក់ហ៊ីប៉ូតែក (ដាក់ជាទ្រព្យធានា) និងដាក់បញ្ចាំ ប៉ុន្តែមិនអាចបង្កើតជាសេវភាព[33] បាននោះទេ និង ត្រូវហាមឃាត់ជាដាច់ខាតនូវការរំខាន ឬ រាំងស្ទះដល់ការប្រើប្រាស់ចំណែករួមរបស់សហកម្មសិទ្ធិករផ្សេងទៀត។ ឧទាហរណ៍៖ លោក **ក** បានយល់ព្រមចុះកិច្ចសន្យាលក់ផ្ទះដែលខ្លួនកំពុងរស់នៅឱ្យទៅលោក **ខ**។ ដូច្នេះផ្ទះដែលលោក **ក** លក់ជាកម្មវត្ថុជាក់លាក់ដោយសារផ្ទះនោះលោក **ខ** បានមើលឃើញក្នុងពេលបច្ចុប្បន្នដោយផ្ទាល់ភ្នែក។ ហើយនៅពេលលោក **ខ** ព្រមទិញ នោះលោក **ក** ត្រូវបញ្ជាក់ពីខាងអាជ្ញាធរមានសមត្ថកិច្ចហើយប្រគល់សោរព្រមជាមួយការផ្ទេរកម្មសិទ្ធិនោះឱ្យ **ខ** ជាការបញ្ចប់នៃកិច្ចសន្យា។

**ខ.កម្មវត្ថុស្របច្បាប់**

ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ មាត្រា៣៥៤ បានចែងយ៉ាងច្បាស់ចំពោះលក្ខណៈទូទៅអំពីអត្ថន័យនៅក្នុងខ្លឹមសារនៃកិច្ចសន្យាថាទោះបីជាកិច្ចសន្យានោះមានការបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយ ក៏ត្រូវបានចាត់ទុកជាមោឃៈក្នុងករណីដែលអត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំណាមួយ ហើយអត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ផ្ទុយទំនៀមទម្លាប់ល្អរបស់សង្គម។

**ខ.១.កម្មវត្ថុមិនផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ**

កម្មវត្ថុមិនផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំសំដៅទៅលើអត្ថន័យនៃកិច្ចសន្យាដែលបង្កើតឡើងដោយមិនអាចមានភាពផ្ទុយពីបញ្ញត្តិអនុវត្តដោយបង្ខំបែបណាមួយ។ បញ្ញត្តិដែលអនុវត្តដោយបង្ខំគឺជាបញ្ញត្តិទាំងឡាយណាដែលច្បាប់តម្រូវឱ្យអនុវត្តដាច់ខាត បើមិនដូច្នេះទេច្បាប់មិនមានការទទួលស្គាល់នូវអានុភាពគតិយុត្តនៃកិច្ច

[32] មាត្រា ៤ នៃច្បាប់ស្តីពីការផ្តល់ សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអាគារ សហកម្មសិទ្ធិ ដល់ ជនបរទេសដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/០៥១០/០០៦ ចុះថ្ងៃទី២២ខែឧសភា ឆ្នាំ២០១០។

[33] សេវភាព គឺជាបន្ទុកដែលផ្ទុកលើអចលនវត្ថុមួយប្រយោជន៍ដល់អចលនវត្ថុមួយទៀត (ដីប្រើ ឬដីលើ) ដែលជារបស់កម្មសិទ្ធិករផ្សេងទៀត។ ឧទាហរណ៍ ស្រែក្រោម មានសេវភាពខាងទទួលទឹកពីស្រែលើ។ស្រែក្រោម ហៅថា ស្រែបំរើ ហើយស្រែលើ ហៅថាស្រែប្រើ។ (ដកស្រង់ចេញពីសទ្ទានុក្រមនៃច្បាប់ភូមិបាល ឆ្នាំ២០០១ )។

សន្យា ឬ សម្មភាពនោះឡើយ។ នៅក្នុងន័យនេះប្រសិនបើកម្មវត្ថុនៃកិច្ចសន្យាលក់ទិញជាអចលនវត្ថុភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុដាច់ខាតត្រូវធ្វើលិខិតយថាភូតទើបកិច្ចសន្យានោះមានអានុភាព។[34]

### ខ.២. កម្មវត្ថុមិនផ្ទុយនឹងសណ្តាប់ធ្នាប់សារណៈ និង ទំនៀមទម្លាប់ល្អ

ការព្រមព្រៀងរវាងគូភាគីនៅក្នុងកិច្ចសន្យា គឺត្រូវបានកំណត់ទៅលើសេចក្តីនៃការព្រមព្រៀងនោះគឺដាច់ខាតត្រូវតែស្របតាមគោលបំណង និង ខ្លឹមសារនៃច្បាប់ ឬ ច្បាប់មិនបានហាមឃាតទើបកិច្ចសន្យានោះមិនចាត់ទុកជាមោឃៈ។ ដូច្នេះសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អក្នុងសង្គមសំដៅទៅលើសកម្មភាពទាំងឡាយណាដែលមិនប៉ះពាល់ដល់ផលប្រយោជន៍សង្គមហើយមិនប៉ះពាល់ដល់របៀបរៀបរយសង្គម។ ដូចជាការមិនកាន់កាប់ដីកម្មសិទ្ធិឯកជនរបស់រដ្ឋធ្វើជាកម្មសិទ្ធិរបស់ខ្លួននឹងដើម្បីជាផលប្រយោជន៍សម្រាប់ការធ្វើជំនួញជាដើម ។ ម្យ៉ាងទៀតការលួចបន្លំ ការឆបោក ការប្រើអំណាចដើម្បីទៅគាបសង្កត់លើជនទន់ខ្សោយដោយបង្ខំឱ្យលក់ដីមកឱ្យខ្លួនជាដើមដែលសកម្មភាពទាំងនេះនឹងត្រូវចាត់ទុកថាផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អក្នុងសង្គម ។

ជារួមមកក្នុងករណីដែលកិច្ចសន្យាត្រូវបានកើតឡើង នៅពេលអត្ថន័យនៃសកម្មភាពផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អឬផ្ទុយនឹងទម្រង់នៃបទដ្ឋានគតិយុត្តដែលបានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបានដែរ។[35] **មោឃភាពនៃកិច្ចសន្យា** ជាកិច្ចសន្យាដែលគ្មានសុពលភាពតាំងពីដើមដែលវាមិនមានអានុភាពតាមផ្លូវ ឬ មិនទទួលស្គាល់ដោយច្បាប់។ ឆន្ទៈមិនពិតក៏ត្រូវចាត់ទុកជាមោឃៈដែរហើយច្បាប់មិនបានកំណត់អាជ្ញាយុកាលនៃការប្តឹងពីមោឃភាពឡើយ។ ក្នុងករណីដែលកិច្ចសន្យានោះមានផ្នែកណាមួយដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អរបស់សង្គមមិនត្រូវចាត់ទុកថាមោឃភាពនៃកិច្ចសន្យាទាំងស្រុងនោះទេ។ មានន័យថាវាមោឃភាពមួយផ្នែកដើម្បីកុំឱ្យប៉ះផលប្រយោជន៍របស់ភាគីដែលមានក្នុងផ្នែកដទៃទៀតមានលក្ខណៈត្រឹមត្រូវស្របច្បាប់។

### គ.ថ្លៃលក់ទិញ

ថ្លៃលក់ទិញអចលនវត្ថុរួមនឹងលក្ខខណ្ឌទូទាត់ប្រាក់ថ្លៃលក់ទិញអចលនវត្ថុ គឺជាកត្តាសំខាន់មួយនៅ

[34] មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧ ។

[35] មាត្រា៣៥៧ នៃក្រមរដ្ឋប្បវេណីដដែល ។

ក្នុងកិច្ចសន្យាលក់ទិញ។ ជាទូទៅភាគីនៃកិច្ចសន្យាត្រូវបានកំណត់ចំនួនប្រាក់នៃថ្លៃលក់ទិញអចលនវត្ថុនោះគឺអាស្រ័យទៅតាមការចរចា និង ការព្រមព្រៀងរវាងគូភាគីនៃកិច្ចសន្យាយ៉ាងច្បាស់លាស់។[36] ចំនួនប្រាក់នៃថ្លៃលក់ទិញអាចត្រូវបានកំណត់ ដោយយោលទៅតាមតម្លៃ នៅទីផ្សារក្នុងពេលបច្ចុប្បន្ន ឬ អនាគត ឬ ដោយផ្អែកលើការវាយតម្លដែលធ្វើដោយតតិយជនដែលត្រូវបានជ្រើសរើសតាមរបៀបកំណត់ដោយគូភាគី ហើយការកំណត់ថ្លៃលក់ទិញនេះភាគីនៃកិច្ចសន្យាក៏អាចកំណត់ដោយបង្ហាញចំនួនថ្លៃដើមពិតប្រាកដ ឬ ឱ្យអ្នកទិញបង់ជាធនលាភដែលមិនកំណត់ពេល ឬ ធនលាភមួយជីវិតបាន។[37] ឧទាហរណ៍៖ អ្នកលក់ដីបានយល់ព្រមលក់ហើយអ្នកទិញដីបានយល់ព្រមទិញនៅក្នុងតម្លៃព្រមព្រៀង១ម៉ែត្រការ៉េ៥០ដុល្លារក្នុងទំហំ១ហិចតា ដែលមានតម្លៃសរុប៥០ម៉ឺនដុល្លារ ដោយសារមានការវាយតម្លៃទៅដីនោះទៅតាមតម្លៃទីផ្សារបច្ចុប្បន្នភាពដោយអ្នកជំនាញខាងអាជីវកម្មអភិវឌ្ឍន៍អចលនវត្ថុនៅកម្ពុជា។ អ្នកលក់បានឱ្យជម្រើសពីរទៅអ្នកទិញដោយអាចធ្វើការបង់ប្រាក់សរុបទាំងអស់ ឬ បង់ជាធនលាភក្នុងមួយឆ្នាំ៣ម៉ឺនដុល្លារគឺបង់រហូតដល់អស់ចំនួនទឹកប្រាក់ដែលបានព្រមព្រៀងលក់ទិញនោះ។ ជាទូទៅក្នុងករណីដែលការវាយតម្លៃរបស់តតិយជនត្រូវបានធ្វើឡើងដោយភាន់ច្រឡំ ឬ ករណីដែលការវាយតម្លៃនោះច្បាស់ជាផ្ទុយនឹងសមភាពភាគីនៃកិច្ចសន្យា ដែលទទួលការខូចខាតផលប្រយោជន៍របស់ខ្លួនដោយសារការវាយតម្លៃនោះ ហើយអាចតវ៉ាចំពោះការវាយតម្លៃនោះបាន ។

ការទិញលក់អចលនវត្ថុភាគច្រើននៅកម្ពុជាគឺទាមទារឱ្យមានប្រាក់កក់។ ដូច្នេះប្រាក់កក់ក៏ត្រូវតែកំណត់ឱ្យមានភាពច្បាស់លាស់ក្នុងកម្មវត្ថុនៃកិច្ចសន្យាផងដែលជៀសវាងនូវការភាន់ច្រឡំ។ ប្រាក់កក់នៅក្នុងកិច្ចសន្យាទិញលក់មិនមែនជាកាតព្វកិច្ចដែលត្រូវតែធ្វើទេក៏ប៉ុន្តែច្បាប់ក៏មិនបានហាមឃាត់ដែរ មានន័យថាវាអាស្រ័យទៅតាមការកំណត់របស់អ្នកទិញនិងអ្នកលក់។ ក្រមរដ្ឋប្បវេណីមានចែងអំពីរឿងប្រាក់កក់នេះគឺបើអ្នកទិញបានបង់ប្រាក់កក់ទៅឱ្យអ្នកលក់អ្នកទិញអាចរំលាយកិច្ចសន្យាជាមួយអ្នកលក់វិញដោយបោះបង់ប្រាក់កក់នេះចោល។ ចំពោះអ្នកលក់វិញក៏អាចរំលាយកិច្ចសន្យានេះបានដែរ តែត្រូវសងប្រាក់ស្មើនឹង២ដងនៃប្រាក់កក់នេះមកវិញ ។[38]

### ១.១.២. លក្ខខណ្ឌទម្រង់

លក្ខខណ្ឌទម្រង់ គឺជាលក្ខខណ្ឌដ៏សំខាន់ក្នុងការរួមចំណែកឱ្យការបង្កើតកិច្ចសន្យាមានសុពលភាពពេញលេញនិងអាចយកទៅអនុវត្តក៏ដូចជាការតតាំងបានជាមួយនឹងតតិយជន ឬ អាចនិយាយបានថាលក្ខខណ្ឌទម្រង់ជាលក្ខខណ្ឌសម្រាប់ការបង្កើតកិច្ចសន្យា ដែលភាគីនៃកិច្ចសន្យាជាអ្នកកំណត់តាមការ

---

[36] មាត្រា ៥២១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ។

[37] មាត្រា ៥២១ កថាខណ្ឌទី១,២ នៃក្រមរដ្ឋប្បវេណីដដែរ។

[38] មាត្រា ៥១៨ នៃក្រមរដ្ឋប្បវេណីដដែល ។

ព្រមព្រៀងគ្នា។[39] ដូច្នេះក្រោយពីមានការយល់ដឹងអំពីការបង្កើតកិច្ចសន្យាដែលទាមទារឱ្យមាននូវលក្ខខណ្ឌគ្រឹះ យើងត្រូវតែស្វែងយល់បន្តអំពីលក្ខខណ្ឌទម្រង់ដែលរួមមាន កិច្ចសន្យាដែលធ្វើជាកិច្ចសន្យាឯកជន ឬ លិខិតឯកជន(១.១.២.១) និង លិខិតយថាភូត(១.១.២.២) ។

**១.១.២.១.លិខិតឯកជន**

លក្ខណៈនៃលិខិតឯកជននៅក្នុងន័យនៃនីតិកិច្ចសន្យា ជាកិច្ចសន្យាឯកជនដែលធ្វើឡើងដោយគូភាគីក្នុងការព្រមព្រៀងគ្នាទៅលើការ ចុះកិច្ចសន្យាដែលការព្រមព្រៀងនេះបង្កើតឱ្យមានលក្ខណៈគតិយុត្តទៅតាមផ្លូវច្បាប់ព្រមទាំងមានការគាំពារដោយច្បាប់។ កិច្ចសន្យាធ្វើបែបនេះវាមិនមានអានុភាពឡើយចំពោះកិច្ចសន្យាលក់ទិញអចលនវត្ថុ។ ទោះបីជាលិខិតឯកជន គឺជាលិខិតដែលបានបង្កើតឡើងដោយបុគ្គលឯកជនដោយចុះហត្ថលេខាឬស្នាមមេដៃ[40] និងជាលិខិតដែលធ្វើឡើងដោយមេធាវីរបស់ភាគីណាម្ខាងនៃកិច្ចសន្យាក៏ដោយ ក៏កិច្ចសន្យានោះនៅតែជាលិខិតឯកជនដដែរ។ ក្នុងន័យនេះវាគឺជាកិច្ចសន្យាដែលធ្វើឡើងតែគ្នាឯងឥតមានមន្ត្រីរាជការសាធារណៈបានដឹងឮ និងឃើញទេគឺមានតែហត្ថលេខានៃគូភាគីតែប៉ុណ្ណោះ ។[41]

ការលក់ទិញអចលនវត្ថុតាមលិខិតឯកជន វាគ្មានភាពខុសច្បាប់ពិតមែនតែថាកិច្ចសន្យាទាំងនោះវាមិនត្រូវបានយកទៅតតាំងជាមួយតតិយជនបានឡើយ ហើយមិនត្រូវបានច្បាប់ការពារនិងទទួលស្គាល់ឡើយនៅពេលមានវិវាទកើតឡើង។ ដូច្នេះចំពោះកិច្ចសន្យាលក់ទិញអចលនវត្ថុគួរណាស់តែមានការព្រមព្រៀងគ្នាពីដំបូងក្នុងការធ្វើលិខិតយថាភូតដើម្បីជាប្រយោជន៍នៅពេលមានវិវាទកើតឡើង។

**១.១.២.២. លិខិតយថាភូត**

ការលក់ទិញដែលកម្មវត្ថុជាអចលនវត្ថុ គឺត្រូវធ្វើជាលិខិតយថាភូតទើបកិច្ចសន្យានោះអានុភាពត្រឹមត្រូវតាមទម្រង់ច្បាប់។[42] ការបង្កើតកិច្ចសន្យាលក់ទិញអចលនវត្ថុគឺមានគោលបំណងផ្ទេរកម្មសិទ្ធិទៅឱ្យបុគ្គលម្ខាងទៀត ហេតុនេះហើយការលក់ទិញអចលនវត្ថុការធ្វើកិច្ចសន្យាតាមទម្រង់ជាលិខិតយថាភូតដូចដែលបានកំណត់ក្នុងមាត្រា ៥១៦ (ការបង្កើតកិច្ចសន្យាលក់ទិញ) គឺជាការចាំបាច់ដោយសារតែវាមានអានុភាពចំពោះការចុះបញ្ជីផ្ទេរកម្មសិទ្ធិ។ ហើយការចុះបញ្ជីផ្ទេរកម្មសិទ្ធិមាននីតិវិធី (ដែលនឹងធ្វើការបកស្រាយលំអិតក្នុងជំពូកទី២ ផ្នែកទី២ ជាបន្ត)ដែលជាបញ្ហាស្មុគស្មាញមួយចំពោះការលក់ទិញអចលនវត្ថុ។

---

[39] មាត្រា ៥១៦ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧ ។

[40] សទ្ទានុក្រម ចំណុចលេខ ១៣២នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ។

[41] សៀវភៅ នីតិកិច្ចសន្យាពិសេស រៀបរៀងដោយ លោក យស បានចំរុង និងលោក ខាំ សុមករា ឆ្នាំ ២០១៣ ,ទំព័រទី១៥។

[42] មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណីដដែរ។

លិខិតយថាភូត គឺជាលិខិតដែលធ្វើឡើងតាមរូបមន្តច្បាប់ដោយមន្ត្រីសាធារណៈដែលត្រូវបានអនុញ្ញាតឱ្យប្រតិបត្តិមុខងារនោះ។[43] ការធ្វើលិខិតដោយមន្ត្រីសាធារណៈគឺជាលិខិតដែលធ្វើឡើងដោយសារការី ឬ លិខិតឯកជនដែលសារការីបានចុះនិទ្ទេសអំពីភាពត្រឹមត្រូវតាមច្បាប់ព្រមជាមួយការចុះកាលបរិច្ឆេទ និង ហត្ថលេខាក្រោយពេលខ្លួនបញ្ជាក់ថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់និងលិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីរៀបចំនៃនីតិវិធីនៃការចុះបញ្ជី។[44] ដូច្នេះហើយការធ្វើលិខិតយថាភូតក៏មិនអាចគ្មានវត្តមានរបស់អាជ្ញាធរមានសមត្ថកិច្ចឡើយ ដើម្បីធ្វើការបញ្ជាក់ទៅលើលិខិតក្នុងទម្រង់បែបណាមួយហើយត្រូវបានចុះបញ្ជីនៅអង្គភាពសុរិយោដី (មាត្រា៦៥ នៃច្បាប់ភូមបាលឆ្នាំ២០០១) ។

លិខិតយថាភូតដែលកិច្ចសន្យាលក់ទិញអចលនវត្ថុត្រូវបង្កើតឡើង តាមរយៈការបញ្ញត្តិរបស់ក្រមរដ្ឋប្បវេណី និង មានការកែសម្រួលដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ នៅមាត្រា៩ មាត្រា១១ គឺត្រូវធ្វើឡើងចំនួន០២(ពីរ)ទម្រង់រួមមាន៖ ទម្រង់លិខិតដែលធ្វើឡើងដោយសារការី និង លិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងសម្រាប់នីតិវិធីនៃការចុះបញ្ជី។

**ក. លិខិតដែលធ្វើឡើងដោយសារការី**

សារការីគឺជាមន្ត្រីសាធារណៈដែលត្រូវបានតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជាហើយទទួលបាននូវសិទ្ធិអំណាចក្នុងការតាក់តែងលិខិតយថាភូតធានាកាលបរិច្ឆេទ តម្កល់ រក្សាទុក និង ចេញសេចក្តីចម្លងយថាភូតនៃលិខិតទាំងឡាយដែលត្រូវតែឱ្យមានការបញ្ជាក់ [45] ហើយសារការីអនុវត្តមុខងាររបស់ខ្លួន ក្នុងក្របខណ្ឌវិជ្ជាជីវៈសេរីនៅក្នុងមន្ទីរសារការីរបស់ខ្លួន។ សារការីជាអ្នកវិជ្ជាជីវៈដែលមានជំនាញផ្នែកច្បាប់លើវិស័យអចលនវត្ថុ ការគ្រប់គ្រងទ្រព្យសម្បត្តិ សន្តតិកម្ម គ្រួសារ និងពាណិជ្ជកម្មជាអាទិ៍។ ដូច្នេះចំពោះកិច្ចសន្យាប្រភេទនេះ គឺត្រូវសរសេរឡើងដោយសារការីផ្ទាល់ ដោយភាគីនៃកិច្ចសន្យាត្រូវធ្វើដំណើរទៅមន្ទីរសាការី និង មានការបង់ថ្លៃសេវាទៅលើការប្រើប្រាស់សេវារបស់សារការី និងត្រូវតែបង់ពន្ធចូលទៅថវិការបស់រដ្ឋ។[46] ប៉ុន្តែគេកម្រឃើញមានខ្លាំងណាស់ ក្នុងប្រតិបត្តិការទិញលក់អចលនវត្ថុនៅកម្ពុជា ដោយសារវាមិនទាន់មានភាពទូលំទូលាយដូចបរទេសជាពិសេសប្រទេសបារាំងជាដើម។ ដោយឡែកប្រភេទលិខិតយថាភូតមួយប្រភេទទៀតតាមរយៈសារការី គឺដែលធ្វើឡើងដោយបុគ្គលឯកជន ហើយត្រូវយកទៅឱ្យសារការីធ្វើការបញ្ជាក់ដើម្បីទទួលបានភាពស្របច្បាប់ដោយ

[43] សទ្ទានុក្រម ចំណុចលេខ ១៣១ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧។

[44] មាត្រា ៩ កថាខណ្ឌទី១នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ។

[45] សទ្ទានុក្រម ចំណុចលេខ ១៥៤ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧។

[46] មាត្រា ១១ កថាខណ្ឌទី៣នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីដដែល ។

សារការីត្រូវចុះហត្ថលេខា ចុះកាលបរិច្ឆេទ និង បានចុះនិទ្ទេសអំពីការបញ្ជាក់លើលិខិតនោះ។

**ខ. លិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងសម្រាប់នីតិវិធីនៃការចុះបញ្ជី**

ប្រសិនបើភាគីមិនបានទៅធ្វើលិខិតយថាភូតនៅមន្ទីរសារការីដោយសារមិនចង់អស់សោហ៊ុយថ្លៃសារការីទេ ជាពិសេសការលក់ទិញអចលនវត្ថុក្នុងតម្លៃទាប ភាគីអាចព្រមព្រៀងគ្នាក្នុងការបង្កើតកិច្ចសន្យាតាមទម្រង់លិខិតយថាភូតបានដោយមន្ត្រីមានសមត្ថកិច្ចហើយដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជីផ្ទេរកម្មសិទ្ធិ ដែលវាមានអានុភាពដូចគ្នាទៅនឹងការធ្វើដោយសារការីដែរ។ សម្រាប់កម្ពុជាគឺជាការពេញនិយមក្នុងការជ្រើសទម្រង់នេះមកប្រើប្រាស់ដោយអ្នកទិញ និង អ្នកលក់ ព្រមទាំងតម្រូវឱ្យមានសាក្សី ម្នាក់១ផងនោះ ត្រូវផ្តិតមេដៃលើលិខិតលក់ដោយមានការដឹងឮពីអាជ្ញាធរមូលដ្ឋានថ្នាក់ ស្រុក /ខ័ណ្ឌ គឺតាមរយៈកិច្ចសន្យាធ្វើឡើងដោយមានប្រថាប់ត្រាឃុំ សង្កាត់ ឬក្រុង ស្រុក ខណ្ឌ ហើយកិច្ចសន្យានេះធ្វើឡើងដោយមានសរសេរឈ្មោះ អត្តសញ្ញាណដីដែលជាកម្មវត្ថុនៃការចុះបញ្ជីនិងចំណុចផ្សេងទៀតដែលសរសេរក្នុងទម្រង់ជាក់លាក់មួយ។ កិច្ចសន្យាតាមទម្រង់លិខិតយថាភូតបានដោយមន្ត្រីមានសមត្ថកិច្ច តួយ៉ាងដូចជារដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ឬ រដ្ឋបាលសូរយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលអចលនវត្ថុតាំងនៅ។ឧទាហរណ៍៖ នៅក្នុងកិច្ចសន្យាលក់ទិញដីគឺនៅពេលសំណើនិងស្វីការមានអានុភាពតាមរយៈការព្រមព្រៀងអំពីតម្លៃដីរួចមក ភាគីត្រូវទៅខាងសុរិយោដីដែលដីនោះតាំងនៅហើយធ្វើលិខិតលក់ផ្តាច់ ដើម្បីអាចផ្ទេរកម្មសិទ្ធិទៅភាគីម្ខាងទៀតបាន។ ហើយលិខិតលក់ផ្តាច់នេះ គឺជាលិខិតយថាភូតចំពោះកិច្ចសន្យាលក់ទិញអចលនវត្ថុ។

## ១.២. វិការៈនៃកិច្ចសន្យា

គ្រប់ការព្រមព្រៀងទាំងអស់មិនមែនសុទ្ធតែជាការបង្ហាញឆន្ទៈដោយពិតប្រាកដនោះទេក្នុងករណីខ្លះភាគីនៃកិច្ចសន្យាក៏បានបង្ហាញនូវវិការៈក្នុងការព្រមព្រៀងនោះផងដែរ។ វិការៈក្នុងការបង្ហាញឆន្ទៈនេះ វាជាការបង្ហាញឆន្ទៈដែលមានលក្ខណៈប្រែប្រួល និង ប្រាសចាកពីភាពប្រក្រតីរបស់ច្បាប់ដែលបណ្តាលឱ្យកិច្ចសន្យាអាចត្រូវបានភាគីណាម្ខាង ឬ គូភាគីមានសិទ្ធិលុបចោល និង អាចលុបចោលបានបើទោះបីជាកិច្ចសន្យានោះមានសុពលភាពហើយក៏ដោយ។ ដូច្នេះករណីដែលចាត់ទុកថាមានវិការៈក្នុងកិច្ចសន្យា (១.២.១) ដែលទាំងនេះវាជាមូលហេតុនាំឱ្យមានការលុបចោលកិច្ចសន្យា (១.២.២) ផងដែរ ។

### ១.២.១. ករណីដែលចាត់ទុកថាមានវិការៈក្នុងកិច្ចសន្យា

វិការៈក្នុងការបង្ហាញឆន្ទៈគឺវាកើតឡើងក្នុងរូបភាពមួយចំនួនដូចជា៖ ការភាន់ច្រឡំ (១.២.១.១) ការឆបោក(១.២.១.២)ព័ត៌មានមិនពិត(១.២.១.៣)ការរំលោភបំពានលើស្ថានភាព(១.២.១.៤)ការគម្រាមកំហែង(១.២.១.៥) អំពើកេងយកចំណេញហួសហេតុ (១.២.១.៦)ការបង្ហាញឆន្ទៈមិនពិត(១.២.១.៧)។

**១.២.១.១. ការភាន់ច្រឡំ**

ការភាន់ច្រឡំមានន័យថាជាករណីដែលកើតចេញពីសកម្មភាពរបស់អ្នកបង្ហាញឆន្ទៈនៅក្នុងការបង្ហាញឆន្ទៈដែលមានលក្ខណៈផ្ទុយ ឬ ខុសគ្នាពីឆន្ទៈពិតប្រាកដរបស់ខ្លួនដោយមិនបានដឹងជាមុនអំពីភាពខុសគ្នានេះ។ ការបង្ហាញឆន្ទៈរបស់បុគ្គលម្នាក់ៗជាទូទៅ ត្រូវឆ្លងកាត់ដំណាក់កាលនីមួយៗដូចជា៖ ទី១ ការកើតឡើងនៃចំណង ឬ មូលហេតុដែលជម្រុញឱ្យធ្វើអ្វីមួយ ទី២ ការសម្រេចចិត្តធ្វើសកម្មភាព ទី៣ ការសម្រេចចិត្តធ្វើការបង្ហាញឆន្ទៈនិងទី៤ គឺការធ្វើសកម្មភាពតាមការបង្ហាញឆន្ទៈ ។[47]

ជាធម្មតាការភាន់ច្រឡំអាចបណ្តាលមកពីការផ្តល់ព័តមាន ឬការពន្យល់របស់ភាគីដែលមានកាតព្វកិច្ចមានភាពមិនច្បាស់លាស់ និងការភាន់ច្រឡំនោះកើតចេញពីអ្នកដែលមានសកម្មភាពបង្ហាញផ្ទាល់ជាដើម។

ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ មាត្រា៣៤៦ បានកំណត់អំពីការភាន់ច្រឡំទៅតាមស្ថានភាពសំខាន់ៗចំនួន០៣(បី)ករណីដែលមាននៅក្នុងកិច្ចសន្យារួមមាន៖

**ការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា៖** កិច្ចសន្យាដែលបានបង្កើតឡើងហើយអាចលុបចោលបានប្រសិនបើកិច្ចសន្យានោះមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យាបានកើតឡើងព្រោះភាគីម្ខាងបានបង្ហាញឆន្ទៈនៅពេលចុះកិច្ចសន្យាដោយមិនបានដឹងអំពីការភាន់ច្រឡំហើយចំពោះភាគីម្ខាងទៀតបានដឹង ឬ អាចដឹងអំពីស្ថានភាពនៃការភាន់ច្រឡំនោះ។[48] ចំណុចសំខាន់ក្នុងកិច្ចសន្យាពុំមានមាត្រាច្បាប់ណាមួយបានកំណត់ច្បាស់លាស់នោះទេមានន័យថាការកំណត់ទៅលើចំណុចណាមួយដែលចាត់ទុកថាសំខាន់ ឬ មិនសំខាន់វាអាស្រ័យទៅលើការពិចារណានៃខ្លឹមសារកិច្ចសន្យានោះទេ[49] តែរួមមានកម្មវត្ថុនៃកិច្ចសន្យាចាត់ទុកថាជាចំណុចសំខាន់ផងដែរ។

**ការភាន់ច្រឡំទៅលើចំណុចនៃកិច្ចសន្យាដែលភាគីយល់ឃើញថាសំខាន់៖** កិច្ចសន្យាដែលបានបង្កើតឡើងហើយអាចលុបចោលបានប្រសិនបើកិច្ចសន្យានោះមានការភាន់ច្រឡំទៅលើចំណុចនៃកិច្ចសន្យាដែលភាគីយល់ឃើញថាសំខាន់ឬចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យាខណៈដែលភាគីម្ខាង

[47] សៀវភៅក្រមរដ្ឋប្បវេណីភាគទី២ ជំពូក៣ ផ្នែកទី៤ កថាភាគទី២របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)បោះពុម្ពលើកទី១ ក្នុងខែ មីនា ឆ្នាំ ២០១២,ទំព័រ៥៦ ។

[48] មាត្រា ៣៤៦ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ។

[49] សៀវភៅក្រមរដ្ឋប្បវេណីភាគទី២ ជំពូក៣ ផ្នែកទី៤ កថាភាគទី២របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)បោះពុម្ពលើកទី១ ក្នុងខែ មីនា ឆ្នាំ ២០១២,ទំព័រ៥៧ ។

ទៀតបានស្ថិតក្នុងស្ថានភាពដែលអាចដឹងបានអំពីការភាន់ច្រឡំនេះ និងការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈ ។[50] ការភាន់ច្រឡំនៅទីនេះវាមិនសំដៅទៅដល់កម្មវត្ថុចម្បងនោះទេវាអាចជាការពាក់ព័ន្ធទៅនឹងផ្នែកណាមួយនៃកិច្ចសន្យាដែលអ្នកបង្ហាញឆន្ទៈគិតថាសំខាន់សម្រាប់ខ្លួន ។

**ការភាន់ច្រឡំដោយភាគីទាំងសងខាង៖** នៅក្នុងករណីការភាន់ច្រឡំដោយភាគីទាំងសងខាងអ្នកបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបានទោះបីជាភាគីម្ខាងទៀត មិនបានដឹងអំពីការភាន់ច្រឡំនេះក៏ដោយ។ នៅក្នុងករណីនេះគូភាគីទាំងសងខាងមានការភាន់ច្រឡំ ដូច្នេះភាពចាំបាច់នៅក្នុងការការពារភាគីម្ខាងទៀត គឺមានកម្រិតទាបដែលខុសពីករណីដែលមានតែភាគីម្ខាងមានការភាន់ច្រឡំ។[51] ករណីនេះវាមិនមានភាពចាំបាច់ក្នុងការពិចារណាទៅលើលទ្ធភាពក្នុងការដឹងរបស់ភាគីម្ខាងទៀតទេ។ ការការពារតតិយជនដោយសារការភាន់ច្រឡំ គឺការលុបចោលកិច្ចសន្យាមិនមែនត្រឹមតែអះអាងទៅលើគូភាគីប៉ុណ្ណោះទេ តែក៏អាចធ្វើការអះអាងទៅលើតតិយជនបានផងដែរ ក៏ប៉ុន្តែការលុបចោលកិច្ចសន្យាដោយការភាន់ច្រឡំមិនអាចអះអាងចំពោះតតិយជនបានឡើយប្រសិនបើតតិយជននោះសុចរិត និង គ្មានកំហុស។

**១.២.១.២. ការឆបោក**

ការបង្ហាញឆន្ទៈដោយការឆបោក សំដៅដល់សកម្មភាពបុគ្គលណាម្នាក់ ឬ អាចជាសកម្មភាពរបស់តតិយជនដែលស្តែងចេញមកខាងក្រៅ ដើម្បីធ្វើឱ្យអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំតាមរយៈ ការបង្ហាញឆន្ទៈមិនពិតប្រាកដ និង មិនត្រូវគ្នានឹងឆន្ទៈដែលមានដោយមធ្យោបាយឆបោកហើយអ្នកបង្ហាញឆន្ទៈមិនបានដឹងជាមុនអំពីភាពខុសគ្នានេះនៅពេលដែលគាត់បានបង្ហាញឆន្ទៈ ។

អំពើឆបោកដែលបានបញ្ញត្តិក្នុងនៅមាត្រា ៣៤៧ នៃក្រមរដ្ឋប្បវេណី និងអំពើឆបោកដែលបានបញ្ញត្តិនៅក្នុងមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌគឺមិនដូចគ្នាទេ។ ការឆបោកក្នុងរឿងព្រហ្មទណ្ឌក្នុងករណីខ្លះអាចត្រូវចូលទៅក្នុងការឆបោកលើរឿងរដ្ឋប្បវេណីដែរ តែការឆបោកក្នុងរឿងរដ្ឋប្បវេណីវាមិនអាចមានការឆបោករឿងព្រហ្មទណ្ឌក្នុងនោះទេ តែមានការឆបោករឿងព្រហ្មទណ្ឌតែមួយ។ អំពើដែលចាត់ទុកថាជាការឆបោកក្នុងរឿងរដ្ឋប្បវេណីបានលុះត្រាតែអំពើនោះមាននូវលក្ខខណ្ឌចំនួន០៤(បួន)រួមមាន[52]៖

[50] មាត្រា ៣៤៦ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ។

[51] មាត្រា ៣៤៦ កថាខណ្ឌ៣ នៃក្រមរដ្ឋប្បវេណីដដែរ។

[52] ក្រមរដ្ឋប្បវេណីសៀវភៅភាគទី២ ជំពូក៣ ផ្នែកទី៤ កថាភាគទី២,ទំព័រ៦៣ ,៦៤ របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA)បោះពុម្ពលើកទី១ ក្នុងខែ មីនា ឆ្នាំ ២០១២

- ភាគីម្ខាងទៀត ឬ តតិយជនមានគោលបំណងឆបោក មានន័យថាភាគីម្ខាងទៀត ឬ តតិយជន បាន ដឹងអំពីសកម្មភាពរបស់ខ្លួនរួចហើយថាជាកម្មភាពឆបោកហើយធ្វើឱ្យភាគីម្ខាងទៀតមានការភាន់ច្រឡំ ដោយសារសកម្មភាពរបស់ខ្លួន។
- សកម្មភាពឆបោកនោះត្រូវបានទទួលស្គាល់ថាជាអំពើខុសច្បាប់ និង មិនអាចទទួលយកបានក្នុង សង្គមដោយសារការផ្តល់ព័ត៌មានមិនពិតទៅកាន់អ្នកដែលបានបង្ហាញឆន្ទៈ។
- អ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំដោយសារសកម្មភាពឆបោក អ្នកបង្ហាញឆន្ទៈត្រូវមានការភាន់ច្រឡំ ហើយកិច្ចសន្យាត្រូវមានវិការៈដែលបណ្តាលមកពីការឆបោក។ ជាទូទៅការឆបោកអាចមានករណី មួយចំនួនជាការធ្វើសកម្មភាពដោយសុចរិតទាក់ទងនឹងការឆបោកដែរប៉ុន្តែភាគច្រើនការឆបោក វាជា អំពើខុសច្បាប់ហើយសកម្មភាពឆបោកបែបណាក៏ដោយក៏ចាត់ទុកថាមានវិការៈនិងត្រូវបានលុបចោល។
- អ្នកបង្ហាញបានបង្ហាញឆន្ទៈដោយមានវិការៈ ដែលវិការៈនោះកើតចេញពីការឆបោកនេះជាទំនាក់ទំនង ហេតុ និង ផលក្នុងការឆបោកបើគ្មានការឆបោកក៏គ្មានវិការៈនៃកិច្ចសន្យាផងដែរ។

ការឆបោកដោយតតិយជនករណីអ្នកធ្វើសកម្មភាពឆបោក ជាតតិយជនក្រៅពីភាគីនៃកិច្ចសន្យាបើភាគីម្ខាងទៀតនៃកិច្ចសន្យាបានដឹងអំពីការឆបោក ឬ អាចដឹងអំពីការឆបោក នោះអ្នកបង្ហាញឆន្ទៈ (អ្នកដែលត្រូវបានគេឆបោក) អាចលុបចោលកិច្ចសន្យាបាន។[53] កិច្ចសន្យាដែលបានបង្កើតឡើងហើយអាចលុបចោលបាន ប្រសិនបើកិច្ចសន្យានោះមានការឆបោកដែលជាមូលហេតុវិការៈនៃកិច្ចសន្យា។ ហើយការលុបចោលអាចអះអាងចំពោះតតិយជនហើយក៏អាចការពារតតិយជនដោយការឆបោក(មាត្រា ៣៤៧-៣ នៃក្រមរដ្ឋប្បវេណី) ប្រសិនបើតតិយជននោះជាជនសុចរិត និង គ្មានកំហុស។

### ១.២.១.៣. ការគំរាមកំហែង

បុគ្គលដែលបានបង្ហាញឆន្ទៈរបស់ខ្លួនដោយសារការគំរាមគំហែងនោះ អាចលុបចោលកិច្ចសន្យាបាន ព្រោះការបង្ហាញឆន្ទៈមានការគំរាមគំហែងសំដៅទៅលើករណីដែលអ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈរបស់ខ្លួនផ្ទុយនឹងគោលបំណងរបស់ខ្លួនដែលបង្កឡើងនូវភាពភ័យខ្លាចពីភាគីម្ខាងទៀត ឬ តតិយជន។[54]

លក្ខខណ្ឌនៃការគំរាមកំហែងគឺមានដូចខាងក្រោម៖

---

[53] មេរៀនស្តីពី ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណីភាគ១ ដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ដំណាក់កាលទី ៤របស់ក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជានិងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន( JICA ) បោះពុម្ពលើកទី១ នៅរាជធានីភ្នំពេញ ឆ្នាំ ២០១៥

[54] មាត្រា ៣៥០ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧ ។

– ភាគីម្ខាងទៀត ឬតតិយជនមានគោលបំណងធ្វើឱ្យអ្នកបង្ហាញឆន្ទៈ ធ្វើការបង្ហាញឆន្ទៈរបស់ ខ្លួនដោយមានការភ័យខ្លាច

– សកម្មភាពបង្ខំត្រូវបានទទួលស្គាល់ថាខុសច្បាប់

– សកម្មភាពបង្ខំធ្វើឱ្យអ្នកបង្ហាញឆន្ទៈខ្លាចហើយអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈរបស់ខ្លួនដោយសារការភ័យខ្លាចនោះ។

ការការពារតតិយជនដោយការគំរាមកំហែងវាមិនមានបញ្ញត្តិច្បាប់ណាដើម្បីការពារតតិយជន ទោះបីជាតតិយជនបានបង្កើតទំនាក់ទំនងក្នុងកិច្ចសន្យាដោយផ្អែកលើកិច្ចសន្យាដែលអាចត្រូវបានគេលុបចោលនោះ។ អ្នកបង្ហាញឆន្ទៈអាចអះអាងពីអានុភាពនៃការលុបចោលចំពោះតតិយជនបានគ្រប់ពេល ទោះបីជាតតិយជននោះជាជនសុចរិតក៏ដោយ។ មូលហេតុដែលមិនមានបទបញ្ញត្តិសំរាប់ការពារតតិយជនទាក់នឹងការគំរាមកំហែងគឺថាអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈរបស់ខ្លួនដោយគ្មានការភាន់ច្រឡំ ដែលមានលក្ខណៈខុសគ្នាពីការភាន់ច្រឡំ ឬការឆបោក ដូច្នេះអ្នកបង្ហាញឆន្ទៈត្រូវបានគេការពារច្រើនជាងនៅក្នុងករណីនៃការឆបោក ឬការភាន់ច្រឡំ ។

**១.២.១.៤. ព័ត៌មានមិនពិត**

ព័ត៌មានមិនពិតសំដៅលើករណីដែលហេតុត្រូវបានលើកឡើងដោយភាគី ដែលជាមូលដ្ឋាននៅក្នុងការបង្កើតកិច្ចសន្យាគឺខុសពីការពិត ហើយអ្នកបង្ហាញឆន្ទៈបានដឹងថាហេតុនោះ មិនមែនជាការពិតនោះខ្លួន នឹងមិនបង្ហាញឆន្ទៈទេ។ នៅក្នុងករណីនៃព័ត៌មានមិនពិតគេតម្រូវឱ្យភាគីម្ខាងទៀតមិនបានដឹងថាហេតុដែលគាត់បានលើកឡើងនោះមិនមែនជាការពិត។[55] ប៉ុន្តែប្រសិនបើគាត់បានដឹងថាហេតុនោះខុសពីការពិត ត្រូវបានគេចាត់ទុកថាជាការឆបោក ។

លក្ខខណ្ឌនៃព័ត៌មានមិនពិតមានដូចខាងក្រោម៖

– ហេតុដែលភាគីម្ខាងបានលើកឡើងដែលជាមូលដ្ឋាននៅក្នុងការបង្កើតកិច្ចសន្យាគឺខុសពីការពិត

– អ្នកបង្ហាញឆន្ទៈបានដឹងថាហេតុនោះ មិនមែនជាការពិតខ្លួននឹងមិនបង្ហាញឆន្ទៈទេ

– ភាគីម្ខាងទៀតមិនបានដឹងថាហេរតុដែលខ្លួនបានបង្ហាញនោះ មិនមេនជាការពិត ។

បុគ្គលដែលបានបង្ហាញឆន្ទៈរបស់ខ្លួនដោយសារព័ត៌មានមិនពិត នោះអាចលុបចោលកិច្ចសន្យាបានដោយសារការបង្ហាញឆន្ទៈនោះមានវិការៈឬអាចទាមទារសំណងនៃការខូចខាតពីបុគ្គលដែលបានបង្ហាញការណ៍

[55] មាត្រា ៣៤៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ។

មិនពិតនោះ ករណីដែលបុគ្គលនោះមានកំហុស។ ហើយការលុបចោលអាចអះអាងចំពោះតតិយជនបាន ឬអាចការពារតតិយជនអំពីព័ត៌មានមិនពិតប្រសិនបើតតិយជននោះជាជនសុចរិតនិងគ្មានកំហុស។[56]

**១.២.១.៥. ការរំលោភបំពានលើស្ថានភាព**

ការរំលោភបំពានលើស្ថានភាពសំដៅលើករណីដែលភាគីបានធ្វើការចុះកិច្ចសន្យាដោយឆ្លៀតឱកាស ដែលភាគីម្ខាងទៀតកំពុងជួបប្រទះនូវការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ សង្គមឬបានប្រើមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀត ដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបតបានទេ។[57] ភាគីដែលបានរំលោភបំពានលើស្ថានភាពមិនត្រូវបានគេចាត់ទុកថាបានគំរាមគំហែងឡើយព្រោះគាត់មិនបានប្រើវិធានការបង្ខំ។ ក៏ប៉ុន្តែដើម្បីបង្កើតជាការរំលោភបំពានលើស្ថានភាពវាមានភាពចាំបាច់ដែលភាគីម្ខាងទៀតឆ្លៀតឱកាស នៃស្ថានភាពទន់ខ្សោយរបស់អ្នកបង្ហាញឆន្ទៈ។

លក្ខខណ្ឌនៃការរំលោភបំពានលើស្ថានភាពមានដូចខាងក្រោម៖

- អ្នកបង្ហាញឆន្ទៈស្ថិតនៅក្នុងស្ថានភាពដែលមានការលំបាកក្នុងការបដិសេធចំពោះការទាមទាររបស់ភាគីម្ខាងទៀតព្រោះភាគីម្ខាងទៀតបានប្រើអំណាចផ្នែកសេដ្ឋកិច្ច ឬ ឋានៈក្នុងសង្គមជាដើមដែលមានលក្ខណៈខ្ពស់ជាង
- ភាគីម្ខាងទៀតបានប្រើឋានៈរបស់ខ្លួនដើម្បីទទួលបានប្រយោជន៍មិនត្រឹមត្រូវ
- អ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈរបស់ខ្លួន ព្រោះគាត់មិនអាចបដិសេធការទាមទាររបស់ភាគី ម្ខាងទៀតដោយសារឋានៈរបស់ខ្លួនទាបជាង។

**១.២.១.៦. អំពើកេងយកចំណេញហួសហេតុ**

អំពើកេងចំណេញហួសហេតុសំដៅលើករណីដែលភាគីម្ខាង បានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ខ្លៅ ឬ ក៏ការខ្វះការពិសោធន៍ហើយបានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានេះ ភាគីម្ខាងទៀតនៃកិច្ចសន្យាអាចលុបចោលកិច្ចសន្យាបានដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។[58]

---

[56] មាត្រា៣៤៨ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ។

[57] មាត្រា ៣៤៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីដដែល ។

[58] មាត្រា ៣៥១ នៃក្រមរដ្ឋប្បវេណីដែល ។

លក្ខខណ្ឌនៃអំពើកេងចំណេញហួសហេតុមានដូចជា៖ អ្នកបង្ហាញឆន្ទៈស្ថិតក្នុងស្ថានភាពការលំបាកផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ខ្លៅ ឬ ការខ្វះការ ពិសោធន៍ ភាគីម្ខាងទៀត បានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ខ្លៅ ឬ ការខ្វះការពិសោធន៍ និង ភាគីម្ខាងទៀតបានកេងយកចំនេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យា ។

### **១.២.១.៧. ការបង្ហាញឆន្ទៈមិនពិត**

កិច្ចសន្យាត្រូវចាត់ទុកថាមោឃៈ នៅពេលណាដែលកិច្ចសន្យានោះមានការបង្ហាញឆន្ទៈមិនពិត។ ការបង្ហាញឆន្ទៈមិនពិតសំដៅទៅលើការបង្ហាញឆន្ទៈខុសពីការពិតដែលអ្នកបង្ហាញឆន្ទៈបានដឹងច្បាស់ហើយ ដែលធ្វើឡើងដោយមានការឃុបឃិតគ្នាជាមួយភាគីម្ខាងទៀត។[59] វិការៈនៃកិច្ចសន្យាផ្សេងៗអាចមានភាគីជាអ្នកបង្ហាញឆន្ទៈដោយផ្ទាល់ ឬ ភាគីម្ខាងទៀតជាអ្នកបង្ហាញឆន្ទៈមិនពិតឬមិនបានដឹងឬជាដើម ។តែក្នុងករណីដែលមានការបង្ហាញឆន្ទៈមិនពិត គឺសំដៅទៅលើភាគីទាំងសងខាងដែលពេលខ្លះអាចធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍របស់តតិយជន។ ជាទូទៅមោឃៈចំពោះកិច្ចសន្យាទូទៅមិនមានអានុភាពក្នុងការការពារតតិយជនបានទេតែមោឃៈនៅទីនេះគឺសំដៅដល់ការបង្ហាញឆន្ទៈមិនពិតដែលផ្សេងពីគេគឺមានអានុភាពក្នុងការការពារតតិយជនចំពោះជនសុចរិតនិងគ្មានកំហុសធ្ងន់ធ្ងរ។

ចំពោះវិការៈនៃកិច្ចសន្យាដោយសារឋបនីយផ្លូវចិត្តមិនមានការលុបចោលឬមោឃភាពនោះទេ ហើយក៏មិនអាចអះអាងចំពោះតតិយជនបានដែលព្រោះអ្នកបង្ហាញឆន្ទៈបានដឹងអំពីវិការៈនៃការបង្ហាញឆន្ទៈនោះ។ ឋបនីយផ្លូវចិត្ត គឺសំដៅដល់ការបង្ហាញឆន្ទៈដោយភាគី ដែលដឹងខ្លួនថា ខុសពីឆន្ទៈពិតរបស់ខ្លួន។[60] មានន័យថានៅពេលដែលអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈតាមការជាក់ស្តែងខុសពីឆន្ទៈពិតប្រាកដរបស់ខ្លួនទៅកាន់ភាគីម្ខាងទៀតបើទោះបីជាខ្លួនបានដឹងថាខុសហើយក៏ដោយ។ នៅក្នុងន័យនេះគឺចង់សំដៅទៅលើសុពលភាពដដែល នៃភាគីក្នុងកិច្ចសន្យាហើយប្រសិនបើភាគីម្ខាងទៀតបានដឹងថាជាឋបនីយផ្លូវចិត្តនោះនោះភាគីម្ខាងទៀតមានសិទ្ធិតវ៉ាដោយបដិសេធការអនុវត្តកិច្ចសន្យាប៉ុន្តែកិច្ចសន្យានៅមានអានុភាព ដូច្នេះក្នុងករណីនេះប្រសិនបើ ភាគីម្ខាងទៀតបានធ្វើលទ្ធកម្មទៅឱ្យតតិយជន នោះតតិយជនមានសិទ្ធិលើកិច្ចសន្យាដោយសារសុពលភាពនោះហើយអ្នកបង្ហាញឆន្ទៈមិនអាចអះអាងជាមួយតតិយជនបានឡើយ។

### **១.២.២..ការលុបចោលកិច្ចសន្យា**

កិច្ចសន្យាត្រូវបានធ្វើឡើងដោយមិនគោរពតាមវិធានខាងលើដែលច្បាប់បញ្ញត្តិនោះទេ កិច្ចសន្យានោះនឹងរងនូវការលុបចោល ។ យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់អំពីមូលហេតុនៃការលុបចោលកិច្ចសន្យា(១.២.២.១) និងបានកំណត់អំពីអ្នកមានសិទ្ធិលុបចោល(១.២.២.២)។

---

[59] មាត្រា ៣៥៣ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧ ។

[60] សទ្ធានុក្រមទី៤៧ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧។

### ១.២.២.១. មូលហេតុនៃការលុបចោលកិច្ចសន្យា

មូលហេតុនៃការលុបចោលកិច្ចសន្យាមាន ០២ (ពីរ)លក្ខខណ្ឌគឺ (១)ក្នុងករណីដែលកិច្ចសន្យាត្រូវបានបង្កើតឡើងដោយមានវិការៈក្នុងការបង្ហាញឆន្ទៈ និង (២)ក្នុងករណីដែលកិច្ចសន្យាត្រូវបានបង្កើតឡើងដោយអសមត្ថជន (ជនដែលគ្មានសមត្ថភាពខាងឆន្ទៈ ឬខ្វះសមត្ថភាពក្នុងការធ្វើសកម្មភាព) ។[61]

**ការលុបចោលកិច្ចសន្យាដោយមូលហេតុមានវិការៈក្នុងការបង្ហាញឆន្ទៈ៖** នៅក្នុងករណីដែលកិច្ចសន្យាត្រូវបានធ្វើឡើងដោយការបង្ហាញឆន្ទៈមានវិការៈ (ផ្នែកទី២ ចំណុច២.១ **វិការៈនៃការព្រមព្រៀង**) ភាគីនៃកិច្ចសន្យាអាចលុបចោលកិច្ចសន្យានោះបាន។

**ការលុបចោលកិច្ចសន្យាដែលធ្វើឡើងដោយអសមត្ថជន៖** ចំពោះកិច្ចសន្យាទាំងឡាយណាដែលត្រូវបានបង្កើតឡើងដោយជនដែលគ្មានសមត្ថភាពក្នុងការបង្ហាញឆន្ទៈអនីតិភាពឬជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ដូចជាអនីតិជនជនស្ថិតនៅក្រោមរបបអាណាព្យាបាលទូទៅនិងជនដែលស្ថិតក្នុងរបបហិតូបត្ថម្ភជាអាទិ៍។ នៅក្នុងករណីនេះ អ្នកដែលមានសិទ្ធិលុបចោល ឬផ្ដល់សច្ចានុមតិរួមមានដូចជា អ្នកមានអំណាចមេបា (ឪពុក ឬម្ដាយ) អ្នកអាណាព្យាបាល (សម្រាប់អនីតិជន ឬជនដែលស្ថិតនៅក្រោមរបបអាណាព្យាបាលទូទៅ) ឬហិតូបត្ថម្ភកៈជាអាទិ៍។

### ១.២.២.២. សិទ្ធិលុបចោលកិច្ចសន្យា

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានផ្ដល់សិទ្ធិដល់ភាគីម្ខាងទៀតដែលបានខូចខាតនូវផលប្រយោជន៍ពីការចុះកិច្ចសន្យាដោយមានវិការៈ ឬ កិច្ចសន្យាដែលបានធ្វើឡើងដោយអសមត្ថជនអាចធ្វើការលុបចោលកិច្ចសន្យានោះវិញបាន។ សមីខ្លួន ឬ អ្នកដែលបានចុះកិច្ចសន្យាអ្នកតំណាងដែលច្បាប់បានកំណត់ សន្តតិជនរបស់អ្នកដែលបង្ហាញឆន្ទៈ និង អ្នកដែលទទួលឋានៈនៃកិច្ចសន្យា។[62]

សកម្មភាពដែលអាចលុបចោលបាន មានសុពលភាពរហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោលលុបចោលសកម្មភាពនោះ ហើយក្រោយពេលលុបចោល សកម្មភាពនោះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង ក៏ប៉ុន្តែការលុបចោលត្រូវធ្វើឡើងតាមវិធីនៃការជូនដំណឹងទៅភាគីម្ខាងទៀតហើយនឹងមានអានុភាពគិតចាប់ពីពេលដែលដំណឹងនោះបានទៅដល់ភាគីម្ខាងទៀត កិច្ចសន្យានោះនឹងមានអានុភាពតាមផ្លូវគតិយុត្ត។[63]

---

[61] មាត្រា ៣៥៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ។

[62] មាត្រា ៣៥៩ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីដដែល ។

[63] មាត្រា ៣៣៦ កថាខណ្ឌ ២ នៃក្រមរដ្ឋប្បវេណី និង មាត្រា ៩ នៃច្បាប់ស្ដីពីការអនុវត្តក្រម។

ភាគីនៃកិច្ចសន្យា ឬ បុគ្គលដែលមានសិទ្ធិលុបចោលកិច្ចសន្យាត្រូវអនុវត្តសិទ្ធិនោះនៅក្នុងអំឡុងពេលដែលកំណត់ដោយច្បាប់បើមិនដូច្នេះទេនោះមិនអាចអះអាងអំពីសិទ្ធិនោះជាមួយភាគី ឬ តតិយជនបានឡើយ។ យោងតាមក្រមរដ្ឋប្បវេណី សិទ្ធិលុបចោលកិច្ចសន្យានឹងត្រូវរំលត់នៅក្នុងរយៈពេល ៣(បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលខ្លួនក្លាយទៅជាអ្នកដែលអាចផ្តល់សច្ចានុមតិ ក៏ប៉ុន្តែទោះបីជាយ៉ាងនេះក្តីបើផុតរយៈពេល ១០(ដប់) ឆ្នាំគិតចាប់ពីកាលបរិច្ឆេទធ្វើសកម្មភាពសិទ្ធិលុបចោលកិច្ចសន្យានេះក៏ត្រូវបានរំលត់ផងដែរ។[64]

ជារួមមកសម្រាប់ការលុបចោលមានភាពស្រដៀងគ្នាមោយភាពដែរ ប៉ុន្តែខុសពីនៅត្រង់ថាការលុបចោលជាកិច្ចសន្យាដែលមានសុពលភាពតាំងពីដំបូង តែអស់សុពលភាពនៅពេលដែលកិច្ចសន្យានោះមានការប្តឹងលុបចោល។ ក្នុងករណីនេះទៀតសោតមិនមែនជនណាក៏អាចលុបចោលបាននោះទេបើគ្មានច្បាប់ចែង។ដូច្នេះអ្នកដែលមានសិទ្ធិលុបចោលកិច្ចសន្យាបានរួមមាន៖ សមីខ្លួន ឬ អ្នកដែលបានចុះកិច្ចសន្យា អ្នកតំណាងដែលច្បាប់បានកំណត់ សន្តតិជនរបស់អ្នកដែលបង្ហាញឆន្ទៈ និងអ្នកដែលទទួលឋានៈនៃកិច្ចសន្យា។[65]

---

[64] អត្ថបទដកស្រង់របស់លោកមេធាវី សេង ឈុនលី និងលោក រ៉ាត់ ចាន់ធី ជាសមាជិកក្រុមការងាររៀបចំ និងផ្សព្វផ្សាយអត្ថបទច្បាប់នៃក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ ចេញផ្សាយថ្ងៃទី១ ខែ កុម្ភៈ ឆ្នាំ ២០២១។

[65] មាត្រា ៣៥៩ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧ ។

# ជំពូកទី២
# អានុភាពនៃកិច្ចសន្យាលក់ ទិញ
# អចលនវត្ថុ

# ជំពូកទី២

# អានុភាពនៃកិច្ចសន្យាលក់ ទិញអចលនវត្ថុ

អានុភាពគតិយុត្តនៃកិច្ចសន្យាលក់ទិញអចលនវត្ថុអាចកើតមានបាន លុះត្រាតែគូភាគីត្រូវបំពេញនូវសកម្មភាពក្នុងការប្រតិបត្តិការនៃលក់ទិញតាមរយៈសិទ្ធិ និងករណីយកិច្ចរៀងៗ ហើយការលក់ទិញអចលនវត្ថុអាចបន្តអានុភាពទៅបានលុះត្រាកិច្ចសន្យានោះអាចផ្ទេរសិទ្ធិកម្មសិទ្ធិពីភាគីម្ខាងទៅភាគីម្ខាងទៀត នៅពេលភាគីម្ខាងបានទទួលបន្តជាស្ថាពរនូវកម្មសិទ្ធិសម្រាប់ការកាន់កាប់ នោះនឹងឈានដល់ការបញ្ចប់កិច្ចសន្យាលក់ទិញអចលនវត្ថុ។ ដូច្នេះអានុភាពនៅក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុគឺសង្កត់ទៅលើសិទ្ធិនិងករណីយកិច្ចរបស់ភាគីនៃកិច្ចសន្យា (២.១) ការផ្ទេរកម្មសិទ្ធិតាមរយៈកិច្ចសន្យាលក់ទិញអចលនវត្ថុ (២.២) ហើយការរំលាយកិច្ចសន្យាលក់ទិញអចលនវត្ថុ (២.៣) ក៏ជាមូលហេតុដែលនាំឱ្យកិច្ចសន្យាត្រូវបានបញ្ចប់ដែរ ។

## ២.១. សិទ្ធិ និង ករណីយកិច្ចរបស់ភាគីនៃកិច្ចសន្យា

ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ បានកំណត់ទៅលើភាគីនៃកិច្ចសន្យាលក់ទិញ ដែលភាគីនោះអាចជារូបវន្តបុគ្គល ឬ នីតិបុគ្គលទាំងឡាយណាដែលអាចលក់ឬទិញបានលើកលែងតែក្នុងករណីដែលច្បាប់ហាមឃាត់។[66] ចំពោះកិច្ចសន្យាលក់ទិញអចលនវត្ថុវិញភាគីទាំងពីរដែលជារូបវន្តបុគ្គលឬនីតិបុគ្គលមានសិទ្ធិ និងករណីយកិច្ចដូចគ្នាគឺតម្រូវឱ្យភាគីទាំងសងខាងបំពេញឱ្យគ្នាទៅវិញទៅមក ក៏ប៉ុន្តែយើងអាចពិនិត្យឃើញថា ភាគីអ្នកលក់មានករណីយកិច្ចច្រើនជាងអ្នកទិញ និង ទាមទារឱ្យមានភាពច្បាស់លាស់ទៅកាន់ភាគីអ្នកទិញដែលនេះជាបញ្ហាស្មុគស្មាញដោយសារភាគីអ្នកលក់គឺជាម្ចាស់កម្មសិទ្ធិនៃអចលនវត្ថុ។ ដូច្នេះដើម្បីធានានូវភាពត្រឹមត្រូវនៃសិទ្ធិ និងករណីយកិច្ចរបស់ភាគីអ្នកលក់ ច្បាប់បានកំណត់ដូចតទៅៈ

### ២.១.១. សិទ្ធិរបស់ភាគីអ្នកលក់

អ្នកលក់គឺជាបុគ្គលដែលមិនត្រឹមតែមានសិទ្ធិលើកម្មសិទ្ធិរបស់ខ្លួនប៉ុណ្ណោះទេ រួមទាំងមានសិទ្ធិដែលពាក់ព័ន្ធនឹងជីវិត រូបកាយ សុខភាព សេរីភាព នាម កិត្តិយស ភាពឯកជន ឬ សិទ្ធិផ្សេងៗទៀតដែលជាផលប្រយោជន៍ទាក់ទងនឹងលក្ខណៈបុគ្គល។[67] នៅក្នុងន័យនេះច្បាប់បានផ្តល់ឱ្យសិទ្ធិមួយចំនួនទៅឱ្យភាគីអ្នកលក់ដូចជា សិទ្ធិទាមទារឱ្យប្រគល់ថ្លៃទិញអចលនវត្ថុ (២.១.១.១) សិទ្ធិជួសជុលរបស់អ្នកលក់ (២.១.១.២) សិទ្ធិតវ៉ារបស់អ្នកលក់ (២.១.១.៣) សិទ្ធិទទួលផលរបស់អ្នកលក់(២.១.១.៤) ។

---

[66] មាត្រា ៥២៤ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧ ។

[67] មាត្រា១១ នៃក្រមរដ្ឋប្បវេណីដដែល ។

### ២.១.១.១. សិទ្ធិទាមទារឱ្យប្រគល់ថ្លៃទិញអចលនវត្ថុ

គោលបំណងនៅក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុ គឺដើម្បីផលប្រយោជន៍រវាងគ្នានិងគ្នាដូចនេះផលប្រយោជន៍ដែលភាគីអ្នកលក់ទទួលនោះជាប្រាក់តាមការកំណត់តម្លៃនៃអចលនវត្ថុ ហើយអ្នកទិញទទួលផលប្រយោជន៍ជាអចលនវត្ថុដែលខ្លួនចង់បាននឹងយកទៅប្រើប្រាស់តាមតម្រូវការជាដើម។ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧បានបញ្ញត្តិថា កូនបំណុល (អ្នកទិញ)ត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនឱ្យស្របទៅតាមខ្លឹមសារនៃកិច្ចសន្យានិងគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់។[68] ដូច្នេះក្នុងករណីនេះបើភាគីអ្នកទិញមិនទាន់បង់ប្រាក់ទៅឱ្យអ្នកលក់ទេនោះ អ្នកលក់មានសិទ្ធិទាមទារប្រាក់ថ្លៃទិញនោះបាន។

ចំពោះការទាមទារថ្លៃទិញដោយផ្អែកលើចំនួនដីលើស បើទំហំនៃដីតាមការវាស់ជាក់ស្តែងលើសចំនួនតាមការបញ្ជាក់ទំហំដីនៅក្នុងកិច្ចសន្យារួមនឹងការកំណត់តម្លៃនៃថ្លៃលក់នេះ គឺមានការគណនាតាមក្បួនខ្នាតច្បាស់លាស់អ្នកលក់ក៏អាចទាមទារឱ្យអ្នកទិញបន្ថែមតម្លៃពីលើតម្លៃដែលកិច្ចសន្យាបានកំណត់ ករណីនេះអ្នកលក់ខ្លួនឯងគឺមិនបានដឹងអំពីការលើសទំហំនោះហើយគ្មានកំហុសក្នុងការមិនបានដឹងនោះ។[69] ផ្ទុយពីបញ្ញត្តិខាងលើអ្នកលក់ក៏មិនអាចទាមទារតម្លៃបន្ថែមពីអ្នកទិញបានឡើយ ក្នុងករណីដែលការព្រមព្រៀងលក់ទិញនោះត្រូវធ្វើឡើងដោយមានការបញ្ជាក់ទំហំនិងការកំណត់តែតម្លៃដីទាំងមូលដោយគ្មានការកំណត់តាមក្បួនខ្នាតទេ បើទោះបីជាអ្នកលក់ខ្លួនឯងផ្ទាល់មិនបានដឹងអំពីការលើសទំហំនេះហើយគ្មានកំហុសក្នុងការមិនបានដឹងនោះក៏ដោយ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយប្រសិនបើចំនួនលើសនោះច្រើនជាង ១ ភាគ២០ (មួយភាគម្ភៃ) ។[70]

### ២.១.១.២. សិទ្ធិជួសជុលរបស់អ្នកលក់

សិទ្ធិជួសជុលរបស់អ្នកលក់គឺមានន័យថា ក្នុងករណីដែលអ្នកលក់បានប្រគល់វត្ថុដែលមានវិការៈទៅអ្នកទិញមុនពេលកំណត់ប្រគល់ អ្នកលក់អាចប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការជួសជុលទៅលើវត្ថុដែលមានវិការៈនោះរហូតដល់ពេលកំណត់នោះ ហើយការជួសជុលនេះលុះត្រាតែមិនបណ្តាលឱ្យខូចខាតផលប្រយោជន៍ហួសហេតុទៅកាន់ភាគីអ្នកទិញ។ ប៉ុន្តែអ្នកទិញមិនត្រូវបានច្បាប់រារាំងក្នុងការអនុវត្តសិទ្ធិរំលាយនិងសិទ្ធិទាមទារសំណងនៃការខូចខាតឡើយ ប្រសិនបើអ្នកទិញយល់ឃើញថាការជួសជុលនោះនៅតែបាត់ផលប្រយោជន៍

[68] មាត្រា ៣៨៤ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧។

[69] មាត្រា៥៤៦ កថាខណ្ឌ៣ នៃក្រមរដ្ឋប្បវេណីដដែល ។

[70] មាត្រា៥៤៦ កថាខណ្ឌ៤ នៃក្រមរដ្ឋប្បវេណីដដែល ។

ខ្លួនដោយចាត់ទុកថាជាការបំពានកិច្ចសន្យាធ្ងន់ធ្ងរ និង ជាការអនុវត្តកាតព្វកិច្ចមិនបានពេញលេញទៅតាមកិច្ចសន្យាដែលបានកំណត់កាលបរិច្ឆេទនៃការប្រគល់ ។[71]

ឧទាហរណ៍៖ នៅក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុ ភាគីអ្នកលក់បានអះអាងថាអចលនវត្ថុដែលខ្លួនប្រគល់ ឬ ផ្ទេរសិទ្ធិឱ្យទៅអ្នកទិញមានសភាពល្អប្រសើរតែផ្ទុយពីក្នុងកិច្ចសន្យា តួយ៉ាងដូចជាផ្ទះដែលជាកម្មវត្ថុនៃការលក់ទិញនោះមានស្នាមប្រេះមានការជ្រាបទឹក ឬ ក៏បញ្ហាដីធ្លីដែលជាកម្មវត្ថុនៃការលក់ទិញនោះមានការពាក់ព័ន្ធនឹងតតិយជន ឬដីដែលមិនទទួលស្គាល់ដោយច្បាប់ដូចជាដីរដ្ឋជាដើម បញ្ហាទាំងអស់នេះភាគីអ្នកលក់អាចប្រើសិទ្ធិរបស់ខ្លួនក្នុងការជួសជុល និងកែតម្រូវការខូចខាតទៅលើវាដោយចំណាយសោហ៊ុយផ្ទាល់ខ្លួន ទោះបីវិការៈនោះកើតឡើងកំឡុងពេលមុន ឬក្រោយការប្រគល់នោះក៏ដោយ។

### ២.១.១.៣. សិទ្ធិតវ៉ារបស់អ្នកលក់

សិទ្ធិតវ៉ាជាសិទ្ធិសំខាន់នៅក្នុងការលក់ទិញដោយសារសិទ្ធិតវ៉ាអាចឱ្យគូភាគីបង្ហាញនូវភាពមិនសុខចិត្តក្នុងកិច្ចសន្យាដើម្បីស្វែងរកដំណោះស្រាយមួយដ៏ពិតប្រាកដ និង ដោយយុត្តិធម៌ដើម្បីធានានូវផលប្រយោជន៍របស់ភាគីទាំងសងខាង។ ដូច្នេះសិទ្ធិតវ៉ាដែលប្រគល់ឱ្យភាគីអ្នកលក់ដោយយោងតាមមាត្រា៥៥១ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ ត្រូវបានកម្រិតជាពីរគឺ សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា និង សិទ្ធិតវ៉ាដោយមានការបារម្ភ។

**ក. សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា**

នៅក្នុងកិច្ចសន្យាលក់ទិញការអនុវត្តព្រមគ្នា គឺសំដៅទៅលើការអនុវត្តនូវសិទ្ធិនិងកាតព្វកិច្ចក្នុងពេលតែមួយដោយគ្មានភាពយឺតយ៉ាវមានន័យថា អ្នកលក់មានសិទ្ធិប្រកែកមិនព្រមផ្ទេរកម្មសិទ្ធិលើអចលនវត្ថុរបស់ខ្លួនទៅឱ្យភាគីអ្នកទិញបានដរាបណាអ្នកទិញមិនទាន់ប្រគល់ថ្លៃលក់មកឱ្យខ្លួន។ ប៉ុន្តែក្នុងករណីនេះអ្នកលក់មិនអាចមិនអនុវត្តសិទ្ធិរបស់ខ្លួនបានទេកាលបើភាគីអ្នកទិញមិនទាន់ដល់កាលបរិច្ឆេទត្រូវបំពេញកាតព្វកិច្ច ឬ ក្នុងករណីដែលមានការព្រមព្រៀងថាមានការប្រគល់ឬផ្ទេរសិទ្ធិមុនពេលបង់ថ្លៃបាន។[72]

**ខ. សិទ្ធិតវ៉ាដោយមានការបារម្ភ**

ចំពោះសិទ្ធិតវ៉ាដោយមានការបារម្ភនេះវិញមានភាពខុសប្លែកគ្នាពីសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា ត្រង់ថាភាគីអ្នកលក់អាចមានសិទ្ធិប្រកែកមិនផ្ទេរសិទ្ធិលើកម្មសិទ្ធិនៃអចលនវត្ថុនោះទៅឱ្យអ្នកទិញបាន បើទោះបីជាមិនទាន់ដល់ពេលកំណត់ត្រូវបំពេញកាតព្វកិច្ចក៏ដោយ ដោយសារតែអ្នកលក់មានការបារម្ភទៅលើទិដ្ឋភាពជាក់ស្តែងរបស់អ្នកទិញចំពោះបញ្ហាដែលអ្នកទិញនោះគ្មានធនធានគ្រប់គ្រាន់ទៅតាមតម្លៃនៃការព្រមព្រៀង ដែលបណ្តាល

---

[71] សូមពិនិត្យលើមាត្រា៥៤១ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ។

[72] សូមពិនិត្យលើមាត្រា៥៥១ វាក្យខណ្ឌ១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីដដែល ។

មកពីអ្នកទិញបានក្ស័យធន ឬ ខ្វះទ្រព្យធនក្រោយពេលបង្កើតកិច្ចសន្យា ឬ អ្នកទិញបានលាក់បាំងអំពីកង្វះខាតទៅលើទ្រព្យធនរបស់ខ្លួនមុនពេលបង្កើតកិច្ចសន្យា។[73]

**២.១.១.៤. សិទ្ធិទទួលផលរបស់អ្នកលក់**

សិទ្ធិទទួលផលរបស់អ្នកលក់នៅទីនេះ គឺសំដៅទៅលើផលនានាទាំងផលស៊ីវិលដូចជាប្រាក់ឬថ្លៃឈ្នួលដែលបានមកពីការជួលអចលនវត្ថុជាដើម និង ទាំងផលធម្មជាតិដូចជាភោគផលនានាដែលដុះលើអចលនវត្ថុនោះជាដើម។ ដែលជាអត្ថប្រយោជន៍កើតចេញពីអចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញហើយអ្នកលក់មានសិទ្ធិទទួលបាននៅមុនពេលប្រគល់ឬផ្ទេរកម្មសិទ្ធិទៅឱ្យអ្នកទិញលើកលែងតែមានការព្រមព្រៀងគ្នាជាមុន។ ឧទាហរណ៍៖ កិច្ចសន្យាការលក់ទិញដីចម្ការស្វាយមួយកន្លែងក្នុងខេត្តកណ្តាលដែលកំពុងស្ថិតក្នុងដំណាក់កាលនៃការផ្ទេរកម្មសិទ្ធិទៅឱ្យភាគីអ្នកទិញដូច្នេះនៅមុនពេលនៃការផ្ទេរកម្មសិទ្ធិនោះមិនទាន់ស្ថាពរ ស្វាយដែលនៅក្នុងចម្ការនោះអ្នកលក់ដែលជាម្ចាស់ដើមនៃទ្រព្យនៅតែអាចប្រមូលផលបានក្នុងករណីមិនមានការសន្យាពិសេសរវាងភាគីទាំងពីរទេ។ កាលដែលច្បាប់បានកំណត់បែបនេះចំពោះសិទ្ធិអ្នកលក់គឺដើម្បីឱ្យសមភាពគ្នារវាងសិទ្ធិអ្នកទិញ ដែលតម្រូវឱ្យមិនចាំបាច់បង់ការប្រាក់នៃថ្លៃទិញរហូតដល់អ្នកទិញទទួលបាននូវកម្មសិទ្ធិនោះ។[74]

**២.១.២. ករណីយកិច្ចរបស់អ្នកលក់**

នៅក្នុងកិច្ចសន្យាលក់ទិញ ការគោរពនូវករណីយកិច្ចរបស់ខ្លួនក្នុងនាមជាអ្នកលក់ គឺជាប្រការដ៏សំខាន់ដើម្បីវាងនូវវិវាទដែលកើតឡើងជាយថាហេតុ។ ដើម្បីបង្ការនូវវិវាទក្នុងកិច្ចសន្យាលក់ទិញក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានបញ្ញត្តិយ៉ាងច្បាស់លាស់ទៅលើករណីយកិច្ចរបស់អ្នកលក់ក្នុងនោះរួមមាន៖ ករណីយកិច្ចត្រូវពន្យល់ឬការផ្តល់ព័ត៌មាន(២.១.២.១)ករណីយកិច្ចប្រគល់អចលនវត្ថុ (២.១.២.២) ករណីយកិច្ចក្នុងការផ្ទេរសិទ្ធិ (២.១.២.៣) ករណីយកិច្ចក្នុងការធានាចំពោះកម្មវត្ថុ (២.១.២.៤) ។

**២.១.២.១. ករណីយកិច្ចត្រូវពន្យល់ ឬ ការផ្តល់ព័ត៌មាន**

ករណីយកិច្ចពន្យល់គឺជាការផ្តល់ព័ត៌មានចាំបាច់ចំពោះការជាប់ពាក់ព័ន្ធនឹងវត្ថុដែលខ្លួនបានលក់នេះជាពិសេសក្នុងករណីលក់ដូចជាអចលនវត្ថុជាផ្ទះ ឬ ក៏ដីធ្លីអ្នកលក់ត្រូវពន្យល់ដល់អ្នកទិញឱ្យបានច្បាស់លាស់អំពីខ្លឹមសារនៃសិទ្ធិលើអចលនវត្ថុ(សិទ្ធិជាម្ចាស់កម្មសិទ្ធិករនៃអចលនវត្ថុឬជាភោគៈ[75] ឬ មានសិទ្ធិលើចំណែកណា

---

[73] សូមពិនិត្យលើមាត្រា៥៥១ វាក្យខណ្ឌ១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[74] មាត្រា៥៥៦ នៃក្រមរដ្ឋប្បវេណីដដែល ។

[75] ភោគៈ គឺជាសិទ្ធិ ដែលជនម្នាក់មានលើទ្រព្យណាមួយជាបណ្តោះអាសន្នមិនទាន់ស៊ុប ជារបស់ខ្លួនមែនទែនទេ។ "ភោគៈ" ជាពាក្យផ្ទុយនឹងកម្មសិទ្ធិដែលជាសិទ្ធិបរិបូណ៌របស់ជនម្នាក់ៗលើទ្រព្យ ។(សទានុក្រមនៃច្បាប់ភូមបាលឆ្នាំ ២០០១)

មួយនៃកម្មសិទ្ធិអវិភាគ[76]) អំពីព្រំដែននៃអចលនវត្ថុ និងពីបន្ទុកផ្សេងៗ ដែលអាចមានលើអចលនវត្ថុនេះ តួយ៉ាងដូចជាករណីមានសេវភាពតម្រូវឱ្យបើកផ្លូវឆ្លងកាត់ជាដើម។

ប្រសិនបើអ្នកលក់មិនបំពេញតាមករណីយកិច្ចផ្តល់ព័ត៌មាននេះទេ ឬផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ ឬមិនច្បាស់លាស់គាត់ជាអ្នកទទួលខុសត្រូវចំពោះការខូចខាតណាមួយដែលកើតឡើង ដោយសារការខកខានមិនបានផ្តល់ព័ត៌មាននេះ។ ម្យ៉ាងទៀតប្រសិនបើអ្នកលក់ផ្តល់ព័ត៌មានមិនពិត ឬ លាក់បាំងការពិតដោយចេតនា ហើយព័ត៌មានមិនពិត ឬ ព័ត៌មានដែលលាក់កំបាំងនេះគឺជាចំណុចសំខាន់ដែលមានឥទ្ធិពលលើការសម្រេចចិត្តរបស់អ្នកទិញ ក្នុងករណីនេះអ្នកទិញអាចសុំលុបចោលកិច្ចសន្យានេះវិញបានដោយលើកយកការឆបោកមកធ្វើជាមូលហេតុ។

**២.១.២.២. ករណីយកិច្ចប្រគល់អចលនវត្ថុ**

ជាករណីយកិច្ចទូទៅរបស់អ្នកលក់គឺត្រូវប្រគល់វត្ថុឬផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិដែលគាត់បានព្រមព្រៀងលក់ទៅឱ្យអ្នកទិញ (មាត្រា ៥៣០នៃក្រមរដ្ឋប្បវេណីកម្ពុជា) ដោយគ្មានវិការៈទៅតាមពេលវេលានិងទីកន្លែងដែលបានកំណត់ក្នុងកិច្ចសន្យាឬតាមរយៈការព្រមព្រៀងផ្ទាល់មាត់ក្តី ហើយសិទ្ធិលើទ្រព្យ ឬ វត្ថុដែលត្រូវប្រគល់ទៅឱ្យអ្នកទិញនេះត្រូវតែមានបរិមាណនិងគុណភាពដូចអ្វីដែលបានព្រមព្រៀងគ្នា។

ចំណែកឯវិធីក្នុងការប្រគល់អចលនវត្ថុវិញ គឺអាចធ្វើឡើងបានជាច្រើនទម្រង់ទៅតាមការសម្រេច និងការព្រមព្រៀងរបស់ភាគីថាតើវិធីណាមួយក្នុងការប្រគល់ ហើយមានផលប្រយោជន៍សម្រាប់គ្នាទៅវិញទៅមកដើម្បីបង្កលក្ខណៈងាយស្រួលដល់ភាគីនៃកិច្ចសន្យា។ ក្នុងគោលបំណងនេះក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានកំណត់អំពីវិធីប្រគល់ ជាពិសេសការប្រគល់សំរាប់អចលនវត្ថុ អាចជាការប្រគល់ សោរនៃអាគារ ឬ ប្រគល់ប័ណ្ណបញ្ជាក់សិទ្ធិ ដែលការប្រគល់នេះត្រូវធ្វើឡើងតាមវិធីប្រគល់កម្មវត្ថុដោយជាក់ស្តែង វិធីប្រគល់ដោយសង្ខេប វិធីផ្ទេរការកាន់កាប់ដោយបញ្ជា ឬ វិធីប្តូរលក្ខណៈនៃការកាន់កាប់ ។[77] ក្នុងករណីដែលអចលនវត្ថុនោះមិនទាន់មានប័ណ្ណកម្មសិទ្ធិនៅឡើយទេអ្នកលក់ត្រូវមានករណីយកិច្ចក្នុងការប្រគល់លិខិតផ្សេងៗហើយដែលមានភាពចាំបាច់ក្នុងបញ្ជាក់នូវសិទ្ធិលើអចលនវត្ថុនោះចំពោះអ្នកទិញដើម្បីជាសំអាងអំពីការផ្ទេរកម្មសិទ្ធិរវាងអ្នកលក់ និង អ្នកទិញសម្រាប់ជាដំណើរការដល់អ្នកទិញក្នុងការចុះបញ្ជីកម្មសិទ្ធិជាដើម។ ម្យ៉ាងទៀតប្រសិនបើការប្រគល់វត្ថុ ឬ ការផ្ទេរសិទ្ធិលើវត្ថុត្រូវធ្វើនៅក្រោយការបង្កើតកិច្ចសន្យាលក់ទិញ អ្នកលក់មានករណីយកិច្ចថែរក្សាវត្ថុ ឬ ទ្រព្យនោះឱ្យ

[76] កម្មសិទ្ធិអវិភាគ សំដៅលើស្ថានភាពដែលបុគ្គលច្រើននាក់មានកម្មសិទ្ធិស្របទៅតាមភាគចំណែករបស់ខ្លួនដែលមានទៅតាមចំនួននៃទ្រព្យតែមួយ។(មាត្រា ២០២ នៃក្រមរដ្ឋប្បវេណី)

[77] មាត្រា២២៩,មាត្រា៥៥០ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ។

ដូចសភាពដើមតាមការកំណត់ក្នុងកិច្ចសន្យារហូតដល់ពេលប្រគល់ទៅឱ្យអ្នកទិញ ហើយច្បាប់តម្រូវឱ្យអ្នកលក់ថែរក្សាវត្ថុ ឬទ្រព្យដែលជាកម្មវត្ថុនៃការលក់នេះឱ្យបានហ្មត់ចត់ក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ។[78] ក្នុងករណីដែលអ្នកលក់ធ្វើឱ្យបាត់បង់ឬធ្វើឱ្យខូចខាតវត្ថុ ដែលជាកម្មវត្ថុនៃការលក់ដោយសារតែមានការធ្វេសប្រហែសមិនបានគោរពករណីយកិច្ចថែរក្សាវត្ថុនោះអ្នកលក់នឹងត្រូវទទួលខុសត្រូវ ចំពោះអ្នកទិញទៅតាមអ្វីដែលបានចែងក្នុងកិច្ចសន្យា ឬ ត្រូវសងសំណងខូចខាតទៅតាមការចែងក្នុងក្រមរដ្ឋប្បវេណីទាក់ទងនឹងសំណងខូចខាតក្នុងករណីមិនគោរពកាតព្វកិច្ចតាមកិច្ចសន្យា ។[79]

**២.១.២.៣. ករណីយកិច្ចក្នុងការផ្ទេរសិទ្ធិ**

អ្នកលក់ត្រូវមានករណីយកិច្ចផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិដែលខ្លួនបានលក់ (មាត្រា ៥៣០)។ ការផ្ទេរកម្មសិទ្ធិនេះនាំឱ្យមានការផ្លាស់ប្តូរកម្មសិទ្ធិករនៃទ្រព្យផងដែរ ។

ការផ្ទេរកម្មសិទ្ធិ គឺជាករណីយកិច្ចដ៏សំខាន់នៅក្នុងកិច្ចសន្យាលក់ទិញពីព្រោះកិច្ចសន្យាលក់ទិញធ្វើឡើងក្នុងគោលបំណងដើម្បីផ្ទេរកម្មសិទ្ធិពីអ្នកលក់ទៅឱ្យអ្នកទិញ ដូចនេះអ្នកលក់មានករណីយកិច្ចត្រូវតែផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញទៅឱ្យអ្នកទិញ[80] ហើយការផ្ទេរកម្មសិទ្ធិក្នុងកិច្ចសន្យាលក់ទិញ ត្រូវអនុវត្តតាមគោលការណ៍ទូទៅដែលបានកំណត់នៅក្នុងមាត្រា១៣៣,១៣៤, ១៣៥,១៦០ និង ១៨៧ លើកលែងតែកម្មវត្ថុនៃកិច្ចសន្យាលក់ទិញជាសិទ្ធិលើទ្រព្យសម្បត្តិក្រៅពីកម្មសិទ្ធិ ដែលការផ្ទេរសិទ្ធិទាំងនោះត្រូវអនុវត្តតាមគោលការណ៍ទូទៅដែលទាក់ទងនឹងការផ្ទេរសិទ្ធិទីមួយ១ នោះ(មាត្រា ៥២៨ កថាខណ្ឌទី១) ។[81] ដូចនេះជារួមសិទ្ធិដែលខ្លួនបានលក់ត្រូវបានផ្ទេរដូចនៅក្នុងករណីខាងក្រោម៖

- កិច្ចសន្យាលក់ទិញលើកម្មសិទ្ធិនៃអចលនវត្ថុ៖ នៅពេលផ្ទេរការចុះបញ្ជី ត្រូវបានធ្វើឡើង។
- កិច្ចសន្យាលក់ទិញក្រៅពីកម្មសិទ្ធិនៃអចលនវត្ថុ៖ នៅពេលព្រមព្រៀង ។

**២.១.២.៤. ករណីយកិច្ចក្នុងការធានាចំពោះកម្មវត្ថុ**

ករណីយកិច្ចក្នុងការធានារបស់អ្នកលក់ចំពោះអ្នកទិញក្នុងកិច្ចសន្យាលក់ទិញដែលមានបញ្ញត្តិដោយក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ គឺមានច្រើនដូចជា ការធានាសិទ្ធិមួយភាគជាសិទ្ធិអ្នកដទៃ ការធានានៅពេលដែលសិទ្ធិប្រត្យក្សនិងសិទ្ធិប្រាតិភោគប្រត្យក្សកើតមានក្នុងករណីដែលមានការលក់ដោយបង្ខំ ឬ ករណីដែលកម្មវត្ថុនៃ

---

[78] មាត្រា៥៥២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ។

[79] មាត្រា៣៩៨ វាក្យខណ្ឌ១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីដដែរ។

[80] មាត្រា ៥៣១ កថាខណ្ឌទី១នៃក្រមរដ្ឋប្បវេណីដដែល ។

[81] សៀវភៅភាគទី៣ ផ្នែកទី៦ គ្របដណ្តប់លើមូលដ្ឋាននៃនីតិកិច្ចសន្យានៃក្រមរដ្ឋប្បវេណី ដែលជាជំនួយរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA)បោះពុម្ពលើកទី១ ក្នុងខែ មីនា ឆ្នាំ ២០១២

ការលក់ទិញនោះកើតមាននូវវិការៈជាដើម ដែលទាំងនេះសុទ្ធតែជាផលវិបាកដែលបង្កឡើងដោយភាគីអ្នកលក់ ដូច្នេះអ្នកលក់ត្រូវមានការធានាចំពោះបញ្ហានេះទៅដល់ភាគីអ្នកទិញ ដើម្បីជៀសវាងកើតមាននូវវិវាទនៃកិច្ចសន្យានៅពេលក្រោយ។ ក៏ប៉ុន្តែការលក់ទិញអចលនវត្ថុនៅកម្ពុជា យើងអាចកំណត់ចំពោះករណីយកិច្ចធានាធំៗរបស់អ្នកលក់ជាអចលនវត្ថុចំនួន០២(ពីរ)គឺ ការធានាដោយសារការរំខានពីតតិយជន ឬ សកម្មភាពរបស់អ្នកលក់ផ្ទាល់ និង ការធានាក្នុងករណីដែលអចលនវត្ថុនោះមានវិការៈ។

**ការធានាដោយសារការរំខានពីតតិយជន ឬសកម្មភាពរបស់អ្នកលក់ផ្ទាល់៖** ការរំខាននៅទីនេះសំដៅទៅលើឧបសគ្គនានានៅក្នុងនីតិវិធីផ្ទេរកម្មសិទ្ធិឬក្នុងការប្រគល់អចលនវត្ថុ ឬ មានការផ្ទេរប្រគល់រួចហើយពីអ្នកលក់ទៅកាន់អ្នកទិញដោយសារកំហុសរបស់អ្នកលក់ផ្ទាល់ខ្លួន ឬ មានការតតាំងជាមួយតតិយជនជាដើម។ ការរំខានពីអ្នកលក់មានរូបភាពដូចជាការរំលោភលើកម្មសិទ្ធិដែលខ្លួនបានផ្ទេរឱ្យទៅអ្នកទិញហើយធ្វើឱ្យមានផលវិបាកសម្រាប់អ្នកទិញឬការលើកសំអាងថាខ្លួនមានសិទ្ធិផ្សេងៗលើអចលនវត្ថុដែលវាផ្ទុយពីការពិតជាក់ស្តែង។ អ្នកលក់ក៏ត្រូវធានាផងដែរ នូវការរំខានពីតតិយជនដើម្បីឱ្យអ្នកទិញមានទំនុកចិត្តទៅលើកិច្ចសន្យាលក់ទិញនេះ អ្នកលក់ត្រូវតែធានាថាខ្លួនពិតជាម្ចាស់កម្មសិទ្ធិករឬមិនមានសិទ្ធិមួយភាគណាជាសិទ្ធិរបស់អ្នកដទៃ។ ការរំខានពីតតិយជនអាចជាការទាមទារដកហូតយកអចលនវត្ថុនោះទាំងស្រុង ឬ មួយផ្នែកពីអ្នកទិញដោយសំអាងជាម្ចាស់កម្មសិទ្ធិស្របច្បាប់ឬបង្ហាញថាខ្លួនមានសិទ្ធិផ្សេងទៀតលើអចលនវត្ថុនោះ។

**ការធានាក្នុងករណីដែលអចលនវត្ថុនោះមានវិការៈ៖** អ្នកលក់ត្រូវមានករណីយកិច្ចប្រគល់វត្ថុដែលគ្មានវិការៈទៅឱ្យអ្នកទិញ។[82] ការដែលប្រគល់វត្ថុផ្ទុយទៅនឹងកិច្ចសន្យាដោយសារកម្មវត្ថុនោះមានលក្ខណៈមិនប្រក្រតី ដូចជា ការផ្ទេរសិទ្ធិលើដីដែលបានមកពីភាពមិនស្របច្បាប់ ផ្ទះ ឬអាគារសហកម្មសិទ្ធិដែលគ្មានគុណភាពទាំងនេះគឺសំគាល់ទៅលើវិការៈនៃអចលនវត្ថុ។ ក្នុងករណីដែលមានបញ្ហាវិការៈនេះកើតឡើងហើយអ្នកទិញមិនបានដឹងនោះអ្នកទិញអាចទាមទារឱ្យអ្នកលក់អនុវត្តពេញលេញមកខ្លួនតាមរយៈ **ការប្រគល់វត្ថុជំនួយ កាត់បន្ថយតម្លៃ ការជួសជុលវិការៈនោះ សំណងខូចខាត និងការរំលាយកិច្ចសន្យា** ជាអាទិ៍។[83] ក៏ប៉ុន្តែក្នុងករណីវត្ថុដែលមានវិការៈនោះអ្នកទិញមិនបានដឹងដោយសារកំហុសរបស់ខ្លួន(មិនបានពិនិត្យពិច័យជាមុន)នោះកិច្ចសន្យាលក់ទិញអចលនវត្ថុនោះមិនអាចរំលាយបានឡើយ។ តែក្នុងករណីអ្នកទិញបានដឹងអំពីអត្ថិភាពនៃវិការៈនោះដោយគ្មានការតវ៉ានោះអ្នកលក់មិនមានការទទួលខុសត្រូវក្នុងការធានាទេ។[84] ការទទួលខុសត្រូវក្នុងការធានាវិការៈកើតឡើងនៅក្នុងករណីដែលគូភាគីមិនបានដឹងអំពីអត្ថិភាពនៃវិការៈនៅពេលផ្ទេរនូវហានិភ័យ។ ចំពោះការធានា

---

[82] មាត្រា ៥៣៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ។

[83] មាត្រា៥៤០ដល់មាត្រា២២៩នៃក្រមរដ្ឋប្បវេណីដដែល ។

[84] មាត្រា៥៤០កថាខណ្ឌទី២នៃក្រមរដ្ឋប្បវេណីដដែរ។

អចលនវត្ថុដែលមានវិការៈ គឺចំពោះតែភាគីអ្នកទិញដែលមានភាពសុចរិត និងគ្មានកំហុសធ្ងន់ធ្ងរតែប៉ុណ្ណោះ ហើយសម្រាប់ការជួសជុលនេះមិនមែនជាបន្ទុកហួសហេតុឡើយ បើមិនដូច្នេះទេអ្នកលក់មានករណីយកិច្ចត្រឹមសងសំណងដោយគ្មានការជួសជុលឡើយ។

**២.១.៣. សិទ្ធិរបស់អ្នកទិញ**

សិទ្ធិរបស់អ្នកទិញបានកើតឡើងព្រមជាមួយនៅអានុភាពនៃកិច្ចសន្យាលក់ទិញដែរ ម្យ៉ាងទៀតចំពោះសិទ្ធិរបស់អ្នកទិញគឺមានភាពស្មើគ្នាទៅនឹងភាគីអ្នកលក់ ប៉ុន្តែបើនិយាយពីកាតព្វកិច្ចអ្នកទិញវិញគឺ មានតិចជាងអ្នកលក់។ កាតព្វកិច្ចធំបំផុតរបស់អ្នកទិញគឺបង់ថ្លៃទិញទៅតាមកិច្ចសន្យា កាតព្វកិច្ចមួយទៀតគឺ កាតព្វកិច្ចទទួលវត្ថុទៅតាមការកំណត់ក្នុងកិច្ចសន្យា។ សិទ្ធិរបស់អ្នកទិញមានដូចជា សិទ្ធិទាមទារឱ្យអនុវត្តពេញលេញ (២.១.៣.១) សិទ្ធិបដិសេធចំពោះការបង់ថ្លៃទិញ (២.១.៣.២) សិទ្ធិទាមទារឱ្យបន្ថយថ្លៃលក់ (២.១.៣.៣) សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នានិងសិទ្ធិតវ៉ាដោយមានការបារម្ភ(២.១.៣.៤) ។

**២.១.៣.១. សិទ្ធិទាមទារឱ្យអនុវត្តពេញលេញ**

អ្នកទិញមានសិទ្ធិក្នុងការទទួលបាននូវកម្មសិទ្ធិលើកម្មវត្ថុនៃការលក់ទិញរបស់ខ្លួនព្រមជាមួយសិទ្ធិផ្សេងៗទៀតដែលអ្នកលក់បានប្រគល់ឱ្យ ដែលមាននៅក្នុងបញ្ញត្តិពិសេសនៃកិច្ចសន្យាតាមរយៈការព្រមព្រៀងគ្នាក្នុងនោះក៏មានសិទ្ធិក្នុងការទទួលផលរបស់អ្នកទិញ[85] (ការកំណត់យកតាមកិច្ចសន្យាពិសេសតាមការព្រមព្រៀងរបស់គូភាគីជារឿងសមហេតុផល ដែលទទួលស្គាល់ការបង្ហាញឆន្ទៈដោយស្មោះត្រង់ក្នុងការលះបង់សិទ្ធិរបស់ភាគីណាមួយនៃកិច្ចសន្យា ដើម្បីសម្រួលដល់ប្រតិបត្តិការលក់ទិញឲ្យកាន់តែមានភាពល្អប្រសើរ)ផងដែរ។ សិទ្ធិទាមទារឱ្យអនុវត្តពេញលេញនៅក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុវាជាការទាមទាររបស់អ្នកទិញ ទៅលើអ្នកលក់ដើម្បីឱ្យអ្នកលក់អនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនដូចជា កាតព្វកិច្ចផ្ទេរកម្មសិទ្ធិ កាតព្វកិច្ចប្រគល់វត្ថុ កាតព្វកិច្ចជួសជុលវត្ថុជាអាទិ៍ ឱ្យបានពេញលេញដើម្បីកុំឱ្យប៉ះពាល់ដល់ផលប្រយោជន៍អ្នកទិញ នៅពេលដែលអ្នកលក់មានភាពទុច្ចរិតក្នុងការអនុវត្តកាតព្វកិច្ចនោះ។ ដូច្នេះក្នុងករណីនេះប្រសិនបើអ្នកលក់មានការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនទៅលើកិច្ចសន្យាក្នុងអំឡុងពេល ដែលបានកំណត់នោះអ្នកទិញមានសិទ្ធិនៅក្នុងការទាមទារឱ្យមានការសង្គ្រោះនូវកិច្ចសន្យាចំពោះការបំពានកាតព្វកិច្ចនោះ និង អ្នកទិញអាចទាមទារសំណងខូចខាតពីអ្នកលក់ដែលបណ្ដាលមកពីការមិនអនុវត្តកាតព្វកិច្ចនោះផងដែរ។

[85] គឺជាសិទ្ធិដែលអ្នកទិញទទួលបានពីការផ្ទេរសិទ្ធកម្មសិទ្ធិរបស់អ្នកលក់ទៅឱ្យអ្នកទិញ ដែលជាការបកស្រាយផ្ទុយពីមាត្រា ៥៥៣ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ ។

### ២.១.៣.២. សិទ្ធិបដិសេធមិនបង់ថ្លៃទិញ

អ្នកទិញក៏មានសិទ្ធិក្នុងការបដិសេធមិនបង់ថ្លៃទិញទៅអ្នកលក់ដែរនៅក្នុងករណីដែលអ្នកទិញមានការបារម្ភថាខ្លួននឹងមិនបានទទួលកម្មសិទ្ធិ លើអចលនវត្ថុនៃការលក់ទិញដោយសារតែសិទ្ធិនោះជារបស់តតិយជនតាមរយៈការអះអាងពីអ្នកដែលបានដឹងអំពីសិទ្ធិលើកម្មវត្ថុនៃការលក់ទិញនោះ។ ក្នុងករណីបើសិទ្ធិទាំងមូលឬសិទ្ធិតែមួយភាគប៉ុណ្ណោះជារបស់តតិយជនក្រៅពីអ្នកទិញអាចបដិសេធមិនបង់ថ្លៃទិញ អ្នកទិញមានសិទ្ធិរំលាយកិច្ចសន្យា និង សំណងការខូចខាតបានដែរ បើអ្នកលក់មិនអាចផ្ទេរកម្មសិទ្ធិលើកម្មវត្ថុនៃការលក់ទិញនោះមកឱ្យអ្នកទិញបានទេ ។[86]

### ២.១.៣.៣. សិទ្ធិទាមទារឱ្យបន្ថយថ្លៃទិញ

ក្នុងករណីវត្ថុដែលការប្រគល់មានវិការៈ ទោះបីជាថ្លៃលក់បង់ហើយ ឬមិនទាន់ហើយក៏ដោយ ក៏អ្នកទិញអាចទាមទារឱ្យបន្ថយថ្លៃលក់ តាមសមាមាត្រនៃភាពខុសគ្នានៅពេលប្រគល់វត្ថុរវាងតម្លៃនៃវត្ថុដែលគ្មានវិការៈនោះ និងតម្លៃនៃវត្ថុដែលត្រូវបានប្រគល់បានដែរ តែបើក្នុងករណីអ្នកលក់បានធ្វើការជួសជុលដោយអនុវត្តចំពោះវត្ថុមានវិការៈ ហើយអ្នកទិញមិនព្រមទទួលដោយគ្មានមូលហេតុត្រឹមត្រូវក៏អ្នកទិញមិនអាចទាមទារឱ្យបន្ថយតម្លៃលក់ឡើយ ។[87]

### ២.១.៣.៤. សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា និង សិទ្ធិតវ៉ាដោយមានការបារម្ភ

ចំពោះសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា មានន័យថាអ្នកទិញមានសិទ្ធិមិនព្រមបង់ថ្លៃទិញបើអ្នកលក់មិនទាន់ប្រគល់ ឬ ផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញនោះមកឱ្យអ្នកទិញទេ។ ប៉ុន្តែប្រសិនបើអ្នកលក់មិនទាន់ដល់ពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ចទេ ឬ អ្នកទិញមានការព្រមព្រៀងថានឹងបង់ថ្លៃជាមុន នោះអ្នកទិញត្រូវតែអនុវត្តការបង់ថ្លៃទិញនោះ។[88]

ចំណែកឯសិទ្ធិតវ៉ាដោយមានការបារម្ភ គឺអ្នកទិញមានសិទ្ធិប្រកែកមិនបង់ថ្លៃទិញបានប្រសិនបើអ្នកទិញមានការបារម្ភថា អ្នកលក់នឹងមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ ប៉ុន្តែប្រសិនបើអ្នកលក់បានដាក់ប្រតិភោគ ឬ បានចាត់ចែងវិធានការដើម្បីរំលត់ការបារម្ភហើយ អ្នកទិញមិនអាចប្រកែកមិនបង់ថ្លៃបានទៀតទេ ។ សម្រាប់អាជ្ញាយុកាលនៃការអនុវត្តសិទ្ធិរបស់អ្នកទិញដូចដែលបានរៀបរាប់ខាងលើនេះ គឺមានរយៈពេល ១ ឆ្នាំប៉ុណ្ណោះ លើកលែងតែសិទ្ធិទាមទារសំណងនៃការខូចខាតទៅលើការខ្វះទំហំដី ត្រូវគិតអាជ្ញាយុកាលរយៈពេល ៥ ឆ្នាំ ។

---

[86] មាត្រា ៥៥៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ។

[87] មាត្រា ៥៤៤ នៃក្រមរដ្ឋប្បវេណីដដែល ។

[88] មាត្រា ៥៥៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីដដែល ។

### ២.១.៤. ករណីយកិច្ចរបស់អ្នកទិញ

នៅក្នុងក្រមរដ្ឋប្បវេណីបានបញ្ញត្តិនូវករណីយកិច្ចរបស់អ្នកទិញដូចជាករណីយកិច្ចបង់ថ្លៃទិញ(២.១.៤.១) និង ករណីយកិច្ចទទួលវត្ថុដែលបានទិញ (២.១.៤.២) ។[89]

#### ២.១.៤.១. ករណីយកិច្ចបង់ថ្លៃទិញ

អ្នកទិញមានករណីយកិច្ចក្នុងការបង់ថ្លៃទិញជាប្រាក់ទៅតាមទីកន្លែងនិងកាលបរិច្ឆេទដែលបានកំណត់ក្នុងកិច្ចសន្យាលក់ទិញនោះ។ កាលបរិច្ឆេទនិងទីកន្លែងនៃការបង់ប្រាក់ត្រូវសម្រេចដោយផ្អែកតាមការព្រមព្រៀងរបស់គូភាគីនៃកិច្ចសន្យាលក់ទិញ។ ដូចនេះបើមិនបានកំណត់តាមកាលបរិច្ឆេទនិងទីកន្លែងបង់ប្រាក់ទេភាគីអាចកំណត់ពេលធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីអចលនវត្ថុនៃការលក់ទិញជាពេលសម្រាប់បង់ថ្លៃទិញបាន។ បើមិនបានកំណត់ពេលធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីអចលនវត្ថុជាកម្មវត្ថុនៃការលក់ទិញទៀតនោះអ្នកទិញត្រូវបង់ថ្លៃទិញនៅពេលដែលអ្នកលក់ទាមទារឱ្យបង់ហើយ។ លើសពីនេះអ្នកទិញអាចមិនចាំបាច់បង់ការប្រាក់ឬសំណង់ខូចខាតដោយសារការយឺតយ៉ាវរបស់ខ្លួនទេរហូតដល់អចលនវត្ថុដែលជាកម្មវត្ថុលក់ទិញដល់ពេលប្រគល់ ។

#### ២.១.៤.២. ករណីយកិច្ចទទួលវត្ថុដែលបានទិញ

អ្នកទិញមានករណីយកិច្ចក្នុងការទទួលកម្មវត្ថុដែលខ្លួនបានទិញ។ បើអ្នកទិញមានការយឺតយ៉ាវក្នុងការទទួលវត្ថុដែលខ្លួនបានទិញ ហើយធ្វើឱ្យខូចប្រយោជន៍ដល់អ្នកលក់នោះអ្នកទិញត្រូវសងសំណងការខូចខាតដល់អ្នកលក់ ហើយអាចប្រឈមនឹងការរំលាយកិច្ចសន្យាលក់ទិញនោះផងដែរ។ ម្យ៉ាងវិញទៀតអ្នកទិញត្រូវទទួលបន្ទុកហានិភ័យចំពោះការបាត់បង់ ឬ ការខូចខាតវត្ថុដែលខ្លួនមិនមកទទួលនោះបើការខូចខាតវាមិនមែនជាកំហុសអ្នកលក់។ ប្រសិនបើអ្នកលក់បានប្រគល់អចលនវត្ថុដែលជាកម្មវត្ថុលក់តែអ្នកទិញមិនព្រមទទួលអ្នកលក់អាចតម្កល់ឬលក់វត្ថុនោះបាន ។

ប្រសិនបើអ្នកទិញមានការយឺតយ៉ាវក្នុងការបំពេញករណីយកិច្ចទទួលវត្ថុអ្នកលាក់អាចទាមទារសំណងប្រសិនបើការយឺតយ៉ាវនេះនាំឱ្យគាត់ទទួលរងនូវការខូចខាតអ្វីមួយ ឬ ក៏អាចទាមទាររំលាយកិច្ចសន្យាទិញលក់នេះវិញបាន។

[89] មាត្រា ៥៥៤ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ/១២០៧/រកម/២០០៧ ។

## ២.២. ការផ្ទេរកម្មសិទ្ធិតាមរយៈកិច្ចសន្យាលក់ទិញអចលនវត្ថុ

នៅក្នុងកិច្ចសន្យាលក់ទិញអ្នកលក់ដែលជាម្ចាស់នៃវត្ថុមានករណីយកិច្ចធំ គឺត្រូវប្រគល់កម្មវត្ថុនៃកិច្ចសន្យាឱ្យទៅភាគីម្ខាងទៀតជាអ្នកទិញ។ ប៉ុន្តែការលក់ទិញអចលនវត្ថុមានលក្ខណៈពិសេសជាងការលក់ទិញធម្មតាត្រង់ថាបន្ទាប់ពីមានការប្រគល់ អ្នកលក់ត្រូវផ្ទេរកម្មសិទ្ធិរបស់ខ្លួនឱ្យទៅភាគីម្ខាងទៀតដោយគ្មានវិការៈទើបកិច្ចសន្យាលក់ទិញអចលនវត្ថុចាត់ទុកថាមានអានុភាពជាស្ថាពរ។ ការផ្ទេរកម្មសិទ្ធិលើកិច្ចសន្យាលក់ទិញអចលនវត្ថុត្រូវអនុវត្តទៅតាមគោលការណ៍ទូទៅដែលបានកំណត់ស្តីពី ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្សដោយការព្រមព្រៀង បន្ទាប់ពីមានការព្រមព្រៀងគ្នាក្នុងការបង្កើតកិច្ចសន្យានឹងមានការអនុត្តសិទ្ធិកាតព្វកិច្ចរបស់ខ្លួនរួចមក ហើយក៏ជាដំណាក់កាលចុងក្រោយនិងជាផ្នែកមួយដ៏សំខាន់ដើម្បីឱ្យកិច្ចសន្យាលក់ទិញអចលនវត្ថុទាំងមូលមានលក្ខណៈពេញលេញទៅតាមបទដ្ឋានគតិយុត្ត ។

ដើម្បីកំណត់ថាការផ្ទេរកម្មសិទ្ធិរបស់ភាគីនៅក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុបានសម្រេច លុះត្រាតែមានការចុះបញ្ជីដោយគោរពតាមនីតិវិធី ប៉ុន្តែដោយហេតុថាការលក់ទិញអចលនវត្ថុបច្ចុប្បន្នមានការពេញនិយមទៅលើអាគារសហកម្មសិទ្ធិហើយការផ្ទេរកម្មសិទ្ធិ គឺវាមានលក្ខណៈខុសប្លែកពីនីតិវិធីនៃការផ្ទេរទូទៅបន្តិចទើបយើងនឹងលើកមកបង្ហាញដើម្បីកុំឱ្យមានភាពភ័ណ្ឌច្រឡំ។ ដូច្នេះការផ្ទេរកម្មសិទ្ធិនៅទីនេះគឺផ្តោតសំខាន់ទៅលើ នីតិវិធីនៃការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ(២.២.១) និង ការផ្ទេរសិទ្ធិលើចំណែកឯកជននៃអាគារសហកម្មសិទ្ធិ (២.២.២)។

### ២.២.១. នីតិវិធីនៃការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ

ក្នុងគោលបំណងដើម្បីទទួលនូវសិទ្ធិប្រត្យក្ស ភាគីដែលបានបង្កើតកិច្ចសន្យាលក់ទិញអចលនវត្ថុ ជាផ្ទះក្តី ឬ ជាដីធ្លីក្តី ត្រូវស្វះស្វែងក្នុងការចុះបញ្ជីលើអចលនវត្ថុនោះ ដោយសារតែការចុះបញ្ជីគឺជាលក្ខខណ្ឌដែលបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុនោះ។[៩០] ដូច្នេះដើម្បីឱ្យការចុះបញ្ជីមានការទទួលស្គាល់ដោយច្បាប់ភាគីត្រូវគោរពនីតិវិធីនៃការចុះបញ្ជីដោយមានការដាក់ពាក្យសុំ(២.២.១.១)ទាក់ទង់នឹងស្ថាប័នមានសមត្ថកិច្ច ( ២.២.១.២) របៀបនៃការចុះបញ្ជី ( ២.២.១.៣) ការបង់ពន្ធប្រថាប់ត្រា ( ២.២.១.៤) និង ចុងបញ្ចប់គឺការប្រគល់ប័ណ្ណកម្មសិទ្ធិ( ២.២.១.៥) ។

#### ២.២.១.១. ការដាក់ពាក្យសុំចុះបញ្ជី

ការដាក់ពាក្យសុំចុះបញ្ជីគឺជាដំណាក់កាលដំបូងនៅក្នុងនីតិវិធីនៃការចុះបញ្ជី ហើយការដាក់ពាក្យសុំនេះមិនមែនបុគ្គលណាក៏សុទ្ធតែអាចដាក់ពាក្យសុំបានទេ ហើយក៏មិនអាចចេះតែបំពេញនូវចំណុចណាដែលច្បាប់

[៩០] មាត្រា ១៣៥ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧ ។

មិនបានកំណត់នោះដែរ ពោលគឺការដាក់ពាក្យសុំត្រូវគោរពតាមវិធាននៃការកំណត់របស់ប្រកាសអន្តរក្រសួង ស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ដូចខាងក្រោម ៖

**ក.បុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី**

បុគ្គលដែលដាក់ពាក្យសុំចុះបញ្ជីសំដៅទៅលើបុគ្គលដែលមានសិទ្ធិ និងកាតព្វកិច្ច ឬបុគ្គលផ្សេងទៀតដែលត្រូវប្រើសិទ្ធិចុះបញ្ជី ឬត្រូវអនុវត្តកាតព្វកិច្ចចុះបញ្ជី។ បុគ្គលដែលមានសិទ្ធិចុះបញ្ជី គឺសំដៅទៅលើអ្នកទិញដោយសារអ្នកទិញជាអ្នកទទួលប្រយោជន៍ ហើយអាចតតាំងជាមួយតតិយជនបន្តបាននៅពេលកិច្ចសន្យាត្រូវបានបញ្ចប់។ ចំណែកឯបុគ្គលដែលមានកាតព្វកិច្ចក្នុងការចុះបញ្ជីគឺសំដៅលើភាគីជាអ្នកលក់ ដែលទទួលការប៉ះពាល់ផលប្រយោជន៍ដោយផ្ទាល់ពីការចុះបញ្ជីគឺការបាត់បង់សិទ្ធិ។[91] ចំពោះការដាក់ពាក្យសុំចុះបញ្ជីលើអចលនវត្ថុត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សររួមគ្នារវាងភាគីដែលមានសិទ្ធិ និង ភាគីមានកាតព្វកិច្ច (គោលការណ៍ដាក់ពាក្យសុំរួមគ្នា) ឬអាចសុំចុះបញ្ជីតែម្ខាងប៉ុន្តែត្រូវមាននីតិវិធីសម្រាប់ពាក្យសុំចុះបញ្ជីពីភាគីតែម្ខាងនោះ។

**ចំពោះគោលការណ៍នៃពាក្យសុំដែលបានធ្វើ និងដាក់រួមគ្នា**[92]**៖** សំដៅលើបុគ្គលដែលមានសិទ្ធិ និងបុគ្គលដែលមានកាតព្វកិច្ចធ្វើការចុះបញ្ជីរួមគ្នាតែមួយហើយយកទៅដាក់នៅស្ថាប័នពាក់ព័ន្ធ។ ភាគីនៃកិច្ចសន្យាគួរតែដាក់ពាក្យសុំរួមគ្នាក្នុងគោលគំនិតមួយដែលអាចឱ្យខ្លឹមសារនៃការចុះបញ្ជីមានភាពត្រឹមត្រូវ និង កាន់តែប្រសើរតាមរយៈការធានាដោយការដាក់ពាក្យសុំរួមគ្នារបស់ភាគី និងមានភាពរហ័សនៃការចុះបញ្ជីដោយសារអាចធានាបានដោយការពិនិត្យជាលក្ខណៈទម្រង់នូវឯកសារពាក្យសុំដោយមន្ត្រីចុះបញ្ជី។[93] ប៉ុន្តែក្នុងករណីដែលភាគីម្ខាងទៀតមិនអាចដាក់ពាក្យសុំចុះបញ្ជីរួមគ្នាបានដោយសារការមិនសហការ ឬ ដោយមូលហេតុផ្សេងទៀត តើភាគីដែលមានសិទ្ធិក្នុងការដាក់ពាក្យសុំចុះបញ្ជីគួរធ្វើយ៉ាងដូចម្តេច?

**ករណីលើកលែងដែលអាចដាក់ពាក្យសុំចុះបញ្ជីតែម្នាក់ឯង**[94]**៖** គឺសម្រាប់បុគ្គលដែលមានសិទ្ធិក្នុងការចុះបញ្ជីតាមរយៈកិច្ចសន្យាលក់ទិញអចលនវត្ថុត្រូវបានភាគីម្ខាងទៀតបដិសេធមិនព្រមសហការ។ ដូច្នេះនៅពេលដែលមានការចុះបញ្ជីតែម្ខាង នីតិវិធីធ្វើការរបស់មន្ត្រីចុះបញ្ជីនៅរដ្ឋបាលសុរិយោដី គឺតែងមានការស្រាវជ្រាវអំពីកម្មវត្ថុនៃការសុំចុះបញ្ជីដើម្បីបញ្ជាក់អំពីខ្លឹមសារនៃការសុំនោះថាពិត ឬ មិនពិតនៅត្រង់ចំណុចនេះដំណើរការ

---

[91] ប្រការ ៤ កថាខណ្ឌទី៣,៤,៥ នៃប្រកាសអន្តរក្រសួង ស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណីចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣ ។

[92] ប្រការ ១០ កថាខណ្ឌទី១នៃប្រកាសអន្តរក្រសួងដដែល ។

[93] មូលដ្ឋាននៃនីតិវិធីចុះបញ្ជីអចលនវត្ថុទាក់ទងនឹងកម្មសិទ្ធិ រៀបចំដោយការិយាល័យស្រាវជ្រាវនីតិកម្ម ផ្នែកកិច្ចសហប្រតិបត្តិការអន្តរជាតិនៃក្រសួងយុត្តិធម៌ (សាស្ត្រាចារ្យច្បាប់ Uchiyama Jun)។

[94] ប្រការ ១០ កថាខណ្ឌទី២នៃប្រកាសអន្តរក្រសួងដដែល ។

នៃការស្រាវជ្រាវមានរយៈពេលយូរនឹងកាន់តែយឺតយ៉ាវដោយសារមិនមានការធានាពីភាគីម្ខាងទៀត។ ការដាក់ពាក្យសុំចុះបញ្ជីអាចធ្វើឡើងតាមរយៈអ្នកតំណាង គឺមានន័យថាអ្នកតំណាងអាចដាក់ពាក្យសុំចុះបញ្ជី និង ចុះហត្ថលេខាលើលិខិតស្នាមនានាដែលចាំបាច់ក្នុងការសុំចុះបញ្ជីក្នុងនាមជាអ្នកការពារផលប្រយោជន៍របស់ភាគីណាម្ខាងនៃកិច្ចសន្យា។

ដែលអ្នកតំណាងនោះអាចជាអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ អាចជាមេធាវី សាច់ញាតិ ឬ ហិតូបត្ថម្ភកៈ ជាដើម។

ក្នុងករណីយកិច្ចសន្យាលក់ទិញអចលនវត្ថុនោះបង្កើតឡើងដោយបុគ្គលដែលជានីតិបុគ្គល នោះអ្នកតំណាងរបស់នីតិបុគ្គលនោះគឺជា អភិបាលក្រុមហ៊ុននោះ។

**ខ.ទម្រង់ពាក្យសុំ និង ឯកសារភ្ជាប់ដែលចាំបាច់**

បន្ទាប់ពីបានកំណត់អំពីបុគ្គលដែលអាចដាក់ពាក្យសុំចុះបញ្ជីតាមរយៈសិទ្ធិ និងកាតព្វកិច្ចរួចមក បុគ្គលទាំងនោះត្រូវត្រៀមនូវឯកសារផ្សេងៗដែលច្បាប់កំណត់ ភ្ជាប់ជាមួយនឹងការបំពេញទៅតាមទម្រង់នៃពាក្យសុំឱ្យស្របទៅតាមគោលបំណងនៃការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ។ ទម្រង់នៃពាក្យសុំចុះបញ្ជី ដោយយោងតាមប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណីគឺត្រូវបំពេញទៅលើទម្រង់ចំនួនពីរសណ្ឋានដែលមួយជាទម្រង់ទូទៅ[95] និងមួយទៀតគឺទម្រង់ពាក្យសុំទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីនោះ។

ចំពោះកិច្ចសន្យាលក់ទិញអចលនវត្ថុការចុះបញ្ជីផ្ទេរកម្មសិទ្ធិជាគោលបំណងសំខាន់ ពីអ្នកលក់មកអ្នកទិញ ដូច្នេះក្នុងការបំពេញទម្រង់នៃពាក្យសុំចុះបញ្ជីគឺមានការបញ្ចូលគ្នារវាងទម្រង់ទូទៅ និង ពាក្យសុំចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ[96] ដើម្បីទទួលបានចំណុចដូចខាងក្រោមដែលធ្វើឱ្យការបំពេញទម្រង់នៃពាក្យសុំនោះមានលក្ខណៈត្រឹមត្រូវ៖

- ឈ្មោះប្រទេសជាផ្លូវការ
- បាវចនារដ្ឋបាលដែលវត្ថុនោះតាំងនៅ
- រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ឬ រាជធានី ខេត្ត ដែលអចលនវត្ថុតាំងនៅ

---

[95] ប្រការ ២៦ នៃប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណីចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០១៣ ។

[96] ប្រការ ២៨នៃប្រកាសអន្តរក្រសួងដដែល ។

- គោលបំណងនៃពាក្យសុំចុះបញ្ជី បើនៅក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុនោះសំដៅលើកម្មសិទ្ធិ ទាំងមូល ឬ មួយផ្នែកក្នុងគោលបំណងក៏ត្រូវចែងអំពីការផ្ទេរកម្មសិទ្ធិទាំងមូល ឬ ការផ្ទេរកម្មសិទ្ធិមួយ ផ្នែកដែរ
- មូលហេតុនៃពាក្យសុំចុះបញ្ជី និង កាលបរិច្ឆេទសំដៅលើការកាលបរិច្ឆេទក្នុងការលក់ទិញ ឬ បរិច្ឆេទដែលកំណត់តាមកិច្ចសន្យា
- ឈ្មោះឬ នាមករណ៍ និង អាសយដ្ឋានរបស់បុគ្គលមានសិទ្ធិចុះបញ្ជី និង បុគ្គលមានកាតព្វកិច្ចចុះបញ្ជីគឺត្រូវបំពេញបន្ថែមលើថ្ងៃ ខែ ឆ្នាំកំណើត និង ទីកន្លែងកំណើតអាសយដ្ឋាននឹងឈ្មោះឪពុកម្តាយ
- ឈ្មោះឬ នាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ នៅពេលសាមីខ្លួនមិនមែនជាបុគ្គលមានសិទ្ធិចុះបញ្ជី និង បុគ្គលមានកាតព្វកិច្ចចុះបញ្ជីឈ្មោះរបស់អភិបាលតំណាងនីតិបុគ្គលនៅ ពេលបុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី គឺជានីតិបុគ្គលឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងក្នុងករណីការដាក់ពាក្យសុំចុះបញ្ជីត្រូវបានធ្វើឡើងដោយអ្នកតំណាង
- អត្តសញ្ញាណ នៃអចលនវត្ថុ ដោយបញ្ជាក់ទៅលើទីតាំងដី លេខក្បាលដី ឬលេខប័ណ្ណ។

បន្ទាប់ពីភាគីបានបំពេញនូវទម្រង់នៃការដាក់ពាក្យសុំចុះបញ្ជីរួចមកភាគីនៃកិច្ចសន្យាត្រូវយកទម្រង់នោះមកដាក់នៅមន្ទីរសុរិយោដី ដោយភ្ជាប់មកជាមួយនូវ **ឯកសារចាំបាច់** មួយចំនួនដូចជា៖

- ឯកសារដែលបញ្ជាក់អត្តសញ្ញាណរបស់បុគ្គលដែលបានដាក់ពាក្យសុំចុះបញ្ជី(ឧ.អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន សៀវភៅស្នាក់នៅ/សៀវភៅគ្រួសារសេចក្តីចម្លងសំបុត្រកំណើត)
- ឯកសារដែលបញ្ជាក់អំពីមូលហេតុនៃការចុះបញ្ជី (ឧ. កិច្ចសន្យាលក់ទិញ និង កាលបរិច្ឆេទ) សាលក្រម ឬ សាលដីកាដែលចូលជាស្ថាពរ (ករណីដែលការដាក់ពាក្យសុំធ្វើឡើងដោយបុគ្គលម្ខាងតែម្នាក់ឯង)
- ប័ណ្ណកម្មសិទ្ធិ និង ឯកសារពាក់ព័ន្ធផ្សេងៗទៀតដែលកំណត់ដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់។[97]

[97] ប្រការ ២៧ នៃប្រកាសអន្តរក្រសួង ស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណីចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣ ។

**គ. ចំណុចសំខាន់នៃពាក្យសុំ**

រដ្ឋបាលសុរិយោដី មានករណីយកិច្ចក្នុងការចុះបញ្ជីទៅតាមចំណុចដែលមាននៅក្នុងពាក្យសុំនៃការចុះបញ្ជីដែលភាគីនៃកិច្ចសន្យាបានដាក់ពាក្យសុំរួចរាល់ហើយ។ ហើយរដ្ឋបាលសុរិយោដីត្រូវចុះចំណុចទាំងនោះក្នុងសៀវភៅចុះបញ្ជី ដើម្បីបង្ហាញពីអត្ថិភាពនៃការចុះបញ្ជីដែលនៅក្នុងនោះរួមមានចំណុចដូចខាងក្រោម៖

- ឈ្មោះ ឬនាមករណ៍របស់បុគ្គលដែលមានសិទ្ធិចុះបញ្ជី រួមជាមួយថ្ងៃ ខែ ឆ្នាំ កំណើត និង ទីកន្លែង កំណើត អាសយដ្ឋាន និង ឈ្មោះឪពុកម្តាយ ។
- គោលបំណងនៃការចុះបញ្ជី
- មូលហេតុនៃការចុះបញ្ជី និង ការបរិច្ឆេទ
- លេខដែលបង្ហាញពីលំដាប់នៃការចុះបញ្ជី
- ចំពោះនីតិបុគ្គលគឺត្រូវបន្ថែមនៃការបរិច្ឆេទនៃការបង្កើត ។[98,99]

**ឃ.ការកែតម្រូវ និង ការលើកចោលពាក្យសុំចុះបញ្ជី**

សម្រាប់ពាក្យសុំនូវការចុះបញ្ជីត្រូវមានការត្រួតពិនិត្យដោយរដ្ឋបាលសុរិយោដី ក្នុងករណីដែលពាក្យសុំនោះមានចំណុចមិនគ្រប់គ្រាន់នោះទេ មិនអាចចុះបញ្ជីក្នុងសៀវភៅចុះបញ្ជីបានទេតែក្នុងករណីនេះរដ្ឋបាលសុរិយោដីក៏មិនអាចច្រានចោលពាក្យសុំនោះបានដែរ។ សម្រាប់ពាក្យសុំចុះបញ្ជីធ្វើឡើងដោយចំណុចខ្វះខាតដូចខាងក្រោម រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្តដែលមានសមត្ថកិច្ចចុះបញ្ជី ត្រូវបង្គាប់ឱ្យកែតម្រូវដោយកំណត់ពេលសមរម្យ ៖

- នៅពេលខ្វះខាតឯកសារចាំបាច់
- នៅពេលខ្លឹមសារនៅក្នុងពាក្យសុំ និងឯកសារភ្ជាប់មិនស្របគ្នា
- នៅពេលអត្តសញ្ញាណដែលមានកាតព្វកិច្ចក្នុងការចុះបញ្ជីមិនដូចគ្នានឹងសៀវភៅចុះបញ្ជី
- នៅពេលពុំបានបង់ពន្ធ ឬ សោហ៊ុយសេវាផ្សេងៗទាក់ទងនឹងការចុះបញ្ជី។[100]

ក្នុងករណីដែលបុគ្គលដាក់ពាក្យសុំចុះបញ្ជីមិនបានកែតម្រូវតាមការបង្គាប់ ដូចបានកំណត់ខាងលើនេះទេ រដ្ឋបាលសុរិយោដីនោះត្រូវលើកពាក្យចុះបញ្ជីនោះចោល ។[101]

---

[98] ប្រការ ១៤ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណីចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០១៣ ។

[99] « អំពីនីតិវិធីចុះបញ្ជីអចលវត្ថុ» រៀបរៀងដោយសាស្ត្រាចារ្យ Yoshie SASAKI / JICA Expert។

[100] ប្រការ ៩ កថាខណ្ឌទី១ នៃប្រកាសអន្តរក្រសួងដដែរ។

[101] ប្រការ ៩ កថាខណ្ឌទី២ នៃប្រកាសអន្តរក្រសួងដដែរ។

### ២.២.១.២. ការចូលរួមដោយអាជ្ញាធរមូលដ្ឋាន

អាជ្ញាធរមូលដ្ឋានរដ្ឋបាល ឃុំ សង្កាត់ អាចអនុវត្តតួនាទីភារៈកិច្ចរបស់ខ្លួនក្នុងការចុះបញ្ជីដីធ្លីបានតែក្នុងបរិបទដែលកំណត់ក្នុងប្រកាសអន្តរក្រសួងស្តីពីតួនាទីនិងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំសង្កាត់តែប៉ុណ្ណោះ។ តួនាទីនោះគឺបន្ទាប់ពីបានបំពេញពាក្យសុំចុះបញ្ជីរបស់បុគ្គលមានសិទ្ធិ និង បុគ្គលដែលមានកាតព្វកិច្ចរួចមក អាជ្ញាធរមូលដ្ឋានរួមមានអភិបាលស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ មានតួនាទីជាអ្នកបញ្ជាក់លើលិខិតសញ្ញាផ្សេងៗ ក្នុងនោះមានលិខិតលក់ផ្តាច់[102] ជាដើមដែលត្រូវយកចិត្តទុកដាក់ និង ទទួលខុសត្រូវទៅលើអត្តសញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា និង អត្តសញ្ញាណគូភាគីនៃកិច្ចសន្យា។ ការធ្វើបែបនេះដើម្បីត្រួតពិនិត្យនូវភាពស្របច្បាប់ ដើម្បីធ្វើការចុះហត្ថលេខា ស្នៀនចុះលេខ និងប្រថាប់ត្រាលើឯកសារទាំងនោះ បន្ទាប់ពីមានការបញ្ជាក់នៅក្នុងឃុំ សង្កាត់រួចមក មេឃុំ ចៅសង្កាត់ នឹងត្រូវយកលិខិតនោះទៅចុះក្នុងបញ្ជីមួយហៅថា«សៀវភៅចុះលិខិតបញ្ជាក់»។ នៅក្នុងសៀវភៅត្រូវចុះលេខរៀង និងកាលបរិច្ឆេទនៃប្រតិបត្តិការរួចស្រង់លេខរៀង និងថ្ងៃ ខែ ឆ្នាំ ដាក់លើលិខិតដើមគ្រប់លិខិតបញ្ជាក់ដែលត្រូវប្រគល់ទៅឱ្យភាគីម្នាក់ៗ បន្ទាប់មកត្រូវចុះថ្ងៃ ខែ ឆ្នាំនៃលិខិត ចុះឈ្មោះព្រមទាំងទីលំនៅនៃភាគី ចុះប្រភពនៃលិខិត និងចុះកម្មវត្ថុនៃលិខិត បើលិខិតនោះទាក់ទងនឹងអចលនវត្ថុ សេចក្តីនៃលិខិតត្រូវចម្លងចូលដោយសង្ខេបដាក់ក្នុងបញ្ជិកាមួយទៀត ហៅថា «បញ្ជិកានៃលិខិតបញ្ជាក់អចលនវត្ថុ»សម្រាប់ឃុំ-សង្កាត់នីមួយៗ ។ បើលិខិតបញ្ជាក់អចលនវត្ថុដោយអភិបាលស្រុក-ខណ្ឌត្រូវបញ្ជូនទៅមេឃុំ ចៅសង្កាត់ដែលអចលនវត្ថុនោះស្ថិតនៅ ដើម្បីមេឃុំ ចៅសង្កាត់ចុះសេចក្តីបញ្ជាក់ក្នុងសៀវភៅចុះលិខិតបញ្ជាក់អចលនវត្ថុថែមទៀត។[103] ចំពោះការអនុវត្តនៅឃុំ សង្កាត់ចំណាយពេលយ៉ាងយូរ៥ថ្ងៃប៉ុណ្ណោះ។

### ២.២.១.៣. ស្ថាប័នមានសមត្ថកិច្ចក្នុងការចុះបញ្ជីផ្ទេរកម្មសិទ្ធិ

ស្ថានប័នមានសមត្ថកិច្ចនៅក្នុងការចុះបញ្ជីក្តី និងនៅក្នុងការដាក់ពាក្យសុំក្តី គឺសំដៅទៅលើរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ឬ រដ្ឋបាលសូរយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលអចលនវត្ថុតាំងនៅ។ នៅពេលដែលពាក្យសុំត្រូវបានដាក់ទៅរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលជាស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី

---

102 និយមន័យ **លិខិតលក់ផ្តាច់** សំដៅឯកសារដែលមានសរសេរឈ្មោះ អត្តសញ្ញាណដីដែលជាកម្មវត្ថុនៃការចុះបញ្ជី និងចំណុចផ្សេងទៀតដែលត្រូវសរសេរចូលទៅក្នុងទម្រង់ជាក់លាក់មួយ ហើយអនុទាយី អនុទានិក សាក្សី២រូប ផ្តិតមេដៃ និងមេឃុំ ចៅសង្កាត់ ចុះហត្ថលេខា និងប្រថាប់ត្រផ្លូវការផងដែរចំពោះមុខការិយាល័យចុះបញ្ជី (ឯកសាររបស់ Yoshie SASAKI/JICA Expert)។

103 ប្រការ ៩ ថ្មី,១២,១៣ នៃប្រកាសអន្តរក្រសួងស្តីពីតួនាទីនិងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ-សង្កាត់ក្នុងការចុះបញ្ជីដីធ្លីចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៥ ។

សិទ្ធិប្រត្យក្សលើអចលនវត្ថុ ត្រូវចុះលេខរៀងទៅតាមលំដាប់នៃការទទួលពាក្យសុំ។[104] សៀវភៅទទួលពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលវត្ថុ។ ហើយរដ្ឋបាលសុរិយោដីទាំងនោះត្រូវបង្កើតសៀវភៅទទួលពាក្យសុំចុះបញ្ជី អំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ដាច់ដោយឡែកពីសៀវភៅទទួលពាក្យសុំផ្សេងៗទៀត។[105] តាមន័យនេះស្ថាប័នដែលមានសិទ្ធិចុះបញ្ជី គឺរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលអចលនវត្ថុនោះតាំងនៅ ។[106]

បន្ទាប់ពីប្រថាប់ត្រានៅឃុំ សង្កាត់រួចហើយ អ្នកលក់ ឬតំណាងរបស់អ្នកលក់ ត្រូវបន្តយកឯកសារនោះទៅការិយាល័យភូមិបាលវិញ ដើម្បីមន្ត្រី និង ប្រធានការិយាល័យអនុវត្តនីតិវិធីបន្ត។ មានន័យថាភាគីទាំងសងខាង ត្រូវអញ្ជើញមកការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ (ដែលជាទូទៅគេហៅថា ការិយាល័យភូមិបាល) ដែលអចលនទ្រព្យនោះស្ថិតនៅ ដើម្បីបំពេញឯកសារនានា នៅចំពោះមុខមន្ត្រីភូមិបាល ដោយមានសាក្សី២រូបមកជាមួយផងដែរ។

ភាគីទាំងសងខាង ត្រូវភ្ជាប់មកជាមួយនូវឯកសារចាំបាច់មួយចំនួនដូចបានបញ្ជាក់ខាងលើ។ បន្ទាប់មកមន្ត្រីភូមិបាលដែលជាមន្ត្រីជំនាញនឹងធ្វើការផ្ទៀងផ្ទាត់ឯកសារ និងព័ត៌មានខាងលើនេះទាំងអស់ និង ចាប់ផ្ដើមតាក់តែងរៀបចំលិខិតលក់ផ្ដាច់ ពាក្យសុំចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ និងតម្រូវឱ្យអ្នកលក់ អ្នកទិញ និង សាក្សី២រូបផ្តិតមេដៃលើឯកសារទាំងនេះ។ ចំពោះការអនុវត្ត ត្រង់ចំណុចនេះ មន្ត្រីភូមិបាល អាចរៀបចំតាក់តែងភ្លាមៗ រួចហើយឱ្យអ្នកលក់ អ្នកទិញ និង សាក្សី២រូប ផ្តិតមេដៃលើឯកសារទាំងនេះនៅចំពោះមុខគាត់ ដែលប្រើពេលប្រហែលកន្លះថ្ងៃ ឬទាក់ទងមកពួកគេនៅថ្ងៃបន្ទាប់ដើម្បីបញ្ចប់កិច្ច។[107]

បន្ទាប់មកមន្ត្រីភូមិបាល នឹងធ្វើការងារផ្ទេរសិទ្ធិអចលនទ្រព្យនោះ ដោយចុះទៅពិនិត្យទីតាំង ដើម្បីថតរូប វាស់វែងនិងគូរ សម្រាប់កសាងសាលកបត្រសម្រង់ជាក់ស្ដែង និងកសាងឯកសារណបផ្សេងៗទៀតដែលពាក់ព័ន្ធ ដែលនឹងត្រូវចុះហត្ថលេខាដោយមន្ត្រីវាស់វែង និង គូរព្រមទាំងចុះហត្ថលេខាដោយប្រធានការិយាល័យភូមិបាលបោះត្រា និង ចុះកាលបរិច្ឆេទផងដែរ។

នេះជាចំណុចបច្ចេកទេសដែលនឹងត្រូវចំណាយពេលខ្លះដើម្បីបញ្ចប់។ បន្ទាប់ពីការងារបច្ចេកទេសត្រូវបានបញ្ចប់ រួចរាល់មន្ត្រីរដ្ឋបាល ត្រូវធ្វើដីកាអមមួយដោយត្រូវស្នើប្រធានការិយាល័យភូមិបាលចុះហត្ថលេខា បោះត្រា ចុះ

[104] ប្រការ ៧ កថាខណ្ឌទី១ នៃប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណីចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០១៣ ។

[105] ប្រការ ៥ កថាខណ្ឌទី១ នៃប្រកាសអន្តរក្រសួងដដែល ។

[106] ប្រការ ៥ កថាខណ្ឌទី២ នៃប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណីចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០១៣ ។

[107] «នីតិវិធីនៃការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ»ផ្សព្វផ្សាយដោយសង្គមថ្មី ចុះថ្ងៃទី១២/១២/២០២១

លេខ និងចុះថ្ងៃខែឆ្នាំ ដើម្បីបញ្ជូនសំណុំរឿងនេះ ទៅច្រកចេញចូលតែមួយនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត (ឬហៅថា មន្ទីរសុរិយោដី)នៅពេលប្រធានមន្ទីរបានឯកភាព មន្ត្រីរដ្ឋបាលត្រូវរៀបចំធ្វើដីកាបញ្ជូនដើម្បីឱ្យប្រធានមន្ទីរចុះហត្ថលេខា ចុះលេខ ចុះថ្ងៃខែឆ្នាំ និងទាក់ទងមកម្ចាស់ ឬអ្នកតំណាងស្របច្បាប់យកសំណុំឯកសារទាំងអស់បន្តទៅ រដ្ឋបាលសារពើពន្ធដើម្បីបន្តនីតិវិធីបង់ពន្ធប្រថាប់ត្រា។[108]

### ២.២.១.៤. ការបង់ពន្ធប្រថាប់ត្រា

នៅពេលពិនិត្យឃើញថាគ្រប់នីតិវិធីនៃការចុះបញ្ជីមានភាពត្រឹមត្រូវរួចអស់ហើយ នោះមន្ត្រីខាងរដ្ឋបាលសុរិយោដីបានតម្រូវឱ្យមានការបង់ពន្ធទៅលើការផ្ទេរកម្មសិទ្ធិ ដែលអ្នកស្នើសុំបានធ្វើការស្នើសុំអំពីការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដែលជាកម្មវត្ថុនៅក្នុងការលក់ទិញ។ ពន្ធប្រថាប់ត្រាចំពោះការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ គឺជាពន្ធដែលត្រូវបង់នៅពេលមានការទិញ លក់ ឬដោះដូរ ឬធ្វើអំណោយអចលនទ្រព្យ ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន។[109] ចំណែកឯ អ្នកជាប់ពន្ធ សំដៅដល់បុគ្គលទាំងឡាយណាដែលមានកាតព្វកិច្ចត្រូវបង់ពន្ធ។[110]

អ្នកជាប់ពន្ធ ឬអ្នកតំណាងស្របច្បាប់ ត្រូវយកសំណុំឯកសារទាំងអស់បន្តទៅដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធប្រថាប់ត្រាលើអចលនវត្ថុ នៅអគ្គនាយកដ្ឋានពន្ធដារចំពោះអចលនវត្ថុដែលស្ថិតនៅរាជធានីខេត្ត ឬនៅសាខាពន្ធដារខេត្ត ដែលអចលនទ្រព្យនោះស្ថិតនៅ ឬបង់ប្រាក់ពន្ធនៅតាមធនាគារដៃគូរបស់អគ្គនាយកដ្ឋានពន្ធដារ។ ចំពោះអចលនវត្ថុនៅបណ្តាខេត្តក៏អាចស្នើសុំបង់ពន្ធនៅអគ្គនាយកដ្ឋានពន្ធដារបាន។ ការពិនិត្យលើសំណើសុំបង់ពន្ធប្រថាប់ត្រាលើអចលនទ្រព្យ មានរយៈពេល ៤ទៅ ៨ថ្ងៃ នៃថ្ងៃធ្វើការ ក្នុងករណីដែលអ្នកជាប់ពន្ធ ឬអ្នកតំណាងស្របច្បាប់បានភ្ជាប់ជាមួយនូវឯកសារគ្រប់គ្រាន់ និងត្រូវបង់សេវាសាធារណៈចំនួន ៤០០ ០០០ រៀល ចំពោះតែអចលនទ្រព្យដែលមានប្រាក់ពន្ធចាប់ពី ៤ ០០០ ០០០ រៀលឡើងទៅ។[111] ហើយចំពោះតម្លៃនៃពន្ធប្រថាប់ត្រាលើអចលនវិញ គឺត្រូវកំណត់តាមអត្រា៤%(បួនភាគរយ)នៃតម្លៃទៅតាម

---

108 «នីតិវិធីនៃការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ»ផ្សព្វផ្សាយដោយសង្គមថ្មី ចុះថ្ងៃទី១២/១២/២០២១

109 ប័ណ្ណផ្សព្វផ្សាយចេញដោយអគ្គនាយកដ្ឋានពន្ធដារ។

110 ប្រការ៣ នៃប្រកាសលេខ៧០១ សហវប្រក ស្តីពីការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធចុះថ្ងៃទី១៤ ខែ. សីហា ឆ្នាំ២០២០ ។

111 ឧបសម្ព័ន្ធភ្ជាប់ទៅនឹងប្រកាសលេខ១១៤៦ សហវ.ប្រក ស្តីពីការផ្តល់សេវាសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ ។

ប្រភេទនៃអចលនវត្ថុនោះ[112]។ ក្រោយពេលដែលអ្នកជាប់ពន្ធបានបង់ពន្ធរួចរាល់ហើយ នោះអ្នកជាប់ពន្ធនឹងទទួលបានបង្កាន់ដៃដែលបញ្ជាក់ពីការបង់ប្រាក់ពន្ធ ចំនួន២សន្លឹក ដល់មន្ត្រីប្រគល់សេចក្តីជូនដំណឹង និងឯកសារវិញ ដើម្បីបន្តនីតិវិធីប្រថាប់ត្រាលើឯកសារដែលបានស្នើសុំ។ មន្ត្រីប្រគល់សេចក្តីជូនដំណឹង និងសំណុំឯកសារ ធ្វើទំនាក់ទំនងទៅអ្នកជាប់ពន្ធ ដើម្បីមកទទួលយកសំណុំឯកសារដែលប្រថាប់ត្រារួច រួមនឹង "បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ" ពណ៌ផ្កាឈូក និង "លិខិតបញ្ជាក់អំពីការបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬកាន់កាប់អចលនទ្រព្យ" ដើម្បីទៅបន្តនីតិវិធីបញ្ចប់ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យនៅរដ្ឋបាលសុរិយោដីដើម្បីបង្គ្រប់នីតិវិធី ។

### ២.២.១.៥. ការប្រគល់ប័ណ្ណកម្មសិទ្ធិ

ការប្រគល់ប័ណ្ណកម្មសិទ្ធិគឺជាដំណាក់កាលចុងក្រោយក្នុងការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ដូច្នេះដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិ អ្នកជាប់ពន្ធ ឬ បុគ្គលដែលមានសិទ្ធិក្នុងការទទួលបានកម្មសិទ្ធិដែលចែងក្នុងកិច្ចសន្យាលក់ទិញនោះ ត្រូវយកឯកសារទាំងអស់ពីពន្ធដារ មកដាក់ចូលនៅមន្ទីរសុរិយោដីវិញ ដើម្បីឱ្យមន្ត្រីធ្វើបច្ចុប្បន្នភាពអំពីម្ចាស់ដីនៅក្នុងប្រព័ន្ធកុំព្យូទ័រ និង ធ្វើលេខាចារឹកលើប្លង់ដីចុះហត្ថលេខាសង្ខេបបោះត្រារាងពងក្រពើចុះកាលបរិច្ឆេទព្រមទាំងសរសេរក្នុង«សៀវភៅគល់បញ្ជីដី»។ ម្ចាស់កម្មសិទ្ធិនៃអចលនវត្ថុនឹងទទួលបាន៖

- ប្លង់កម្មសិទ្ធិដី ១ ច្បាប់ដើម
- លិខិតលក់ផ្តាច់ ១ ច្បាប់ដើម
- លិខិតបញ្ជាក់អំពីការបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬកាន់កាប់អចលនទ្រព្យ ១ ច្បាប់ដើម។

## ២.២.២. ការផ្ទេរសិទ្ធិលើចំណែកឯកជននៃអាគារសហកម្មសិទ្ធិ

ចប្ចុប្បន្ននៅក្នុងប្រទេសកម្ពុជាយើង មានការកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃអំពីការបង្កើតកិច្ចសន្យាលក់ទិញអាគារសហកម្មសិទ្ធិ ដែលយើងស្គាល់ថាជាផ្ទះក្នុងបុរី ឬ ខុនដូជាដើម។ ដូច្នេះការយល់ដឹងអំពីការផ្ទេរកម្មសិទ្ធិ (កាត់ឈ្មោះ)ពីអ្នកលក់ ឬ បុគ្គលអភិវឌ្ឍអចលនវត្ថុ ទៅកាន់អ្នកទិញគឺជារឿងសំខាន់សម្រាប់ប្រជាពលរដ្ឋក្នុងការយល់ដឹងដើម្បីជៀសវាងកើតមាននូវវិវាទនាពេលក្រោយ ។ នៅក្នុងការផ្ទេរកម្មសិទ្ធិលើអាគារសហកម្មសិទ្ធិដោយការលក់ទិញ ក្នុងគោលបំណងដើម្បីទទួលបាននូវវិញ្ញាបត្រសម្គាល់ចំណែកឯកជននៃអាគារសហកម្មសិទ្ធដែលអ្នកលក់បានធ្វើការបំបែកក្បាលដីនិងធ្វើការចុះបញ្ជីចំណែកឯកជននីមួយៗក្នុងសៀវភៅគោលបញ្ជីនៃអាគារសហកម្មសិទ្ធិរួចរាល់ហើយ មុននឹងធ្វើការលក់បន្តទៅឱ្យសហកម្មសិទ្ធិករថ្មី ។

[112] មាត្រា១១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។

ជាគោលការណ៍ការផ្ទេរកម្មសិទ្ធិលើចំណែកឯងជននៃអាគារសហកម្មសិទ្ធិ វាមិនមែនលក្ខណៈខុសគ្នាពេកទេជាមួយនឹង ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុទូទៅពិសេសគឺដីធ្លី ដោយសារអាគារសហកម្មសិទ្ធិក៏ជាប្រភេទមួយនៃអចលនវត្ថុដែរ ។ គ្រាន់តែទាក់ទងនឹងវិស័យអាគារសហកម្មសិទ្ធិនៅកម្ពុជាមានច្បាប់ចែងដាច់ដោយឡែក ដូច្នេះការអនុវត្ត ចំពោះនីតិវិធីមួយចំនួនត្រូវរួមបញ្ចូលដើម្បីឱ្យស្របតាមអនុឡោមនៃបទដ្ឋានគតិយុត្តទាំងនោះដែលរួមមាន ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអាគារសហកម្មសិទ្ធិដល់ជនបរទេស ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៥១០/០៦ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១០ និង អនុក្រឹត្យលេខ ១២៦ អនក្រ.បក ចុះថ្ងៃទី ១២ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អាគារសហកម្មសិទ្ធិ ដែលក្រោយមកបានធ្វើវិសោធនកម្មខ្លឹមសារមួយចំនួនដោយអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលមាត្រា១៦និងមាត្រា១៧នៃអនុក្រឹត្យលេខ១២៦អនក្រ.បកចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អាគារសហកម្មសិទ្ធិជាអាទិ៍ ។

ជាទូទៅការផ្ទេរសិទ្ធិលើចំណែក ឯកជនសហកម្មសិទ្ធិករឬអ្នកទទួលសិទ្ធិត្រូវស្នើធ្វើចរន្តការនៃការប្រែប្រួលនោះតាមរយៈការចុះបញ្ជីចំណែកឯកជននៃអាគារសហកម្មសិទ្ធិ។ ការចុះបញ្ជី ត្រូវធ្វើឡើងដោយស្ថាប័នមានសមត្ថកិច្ច ក្នុងការចុះបញ្ជី និងជាអ្នកចេញវិញ្ញាបនបត្រ គឺ ក្រសួងដែនដីនគរូបនីយកម្ម និង សំណង់ ដែលជាសមត្ថកិច្ចរបស់មន្ទីរសុរិយោដី ក្នុងការបំពេញមុខងារទូនាទីនេះ ។ ការចេញនេះតាមរយៈការ ដាក់ពាក្យស្នើសុំរបស់សហកម្មសិទ្ធិករឬអ្នកទទួលសិទ្ធិនិងត្រូវគោរពតាមនីតិវិធីដែលកំណត់ដោយច្បាប់ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដែលសំដៅទៅលើការបំពេញទម្រង់ពាក្យសុំចុះបញ្ជី និងឯកសារភ្ជាប់ទាក់ទងទៅនឹងអាគារសហកម្មសិទ្ធិនោះដែលឯកសារភ្ជប់នេះវាមានលក្ខណៈខុសគ្នាពីការផ្ទេរកម្មសិទ្ធិលើដីធ្លី ហើយអ្នកមានសិទ្ធិក្នុងការទទួលបានចំណែកឯកជននៃអាគារសហកម្មសិទ្ធិនោះត្រូវអនុវត្តនូវកាតព្វកិច្ចពន្ធដារផងដែរតាមរយៈការបង់ពន្ធប្រថាប់ត្រា គឺ **៤%**(បួនភាគរយ) នៃតម្លៃចំណែកឯកជនដែលត្រូវផ្ទេរសិទ្ធិនោះ ដែលជាការកំណត់តម្លៃដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ហើយដំណាក់កាលចុងក្រោយគឺដូចគ្នានឹងនីតិវិធីនៃការផ្ទេរកម្មសិទ្ធិលើដីធ្លីដែរ។

**<u>ចំណាំ</u>** ការចុះបញ្ជីផ្ទេរកម្មសិទ្ធិជាទូទៅទាំងអំពីការផ្ទេរកម្មសិទ្ធិ និងអំពីការផ្ទេរចំណែកកម្មសិទ្ធិអវិភាគសុទ្ធតែមានរបៀបនៃការចុះបញ្ជីនោះ ដើម្បីធានាពីភាពត្រឹមត្រូវតាមតម្រង់ច្បាប់ដូចបង្ហាញក្នុងឧបសម្ព័ន្ធ(ទី២ )។

**<u>សំគាល់</u>** ចំពោះ**ការផ្ទេរដីគ្មានប័ណ្ណកម្មសិទ្ធិ** ឬ ហៅថា**ប្លង់ទន់** គឺមិនមាននីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិនៅរដ្ឋបាលសុរិយោដីដូចដីដែលមានប័ណ្ណកម្មសិទ្ធិនោះទេ ដោយសារតែដីប្រភេទនេះមិនទាន់មានការចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីនៅឡើយទេ ដូច្នេះចំពោះការលក់ទិញអចលនវត្ថុប្រភេទនេះ ត្រូវបានធ្វើការផ្ទេរសិទ្ធិ

កាន់កាប់ត្រឹមតែអាជ្ញាធរមូលដ្ឋានដែលអចលនវត្ថុនោះតាំងនៅតែប៉ុណ្ណោះ។ ការផ្ទេរការកាន់កាប់អាចត្រូវបានផ្ទេរ ដោយការព្រមព្រៀងគ្នារវាងគូភាគីបើយោងតាមក្រមរដ្ឋប្បវេណីមាត្រា២២៩ កថាខណ្ឌទី២,៣,៤ ។

## ២.៣. ការរំលាយកិច្ចសន្យាលក់ទិញអចលនវត្ថុ

ការរំលាយកិច្ចសន្យា គឺជាការបញ្ចប់កិច្ចសន្យាមួយប្រភេទដែលក្នុងករណីណាភាគីណាម្ខាងនៃកិច្ចសន្យាមិនអនុវត្តកាតព្វកិច្ច ចំពោះកិច្ចសន្យាដែលព្រមព្រៀងគ្នាក្នុងការលក់ទិញអចលនវត្ថុ នោះភាគីម្ខាងទៀតអាចរំលាយកិច្ចសន្យាដោយឯកតោភាគីបាន ទោះបីជាមិនមានការយល់ព្រមពីភាគីម្ខាងទៀតក៏ដោយ ដែលធ្វើឱ្យមានអានុភាពជាឯកតោភាគី[113] (តែអាចធ្វើបានតែចំពោះកិច្ចសន្យាអញ្ញមញ្ញក្នុងករណីដែលភាគីម្ខាងទៀតបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ)[114]។ តាមន័យនេះយើងអាចកំណត់ពី **ការរំលាយកិច្ចសន្យា** ដែលជាការរំលត់កាតព្វកិច្ចរវាងភាគី នៃកិច្ចសន្យាទៅវិញទៅមក ។

ជាគោលការណ៍ ការរំលាយកិច្ចសន្យាគឺកើតចេញពីការមិនអនុវត្តកាតព្វកិច្ច។ ដូច្នេះ ភាគីណាម្ខាងនៃកិច្ចសន្យាដែលគិតថាខ្លួនមានការខូតប្រយោជន៍ ហើយមិនចង់រំលាយកិច្ចសន្យាដែលបានកើតឡើង នោះភាគីអាចទាមទារឱ្យភាគីម្ខាងទៀតអនុវត្តដោយបង្ខំ ឬអាចទាមទារសំណងនៃការខូចខាតបាន មុននឹងសម្រេចចិត្តរំលាយកិច្ចសន្យា។ដូច្នេះនៅក្នុងការរំលាយកិច្ចសន្យាត្រូវតែមានប្រភពច្បាស់លាស់ដែលច្បាប់អនុញ្ញាត (២.៣.១) ត្រូវមានលក្ខខណ្ឌដើម្បីអាចរំលាយបាន (២.៣.២) ហើយនៅពេលរំលាយនឹងបង្ហាញអំពីអានុភាពនៃការរំលាយនោះ(២.៣.៣)និងការរលត់នូវសិទ្ធិក្នុងការរំលាយដោយមានការកំណត់អំពីអាជ្ញាយុកាល(២.៣.៤) ។

### ២.៣.១. ប្រភពនៃការរំលាយកិច្ចសន្យា

ដើម្បីអាចរំលាយកិច្ចសន្យាបាន លុះត្រាតែមានលក្ខខណ្ឌច្បាស់លាស់ដែលច្បាប់អនុញ្ញាតឱ្យធ្វើការរំលាយបានដូចជាការមិនអនុវត្តកាតព្វកិច្ចដោយសារការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរនិង លក្ខខណ្ឌអាចរំលាយមួយទៀតដែលមិនមែនបណ្ដាលមកពីការមិនអនុវត្តកាតព្វកិច្ចនោះទេតែវាគឺជាការរំលាយដោយការបង្ហាញឆន្ទៈរំលាយ។ មានប្រភពមួយចំនួនសម្រាប់សិទ្ធិរំលាយកិច្ចសន្យារួមមាន៣(បី) គឺ សិទ្ធិរំលាយកិច្ចសន្យាតាមច្បាប់ (២.៣.១.១) សិទ្ធិរំលាយកិច្ចសន្យាតាម ការកំណត់ក្នុងកិច្ចសន្យា( ២.៣.១.២) និង សិទ្ធិរំលាយកិច្ចសន្យាតាមការព្រមព្រៀងរបស់ភាគី( ២.៣.១.៣) ។

---

[113] មាត្រា ៣១២ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧ ។

[114] មាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណីដដែរ។

**២.៣.១.១. សិទ្ធិរំលាយដែលបានកំណត់នៅក្នុងច្បាប់**

សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់នៅក្នុងច្បាប់ ត្រូវបានបញ្ញត្តិឡើងដោយមាត្រា ៤០៧ ដល់មាត្រា ៤១៣នៃក្រមរដ្ឋប្បវេណី។ សិទ្ធិរំលាយកិច្ចសន្យាតាមច្បាប់ អាចធ្វើទៅបានលុះត្រាតែកិច្ចសន្យានោះជាកិច្ចសន្យាអញ្ញមញ្ញ ហើយភាគីណាម្ខាងនៃកិច្ចសន្យានោះ មិនអនុវត្តកាតព្វកិច្ច ឬមិនអាចអនុវត្តកាតព្វកិច្ចបាន ឬបានរំលោភបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ។ ឧទាហរណ៍៖ **ក** បានបង្កើតកិច្ចសន្យាលក់ទិញអាគារសហកម្មសិទ្ធិ (ខុនដូរ)ជាមួយ **ខ** ដោយកំណត់ថ្ងៃប្រគល់សោរនៅថ្ងៃទី១១ ខែ ឧសភា ។ ប៉ុន្តែដោយសារថ្ងៃប្រគល់សោរ **ខ** មិនបានមកតាមការកំណត់ដូចក្នុងកិច្ចសន្យា រហូតដល់ថ្ងៃទី៣០ ខែ ឧសភា **ក** បានធ្វើការដាស់តឿន **ខ** ហើយ **ខ** នៅតែមិនអនុវត្តកាតព្វកិច្ចនោះ **ក** អាចលើកឡើងពីការរំលាយកិច្ចសន្យាបាន។

**២.៣.១.២. សិទ្ធិរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងកិច្ចសន្យា**

សិទ្ធិរំលាយដែលកំណត់ក្នុងកិច្ចសន្យា[115] គឺជាការផ្តល់ឱ្យភាគីម្ខាង ឬ ភាគីសងខាងនូវសិទ្ធិរំលាយ ទោះបីជាគ្មានការមិនអនុវត្តកាតព្វកិច្ចក៏ដោយ។ ក្នុងករណីនេះជាសិទ្ធិរបស់ភាគី ប្រសិនបើកិច្ចសន្យាបានចែងពី **លក្ខខណ្ឌក្នុងការរំលាយកិច្ចសន្យា** នោះភាគីនៃកិច្ចសន្យា ត្រូវគោរព និងអនុវត្តតាមកិច្ចសន្យា ។ ប្រសិនបើភាគីណាមួយមានបំណងចង់រំលាយកិច្ចសន្យា ភាគីនោះត្រូវធ្វើការបង្ហាញឆន្ទៈក្នុងការរំលាយកិច្ចសន្យានោះ ដោយអានុភាពនៃការរំលាយកិច្ចសន្យានេះនាំឱ្យភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា លើកលែងតែករណីយកិច្ចសំណងការខូចខាត (ប្រសិនបើការរំលាយកិច្ចសន្យានេះ នាំឱ្យខូចខាតផលប្រយោជន៍របស់ភាគីណាម្ខាង នោះភាគីប្រព្រឹត្តកំហុសត្រូវសងសំណងការខូចខាតដល់ភាគីរងគ្រោះនៃកិច្ចសន្យា) ។

**២.៣.១.៣. សិទ្ធិរំលាយកិច្ចសន្យាតាមការព្រមព្រៀងរបស់ភាគី**

សិទ្ធិរំលាយកិច្ចសន្យាតាមការព្រមព្រៀង ករណីនេះមានលក្ខណៈងាយស្រួលជាងគេ ព្រោះថា បើទោះបីជាគ្មានការកំណត់សិទ្ធិក្នុងការរំលាយក៏ដោយ ក៏ភាគីម្ខាងមានសិទ្ធិរំលាយបានដែរ ប្រសិនបើមានការព្រមព្រៀងរបស់ភាគីម្ខាងទៀតនៃកិច្ចសន្យានោះ ។ ប៉ុន្តែត្រង់ចំណុចនេះច្បាប់បានចែងការពារដល់ផលប្រយោជន៍របស់តតិយជនដោយមិនអនុញ្ញាតឱ្យការរំលាយកិច្ចសន្យានេះ ជាហេតុធ្វើឱ្យមានការខូចខាត ដល់ផលប្រយោជន៍របស់តតិយជនឡើយ ។[116]សរុបមក ការរំលាយកិច្ចសន្យាអាចធ្វើទៅបាន លុះត្រាតែ

---

[115] មាត្រា ៤១៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ។

[116] យល់ដឹងពីផ្នែកច្បាប់៖ **ការរំលាយកិច្ចសន្យា** (រៀបរៀងដោយ៖ លោកមេធាវី ថន យូសៀង និងកញ្ញា ថន រ៉ារ៉ាឌី ជាសមាជិកក្រុមការងាររៀបចំ និងផ្សព្វផ្សាយអត្ថបទច្បាប់ នៃក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ)ចុះថ្ងៃទី១៩ ខែ តុលា ឆ្នាំ ២០២០ ។

ភាគីម្ខាងមានការបំពានកិច្ចសន្យាធ្ងន់ធ្ងរពីសំណាក់ភាគីម្ខាងទៀតនៃកិច្ចសន្យា ឬ អាចធ្វើការរំលាយបានតាមរយៈកិច្ចសន្យារបស់ភាគី ឬ អាចធ្វើការរំលាយបានតាមការព្រមព្រៀងរបស់ភាគីនៃកិច្ចសន្យា ។

**២.៣.២ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ**

ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ សំដៅទៅលើករណីយកិច្ចដែលភាគីម្ខាងមិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យាបាន ដោយសារការបំពានរបស់ភាគីម្ខាងទៀតទោះបីជាមានការដាស់តឿនហើយក៏ដោយ។ ភាគីដែលបំពានកិច្ចសន្យា មិនអាចរារាំងការរំលាយកិច្ចសន្យាដោយផ្អែកលើបញ្ញត្តិ ខាងលើនេះ ដោយយកមូលហេតុថាខ្លួនគ្មានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនបានឡើយ ។[117]ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរកើតឡើងដោយសារអនុវត្តយឺតយ៉ាវជាមួយនឹងការដាស់តឿន (២.៣.២.១) អនុវត្តយឺតយ៉ាវចំពោះសកម្មភាពដែលមានកំណត់ពេលវេលា (២.៣.២.២) អលទ្ធភាពក្នុងការអនុវត្ត (២.៣.២.៣)ការបាត់បង់នូវទំនុកចិត្តរវាងគ្នា (២.៣.២.៤) ។[118]

**២.៣.២.១. អនុវត្តយឺតយ៉ាវជាមួយនឹងការដាស់តឿន**

យោងតាមមាត្រា ៤០៨ កថាខណ្ឌទី១ ចំណុច ក បញ្ញត្តិថាភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀតដែលមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ ដោយអំឡុងពេលសមរម្យដើម្បីឱ្យអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុងអំឡុងពេលនោះ។

មូលហេតុដែលចាត់ទុកថាជាការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចដោយសារ ៖

- ភាគីម្ខាងដែលចាត់ទុកថាជាកូនបំណុល មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមពេលកំណត់នៃកិច្ចសន្យា ដូចជាការមិនបង់ថ្លៃនៃអចលនវត្ថុដែលបានទិញក្នុងថ្ងៃកំណត់ដែលបញ្ជាក់ក្នុងកិច្ចសន្យា។
- ភាគីម្ខាងទៀតជាម្ចាស់បំណុលបានធ្វើការដាស់តឿនភាគីដែលមិនអនុវត្តកាតព្វកិច្ច ដោយកំណត់អំឡុងពេលសមរម្យ សម្រាប់អនុវត្ត។ ក្នុងករណីនេះបើភាគីជាកូនបំណុលមិនព្រមបង់ប្រាក់ទោះបីជាដល់ថ្ងៃកំណត់ក៏ដោយ ក៏អ្នកលក់ដែលជាម្ចាស់បំណុលត្រូវមានការដាស់តឿនជាមុន មុននឹងធ្វើការរំលាយកិច្ចសន្យានោះចោល ។
- ភាគីដែលជាកូនបំណុលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្នុងអំឡុងពេលសមរម្យ ដែលភាគីម្ខាងទៀតបានកំណត់ ដោយគិតថេរវេលាតាមកម្មវត្ថុនៃការលក់ទិញហើយភាគីនៅតែមិនព្រមអនុវត្តកាតព្វកិច្ច

[117] មាត្រា ៤០៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ។

[118] ការរំលាយកិច្ចសន្យា : ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ (ដោយសាស្ត្រាចារ្យ UMEMOTO Yumi

នោះទៀត ដូច្នេះភាគីអាចរំលាយកិច្ចសន្យានោះដោយសំអាងទៅលើភាពយឺតយ៉ាងក្នុងការអនុវត្ត កាតព្វកិច្ចរបស់ភាគីម្ខាងទៀតបាន។

### ២.៣.២.២. អនុវត្តយឺតយ៉ាវចំពោះសកម្មភាពដែលមានកំណត់ពេលវេលា

អនុវត្តយឺតយ៉ាវចំពោះសកម្មភាពដែលមានកំណត់ពេលវេលាសំដៅលើការរំលាយកិច្ចសន្យាដោយសារការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចក្នុងករណីដែលពេលវេលានោះគឺជាចំណុចសំខាន់ ។

នៅក្នុងករណីដែលគោលបំណងនៃកិច្ចសន្យាមិនបានសំរេច ប្រសិនបើការអនុវត្តកាតព្វកិច្ចមិនត្រូវបានបំពេញនៅក្នុងពេលកំណត់នោះ ត្រូវបានគេចាត់ទុកថាជា ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ ប្រសិនបើកូនបំណុលមិនបានបំពេញកាតព្វកិច្ចនៅពេលកំណត់នោះ ។[119] នៅក្នុងចំណុចនេះវា មានកិច្ចសន្យា ០២(ពីរ) ប្រភេទ [120]គឺ

**ប្រភេទទី១** គឺជាកិច្ចសន្យាដែលគោលបំណងរបស់វាមិនអាចសំរេចបានសោះតាមលក្ខណៈរបស់កិច្ចសន្យានោះ ប្រសិនបើការអនុវត្តកាតព្វកិច្ចមិនត្រូវបានធ្វើឡើងនៅក្នុងពេលកំណត់។ ឧទាហរណ៍ ៖ **ច** បានទិញដីមួយកន្លែងនៅជិតច្រាំងទន្លេពី **ឆ** ដោយសារ **ច** ត្រូវការកន្លែងនោះដើម្បីឱ្យក្រុមហ៊ុនរោងចក្រមកពីជប៉ុនមានទីតាំងសម្រាប់ដាក់សម្ភារៈផ្សេងៗសម្រាប់សាងសង ដែលការកំណត់មកដល់ នៅថ្ងៃ ៣ខែមិថុនា ឆ្នាំ ២០២២ ។ **ច** និង **ឆ** បានបង្កើតកិច្ចសន្យាលក់ទិញឡើងដោយសំអាងថា ដីនៅតំបន់នោះមានសុវត្ថិភាពល្អ អាចយកធ្វើអ្វីក៏បានលុះដល់ថ្ងៃកំណត់ដីនោះបានស្រុតធ្វើឱ្យប្រើការមិនកើត។ ក្នុងករណីនេះ **ច** ក៏អាចរំលាយកិច្ចសន្យាដោយសារ **ឆ** បានបំពានកិច្ចសន្យាធ្ងន់ធ្ងរ ។

**ប្រភេទទី២** គឺជាកិច្ចសន្យាដែលត្រូវអនុវត្តកាតព្វកិច្ចនៅក្នុងពេលកំណត់ដោយស្របទៅតាមឆន្ទៈរបស់ភាគី ។ ឧទាហរណ៍៖ **ក** បានបង្កើតកិច្ចសន្យាលក់ទិញផ្ទះពី **ខ** ក្នុងគោលបំណងជាអំណោយក្នុងថ្ងៃអាពាហ៍ពិពាហ៍ដល់កូនស្រីខ្លួន នៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០២២។ ដោយ **ខ** បានប្រាប់ **ក** ថាផ្ទះដែលខ្លួនបានលក់ទៅឱ្យនោះសាងសងរួចរាល់ហើយ ប៉ុន្តែនៅមុនពេលកំណត់មួយថ្ងៃ **ក** បានទៅមើល ហើយឃើញផ្ទះនោះមិនទាន់សាងសងរួចរាល់នៅឡើយទេ។ ដូច្នេះគោលបំណងមិនបានសម្រេច ធ្វើឱ្យ **ក** មានសិទ្ធិលុបចោលកិច្ចសន្យាជាមួយ **ខ** បាន ។

---

[119] មាត្រា ៤០៧ កថាខណ្ឌទី១ ចំណុច ខ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ។

[120] សៀវភៅក្រមរដ្ឋប្បវេណីភាគទី៣ ជំពូក១ ផ្នែកទី៥,ទំព័រ៤១ របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA)បោះពុម្ពលើកទី១ ក្នុងខែ មីនា ឆ្នាំ ២០១២។

**២.៣.២.៣. អលទ្ធភាពនៃការអនុវត្តកាតព្វកិច្ច**

អលទ្ធភាពនៃការអនុវត្តកាតព្វកិច្ច សំដៅលើភាគីដែលមិនអាចអនុវត្តតាវកាលិកចម្បងរបស់ខ្លួនបានទេ[121]តាវកាលិកចម្បងគឺជាសកម្មភាពដែលភាគីមិនអាចសម្រេចគោលបំណងនៃកិច្ចសន្យាប្រសិនបើតាវកាលិកមិនត្រូវបានផ្តល់ឱ្យ។ លើសពីនេះតាវកាលិកចម្បងត្រូវសម្រេចដោយផ្អែកលើលក្ខណៈ ឬ ខ្លឹមសារ នៃកិច្ចសន្យា និងឆន្ទៈរបស់ភាគី។ ជាក់ស្តែងដូចជាការទិញលក់ ផ្ទះ អ្នកទិញបានប្រគល់ប្រាក់ថ្លៃលក់ឱ្យអ្នកលក់ តែអ្នកលក់គ្មានលទ្ធភាពក្នុងការប្រគល់សោរ និងផ្ទេរកម្មសិទ្ធិឱ្យអ្នកទិញដោយសារផ្ទះនោះជាទ្រព្យរួមរបស់ប្តីប្រពន្ធ ហើយការបង្កើតកិច្ចសន្យានោះត្រូវបានបដិសេធដោយសហព័ទ្ធណាម្ខាង។ ក្នុងករណីនេះប្រសិនជាអ្នកលក់បានប្រគល់ និង ផ្ទេរកម្មសិទ្ធិឱ្យហើយតែអ្នកលក់គ្មានលទ្ធភាពចំពោះកាតព្វកិច្ចបន្ទាប់បន្សំនោះអ្នកទិញមិនអាចរំលាយកិច្ចសន្យានោះបានទេ។

**២.៣.២.៤. ការបាត់បង់នូវទំនុកចិត្តរវាងគ្នា**

ការបំពានកិច្ចសន្យាមានភាពហួសហេតុដែលធ្វើឱ្យបាត់បង់នូវទំនុកចិត្តរវាងគូភាគីហើយមិនជឿជាក់ថានឹងអនុវត្តកាតព្វកិច្ចនាអនាគតបាន។[122]

ពាក្យថាហួសហេតុក្នុងន័យនេះគឺសំដៅទៅលើសកម្មភាព ឬ ជាមូលហេតុណាមួយដែលភាគីម្ខាងទៀតមិនអាចទទួលយកបានដោយសារប្រាស់ចាក់ពីកិច្ចសន្យា ឬ កេញចំណេញលើខ្លឹមសារនៃកិច្ចសន្យា។ ដូច្នេះការរំលាយកិច្ចសន្យាប្រភេទនេះគឺវាមានភាពមិនច្បាស់លាស់ដោយសារវាអាស្រ័យទៅលើទំនុកចិត្តរបស់ភាគីដែលពិបាកស្មានដឹង ។

**២.៣.៣. ការបង្ហាញឆន្ទៈរំលាយ**

ប្រសិនបើសិទ្ធិរំលាយកើតឡើង ចំពោះភាគីម្ខាងនៃកិច្ចសន្យាសិទ្ធិនោះមានអានុភាពនៅពេលដែលភាគីនោះបង្ហាញឆន្ទៈរំលាយកិច្ចសន្យាទៅឱ្យភាគីម្ខាងទៀត។[123]ជាគោលការណ៍ការរំលាយកិច្ចសន្យាគឺជាសកម្មភាពក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ បានអនុញ្ញាតឱ្យការរំលាយកិច្ចសន្យាតាមរយៈការបង្ហាញឆន្ទៈ អាចធ្វើនៅក្រៅប្រព័ន្ធតុលាការបាន ក្នុងគោលបំណងបង្កនូវលក្ខណៈងាយស្រួលដល់គូភាគីក្នុងការរំលាយកិច្ចសន្យា ចំពោះការបំពានកិច្ចសន្យា។ ការបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀត ធ្វើឡើងដោយផ្ទាល់មាត់ក៏បាន ជាលិខិតក៏

[121] មាត្រា ៤០៧ កថាខណ្ឌទី១ ចំណុច គ នៃក្រមរដ្ឋប្បវេណីដដែល ។

[122] មាត្រា ៤០៧ កថាខណ្ឌទី១ ចំណុច ឃ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ។

[123] សៀវភៅនីតិកាតព្វកិច្ច រៀបរៀងដោយសាស្ត្រាចារ្យ មេធាវី ហេង បូរ៉ា ឆ្នាំសិក្សា២០២០-២០២១,ទំព័រទី១១៣។

បាន ជាអ៊ីម៉ែលក៏បាន។[124] វិវាទអាចដោះស្រាយដោយផ្អែកតាមការរំលាយនៅក្រៅតុលាការ ប្រសិនបើគ្មានបំណងថានឹងមានវិវាទតទៅទៀតជាមួយភាគីម្ខាងទៀតនោះទេ ។

ដូច្នេះនៅពេលកិច្ចសន្យាត្រូវបានរំលាយ តើភាគីនៃកិច្ចសន្យាមានសិទ្ធិបែបណាហើយក្នុងករណីដែលការរំលាយនោះពាក់ព័ន្ធនឹងតតិយជនតើតតិយជននោះមានសិទ្ធិយ៉ាងដូចម្តេច?

### ២.៣.៤. អានុភាពនៃការរំលាយកិច្ចសន្យា

ចំពោះអចលនវត្ថុ ក្នុងករណីនេះបើភាគីបានទទួលតាវកាលិកផ្សេងទៀតចំនួន មួយភាគ ឬ ទាំងអស់ នោះភាគីអ្នកទទួលត្រូវធ្វើបដិទានទៅភាគីម្ខាងទៀតវិញនៅពេលរំលាយកិច្ចសន្យា ចំពោះករណីយកិច្ចនោះជាអចលនវត្ថុ នោះភាគីត្រូវបង្វិលសងទៅភាគីម្ខាងទៀតវិញរួមទាំងផលដែលទទួលបានពីអចលនវត្ថុនោះ។ បន្ថែមលើនេះផ្អែកតាមមាត្រា ៤១១ នៃក្រមរដ្ឋប្បវេណីនៅពេលកិច្ចសន្យាត្រូវបានរំលាយនាំឱ្យបង្កើតនូវអានុភាពគតិយុត្ត ដូចខាងក្រោម៖

**ការរួចផុតពីកាតព្វកិច្ច៖**ភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យាលើកលែងតែករណីយកិច្ចសងការខូចខាត។

**កាតព្វកិច្ចបដិទាន៖** ភាគីដែលបានទទួលតាវកាលិកនៃកិច្ចសន្យាតែមួយភាគឬទាំងអស់ ត្រូវមានករណីយកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀត ដើម្បីឱ្យភាគីម្ខាងទៀតទទួលបដិទាន និងប្រសិនបើភាគីទាំងសងខាងមានករណីយកិច្ចធ្វើបដិទានទៅវិញទៅមកករណីយកិច្ចទាំងនោះ ត្រូវអនុវត្តនៅពេលជាមួយគ្នា។

**ការសងការប្រាក់៖** ភាគីដែលមានករណីយកិច្ចសងជាប្រាក់ដោយការរំលាយត្រូវសងជាមួយនឹងការប្រាក់ដោយគិតចាប់ពីថ្ងៃដែលបានទទួលប្រាក់ដើម ភាគីដែលមានករណីយកិច្ចបង្វិលវត្ថុ ឬ តាវកាលិកផ្សេងដែលខ្លួនបានទទួលពីភាគីម្ខាងទៀតដោយការរំលាយ ត្រូវសងទាំងផលដែលបានទទួលពីវត្ថុ ឬ តាវកាលិកនោះ។ ការរំលាយកិច្ចសន្យាធ្វើឱ្យភាគីរួចផុតពីកាតព្វកិច្ច លើកលែងតែករណីយកិច្ចសងការខូចខាត។

ក្នុងករណីមានការពាក់ព័ន្ធជាមួយតតិយជនដែលជាជនសុចរិត ការរំលាយកិច្ចសន្យានោះអាចធ្វើទៅបាន ប៉ុន្តែមិនអាចធ្វើឱ្យខូចប្រយោជន៍ត្រឹមត្រូវរបស់តតិយជន បានឡើយ។[125]

### ២.៣.៥. អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យា

អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យា ដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច និងសិទ្ធិទាមទារឱ្យស្តារឡើងវិញនូវស្ថានភាពដើម ឬ ការប្រគល់ត្រឡប់ មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ក្រោយពីពេលដែលមានការមិនបានអនុវត្តកាតព្វកិច្ច នេះមានន័យថាបើផុតអំឡុងពេល ៥ (ប្រាំ) ឆ្នាំ នេះហើយភាគីដែលមាន

---

[124] ការរំលាយកិច្ចសន្យា : ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ (ដោយសាស្ត្រាចារ្យ UMEMOTO Yumi)

[125] មាត្រា ៤១១ កថាខណ្ឌទី៤ ចំណុច គ នៃក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ។

សិទ្ធិរំលាយលែងមានសិទ្ធិអនុវត្តសិទ្ធិរបស់ខ្លួនទៀតឡើយ។[126] ចំពោះសិទ្ធិទាមទារឱ្យអនុវត្ត គឺ ៥ (ប្រាំ) ឆ្នាំគិតចាប់ពីពេលដែលអាចអនុវត្តសិទ្ធបាន ។ ហើយសិទ្ធិទាមទារសំណងនៃការខូចខាត គឺមានរយៈពេល ៥ (ប្រាំ) ឆ្នាំគិតចាប់ពីពេលដែលការខូតខាតបានកើតឡើង។ ក្នុងករណីដែលនោះកន្លងហួសទៅនោះសិទ្ធិរំលាយកិច្ចសន្យាត្រូវបានរំលត់៕

[126] មាត្រា ៤១៣ នៃក្រមរដ្ឋប្បវេណីដដែរ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

អត្ថបទដែលបានសរសេរចង់ក្រងតាមរយៈសារណានេះ ជុំវិញកិច្ចសន្យាលក់ទិញអចលនវត្ថុនៅកម្ពុជា បានបង្ហាញពីទិដ្ឋភាពច្បាប់ដែលត្រូវអនុវត្តលើការលក់ទិញអចលនវត្ថុសម្រាប់ប្រជាពលរដ្ឋខ្មែរទូទៅ។ ជាទូទៅ ទម្រង់នៃការចុះកិច្ចសន្យាលក់ទិញអចលនវត្ថុដូចជាដី ផ្ទះ អាគារសហកម្មសិទ្ធិរួមមាន បុរី ខុនដូ សំណង់អាគារផ្សេងៗ ជាសំខាន់គឺកិច្ចសន្យានោះបានគោរពទៅតាមលក្ខខណ្ឌសុពលភាពដែលបានកំណត់ដោយច្បាប់ឬអត់ ហើយភាគីទាំងសងខាងបានអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនបានត្រឹមត្រូវស្របនឹងច្បាប់ដែរឬទេ ។

ជាការពិតកិច្ចសន្យាលក់ទិញអចលនវត្ថុ ដែលគូភាគីបានបំពេញមានសុពលភាព ហើយអាចអះអាងជាមួយតតិយជនបានជាកិច្ចសន្យាកើតឡើងតាមរយៈការបង្ហាញឆន្ទៈដោយសេរីរបស់ភាគីដែលមានសិទ្ធិក្នុងការចុះកិច្ចសន្យាទៅលើកម្មវត្ថុណាមួយ ដែលភាគីបានសម្តែងឆន្ទៈរួមគ្នាដើម្បីស្របតាមគោលបំណងដែលទទួលបានមកវិញនូវផលប្រយោជន៍ទៅវិញទៅមក។ ផលប្រយោជន៍ដែលភាគីទាំងសងខាងទទួលបានត្រូវមានភាពសុចរិត និងភាពស្មោះត្រង់ដោយស្របតាមគោលការណ៍នៃក្រមរដ្ឋប្បវេណី ដូច្នេះគូភាគីនៃកិច្ចសន្យាដែលជាអ្នកលក់ និងអ្នកទិញ ក៏ត្រូវបំពេញនូវករណីយកិច្ចសំខាន់ៗមួយចំនួនរួមមាន ៖ករណីយកិច្ចត្រូវពន្យល់ ឬការផ្តល់ព័ត៌មាន ករណីយកិច្ចប្រគល់អចលនវត្ថុ ករណីយកិច្ចក្នុងការផ្ទេរសិទ្ធិ ករណីយកិច្ចបង់ថ្លៃទិញ ករណីយកិច្ចទទួលវត្ថុដែលបានទិញជាអាទិ៍ និងទទួលបានសិទ្ធិមួយចំនួនរួមមាន ៖ សិទ្ធិទាមទារឱ្យប្រគល់ថ្លៃទិញអចលនវត្ថុ សិទ្ធិជួសជុល សិទ្ធិទាមទារឱ្យអនុវត្តពេញលេញ សិទ្ធិទទួលផលជាអាទិ៍។ ហើយនៅក្នុងប្រតិបត្តិការលក់ទិញអចលនវត្ថុនេះភាគីទាំងសងត្រូវបង្កើតកិច្ចសន្យាទាំងមូលដោយធ្វើទៅតាមទម្រង់លិខិតយថាភូត ដើម្បីឱ្យកិច្ចសន្យាមានអានុភាពរហូតដល់នីតិវិធីផ្ទេរកម្មសិទ្ធិ ព្រោះថាការលក់ទិញអចលនវត្ថុជាគោលបំណងគឺដើម្បីផ្ទេរសិទ្ធិកម្មសិទ្ធិករនៃទ្រព្យ ដែលត្រូវធ្វើឡើងតាមទម្រង់បែបបទដែលដាក់ឱ្យប្រើដោយក្រសួងសុរិយោដីដែលគេហៅថា លិខិតលក់ផ្តាច់ និង ការចុះបញ្ជីផ្ទេរកម្មសិទ្ធិ (ចុះហត្ថលេខា/ផ្តិតស្នាមមេដៃ ដោយគូភាគីទាំងសងខាង) ចំពោះមុខមន្ត្រីមូលដ្ឋានតាមរយៈការដឹងឮពីអាជ្ញាធរមូលដ្ឋានថ្នាក់ ស្រុក /ខ័ណ្ឌ ឬ សារការី និងដោយមន្ត្រីសុរិយោដី។ ព្រមទាំងការបង់ពន្ធប្រថាប់ត្រា៤% នៃតម្លៃអចលនទ្រព្យសរុប និង ការទទួលបានប័ណ្ណកម្មសិទ្ធិក្នុងឈ្មោះអ្នកទិញជាដើម ។ ដូច្នេះនៅចុងបញ្ចប់អានុភាពនៃកិច្ចសន្យាលក់ទិញអចលនវត្ថុត្រូវបានបញ្ចប់នៅពេលដែលមានការផ្ទេរកម្មសិទ្ធិហើយបានស្ថាពរ ឬ អាចបញ្ចប់ដោយការរំលាយកិច្ចសន្យាដោយសារការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ឬ ក៏មានការបង្ហាញឆន្ទៈរំលាយដោយភាគីជាដើម។

ជាក់ស្តែងបើទោះបីជាច្បាប់បានកំណត់ជាក់លាក់ទៅតាមមួយដំណាក់កាលម្តងៗ យ៉ាងណាក្តីក៏ការអនុវត្តនៅតែមានចំណុចខ្វះខាតនៅឡើយ ដែលនោះបណ្តាលមកពីការមិនយល់ដឹងនូវច្បាប់ទាក់ទងទៅនឹងកិច្ចសន្យាដែលភាគីអ្នកលក់ និង អ្នកទិញបានចុះហត្ថលេខាលើកិច្ចសន្យាលក់ទិញនោះដោយសារមានការធ្វេសប្រហែស ដោយសារភាគីមិនយល់ពីគ្នាធ្វើឱ្យកិច្ចសន្យាកើតមាននូវវិការៈ និង មួយវិញទៀតការលក់ទិញអចលន

វត្ថុភាគច្រើនមិនបានធ្វើតាមលក្ខខណ្ឌទម្រង់ច្បាស់លាស់ទេ ដូច្នេះវាជាលំបាកក្នុងការតវ៉ានៅពេលមានវិវាទកើតឡើង។ ហើយបញ្ហាមួយទៀតគឺដីធ្លីរបស់ប្រជាពលរដ្ឋដែលមិនទាន់មានប័ណ្ណកម្មសិទ្ធិនៅឡើយធ្វើឱ្យការផ្ទេរកម្មសិទ្ធិមានភាពស្មុគស្មាញជាងច្បាប់ ។ ដោយមើលឃើញនូវចំណុចខ្វះខាតក្នុងការអនុវត្តសកម្មភាពទាំងអស់នេះហើយ ទើបយើងព្យាយាមកែតម្រូវតាមរយៈការក្នុងការប្រមូលរាល់លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលមានការពាក់ព័ន្ធមកប្រមូលផ្ដុំគ្នា រួមជាមួយការពន្យល់បកស្រាយតាមគោលបំណងរបស់ច្បាប់យ៉ាងច្បាស់លាស់ ទៅលើការលក់ទិញអចលនវត្ថុ។ ជាគោលការណ៍ធ្វើឡើងក្នុងគោលបំណងផ្សព្វផ្សាយឱ្យមានភាពទូលំទូលាយ ក្នុងការធ្វើទំនាក់ទំនងលើវិស័យជំនួយអចលវត្ថុ ហើយអាចការពារនៅពេលដែលកើតមានឡើងនូវសកម្មភាពអយុត្តិធម៌ និងការរំលោភបំពានលើសិទ្ធិដីធ្លី ក៏ដូចជាទ្រព្យសម្បត្តិជាអចលនវត្ថុទាំងឡាយរបស់ប្រជាពលរដ្ឋដែលមានការកាន់កាប់ដោយស្របច្បាប់ទោះបីជាមានប័ណ្ណកម្មសិទ្ធិក្ដី (ប្លង់រឹង) និង គ្មានក្ដី (ប្លង់ទន់) ។ ដូចនេះប្រសិនបើក្នុងករណីដែលកិច្ចសន្យាបានកើតឡើងហើយ តែកិច្ចសន្យានោះធ្វើឱ្យខាតប្រយោជន៍ដល់ភាគីណាម្ខាង នោះភាគីណាម្ខាងអាចដាក់ពាក្យសុំទៅកាន់សមត្ថកិច្ចចំនួនប្រាំដែលមានយន្តការដោះស្រាយទំនាស់ដីធ្លីនៅកម្ពុជារួមមាន៖ ១.ក្រុមប្រឹក្សាឃុំសង្កាត់ ២.គណៈកម្មការសុរិយោដី ៣.គណៈកម្មការរដ្ឋបាល ៤.អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និង ៥. ដំណោះស្រាយដោយប្រព័ន្ធតុលាការ។

ទន្ទឹមនឹងការបកស្រាយខាងលើនេះ យើងខ្ញុំសង្ឃឹមថាខ្លឹមសារអំពីរបបគតិយុត្តនៃកិច្ចសន្យាលក់ទិញអចលនវត្ថុទាំងមូលនេះនឹងមានតម្លៃ ហើយអាចយកធ្វើជាគតិសម្រាប់ត្រិះរិះពិចារណាក្នុងការធ្វើអាជីវកម្មក្ដី ឬបម្រើឱ្យជីវភាពរស់នៅក្ដី ដែលជាប្រយោជន៍មួយទៅតាមការរីកចម្រើនលើវិស័យលក់ទិញអចលនវត្ថុនៅកម្ពុជា។ ពិសេសសំដៅដល់ប្រជាពលរដ្ឋខ្មែរទូទៅដែលគួរតែស្វែងយល់ទៅលើសិទ្ធិ និង ករណីយកិច្ចរបស់ខ្លួនឱ្យបានច្បាស់មុននឹងភ្ជាប់ចំណងគតិយុត្តទៅលើកិច្ចសន្យា ព្រោះថានៅក្នុងកិច្ចសន្យាលក់ទិញអចលនវត្ថុទំនាស់គឺកើតចេញពីការមិនគោរពសិទ្ធិ និង ករណីយកិច្ចនេះគឺនៅពេលការយល់ដឹងរបស់គូភាគីបានច្បាស់លាស់ហើយការអនុវត្តតាមឆន្ទៈពិតប្រាកដនិងត្រឹមត្រូវនោះនឹងឈានទៅរកផលប្រយោជន៍នៃទំនាក់ទំនងដ៏មានប្រសិទ្ធិភាព ភាពគ្មានទំនាស់ និង ដំណោះស្រាយប្រកបដោយភាពយុត្តិធម៌ផងដែរ៕

# អនុសាសន៍

# អនុសាសន៍

ជាការពិតកិច្ចសន្យាទិញលក់អចលនវត្ថុក្នុងពេលបច្ចុប្បន្នការយល់ពីគ្នាអំពីសិទ្ធិនិងករណីយកិច្ចរវាងគូភាគីជាម្ចាស់អចលនវត្ថុ និង អ្នកទិញគឺជារឿងសំខាន់ដែលនាំឱ្យកិច្ចសន្យាតាមទម្រង់ជាលិខិតយថាភូតមួយនេះមានប្រសិទ្ធភាព និង គ្មានទំនាស់ហើយអាចជួយធានានូវសន្តិសុខទាំងភាគីអ្នកទិញ និង ភាគីអ្នកលក់សម្រាប់ជាភស្តុតាងនៅពេលមានជម្លោះណាមួយកើតឡើងជាយថាហេតុ។ ប៉ុន្តែភាគីជាអ្នកលក់ឬជាម្ចាស់អចលនវត្ថុ និង អ្នកទិញក៏ត្រូវមានការប្រុងប្រយ័ត្នដោយខ្លួនឯង ដើម្បីជៀសវាងពីការលក់ទិញដោយបំពានព្រោះភាគីអ្នកលក់ ឬ អ្នកទិញមួយចំនួននូវតែប្រើសិទ្ធិបំពានទៅលើគូភាគីរបស់ខ្លួនក្នុងរូបភាពជាការលក់ទិញដីដែលមានវិវាទដីដែលជាកម្មសិទ្ធិរបស់រដ្ឋការលក់ដោយប្រើប័ណ្ណកម្មសិទ្ធិក្លែងក្លាយ និងការឆបោកទៅលើប្រាក់កក់ទៅលើគម្រោងអភិវឌ្ឍន៍ដែលទាមទារឱ្យបង់ប្រាក់មុនជាដើម។ ម្យ៉ាងទៀតបញ្ហានានាក៏អាចកើតមានបានដែលក្នុងករណីភាគីដែលបានចុះកិច្ចសន្យាគឺរវាងម្ចាស់អចលនវត្ថុ និង អ្នកទិញមិនយល់ពីគ្នាទៅវិញទៅមក តែងតែប្រើសិទ្ធិនិងករណីយកិច្ចហួសព្រំដែនដែលច្បាប់បានកំណត់ដែលធ្វើឱ្យភាគីណាម្ខាងមានការខាតបង់នូវប្រយោជន៍។ ដូចនេះរាល់បញ្ហាដែលកើតឡើងខាងលើនេះសុទ្ធតែជាចំណុចវិវាទដែលជាមូលហេតុនាំឱ្យភាគីនៃកិច្ចសន្យាអាចតតាំងគ្នាទៅតាមនីតិវិធីផ្លូវច្បាប់ដើម្បីស្វែងរកដំណោះស្រាយ។

ក្រៅពីភាគីនៃកិច្ចសន្យាការចូលរួមពីសំណាក់រដ្ឋាភិបាលនិងមន្ត្រីមានសមត្ថកិច្ចក៏ជាកត្តាមួយដ៏សំខាន់នៅក្នុងដំណើរការនៃការលក់ទិញអចលនវត្ថុរបស់ប្រជាពលរដ្ឋដោយកាន់តែមាននូវតម្លាភាព តាមរយៈតួនាទីក្នុងការបណ្តុះបណ្តាលប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ឬ ក៏ប្រើប្រាស់នូវប្រព័ន្ធផ្សព្វផ្សាយនានាដើម្បីឱ្យប្រជាពលរដ្ឋអាចស្វែងយល់ដោយខ្លួនឯងបានព្រោះកាលណាប្រជាពលរដ្ឋមានចំណេះដឹង និង ការស្វែងយល់ទៅលើកិច្ចសន្យាលក់ទិញអចលនវត្ថុបានច្បាស់លាស់ហើយមានន័យថាមានសមត្ថភាពក្នុងការកំណត់លក្ខខណ្ឌសុពលភាពទៅលើកិច្ចសន្យាដឹងអំពីអនុវត្តកិច្ចសន្យាដែលមានអានុភាពហើយកម្រមានការរំលោភបំពាន និងមានវិវាទណាស់។ បន្ថែមពីលើនេះពាក់ព័ន្ធអាជ្ញាធរថ្នាក់ក្រោមជាតិដែលរដ្ឋាភិបាលបានប្រគល់តួនាទីភារៈកិច្ចឱ្យអនុវត្តក្នុងការផ្ទេរកម្មសិទ្ធិត្រូវចុះស៊ើបអង្កេត និង ស្រាវជ្រាវឱ្យច្បាស់លាស់ពីប្រវត្តិអចលនវត្ថុដោយសារមានប្រជាពលរដ្ឋខ្មែរមួយភាគធំបង្កើតកិច្ចសន្យាលក់ទិញដីធ្លីហើយមិនទាន់មានប័ណ្ណកម្មសិទ្ធិ នោះក៏ត្រូវមានតួនាទីក្នុងការពិនិត្យបញ្ហានេះឡើងវិញ ហើយគួរគប្បីអំពាវនាវទៅដល់ប្រជាពលរដ្ឋអំពីការចុះបញ្ជីអចលនវត្ថុឱ្យបានត្រឹមត្រូវ គឺដើម្បីងោយប្រជាពលរដ្ឋអាចការពារសិទ្ធិរបស់ខ្លួនដែលមានទៅលើអចលនវត្ថុផង ដើម្បីជាសុវត្ថិភាពនិងទំនុកចិត្តសម្រាប់អ្នកទិញអចលនវត្ថុផង និង ដើម្បីបំពេញកាតព្វកិច្ចបង់ពន្ធជូនរដ្ឋផង ហើយចំពោះប្រជាពលរដ្ឋដែលជាអ្នកទិញអចលនវត្ថុដែលមិនទាន់ចុះបញ្ជីទាំងអស់ដោយធ្វើការស្រាវជ្រាវប្រវត្តិអចលនវត្ថុឱ្យបានច្បាស់លាស់ជាមុនសិន ជៀសវាងខាតប្រយោជន៍ដោយប្រការណាមួយ ៕

# ឯកសារយោង

# ឯកសារយោង

## ក. ច្បាប់ និងបទដ្ឋានគតិយុត្ត

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសអោយប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ។

២. ក្រមរដ្ឋប្បវេណី ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧ ។

៣. ច្បាប់ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា ក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៨៨។

៤. ច្បាប់ភូមិបាលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស /រកម/០៨០១/១៥ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១។

៥. ច្បាប់ស្តីពីសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស ប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០៥១០/០០៦ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០ ។

៦. ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១។

៧. ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ នស/រកម/១២២០/០៣៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ ។

៨.អនុក្រឹត្យលេខ១២៦អនក្រ.បក ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អាគារសហកម្មសិទ្ធិ ចុះថ្ងៃទី១២ ខែ សីហា ឆ្នាំ២០០៩ ។

៩. អនុក្រឹត្យលេខ លេខ ១១៤ អនក្រ.បក ស្តីពីការកែសម្រួលមាត្រា១៦ និងមាត្រា១៧ នៃអនុក្រឹត្យ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ២០០៩ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អាគារសហកម្មសិទ្ធិចុះថ្ងៃទី ១៤ខែសីហា ឆ្នាំ ២០១០ ។

១០. ប្រកាសអន្តរក្រសួង លេខ២១៥ ប្រក/ជនស.មផ ស្តីពីតួនាទីនិងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ-សង្កាត់ក្នុងការចុះបញ្ជីដីធ្លីចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០០៥

១១. ប្រកាសលេខ១១៤៦ សហវ.ប្រក ស្តីពីការផ្តល់សេវាសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ នៃ ក្រសួងសេដ្ឋកិច្ចចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ ។

១២. ប្រកាសអន្តរក្រសួង លេខ៣០ កយ.ជនស.ប្រក/១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្ស ទាក់ទង នឹងក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៣ ។

១៣. ប្រកាសលេខ៧០១ សហវប្រក ស្តីពីការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់.ពន្ធ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ។

**ខ. សៀវភៅ**

១៤. សម្តេចព្រះសង្ឃរាជ ជួន ណាត, *វចនានុក្រមខ្មែរ* (ភ្នំពេញ៖ ពុទ្ធសាសនបណ្ឌិត ឆ្នាំ១៩៦៧ )។

១៥. លោក ជិន វណ្ណារ៉ា ,*នីតិកិច្ចសន្យា* ផ្នែកទី៣ កម្មវត្ថុ ជំពូកទី១សម្រាប់និស្សិតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, បោះពុម្ពឆ្នាំ២០១៣ ។

១៦. លោក ហាប់ ផល្លី , *កម្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងដីធ្លី និងនគរូបនីយកម្ម ឆ្នាំ១៩៨៥-២០១៥* បោះពុម្ពលើកទី ៤ ឆ្នាំ២០១៥ ភ្នំពេញ៖ ជោគជ័យ ។

១៧. លោក ហេង បូរ៉ា *មេរៀនស្តីពីនីតិកាតព្វកិច្ច* សម្រាប់និស្សិតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំសិក្សា២០២០-២០២១ ។

១៨. លោក យស បានចំរុង និងលោក ខាំ សុមករា ,*នីតិកិច្ចសន្យាពិសេស* ,ឆ្នាំ ២០១៣ , ទំព័រទី១៥

១៩. ក្រុមការងារក្រសួងយុត្តិធម៌ *មេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីភាគ១* បោះពុម្ពលើកទី១ (ភ្នំពេញ៖ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់និងតុលាការរបស់ក្រសួងយុត្តិធម៌និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ឆ្នាំ២០១៥) ,ទំព័រ១៩។

២០. គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ , *សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី* ( ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី នៅឆ្នាំ២០០៧ )។

២១. គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកលើសេចក្តីព្រាងក្រមរដ្ឋប្បវេណី *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* ភាគ២ គន្លីទី៤ (ភ្នំពេញ៖ ក្រសួងយុត្តិធម៌ ឆ្នាំ២០១០)។

២២. ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA) *សៀវភៅក្រមរដ្ឋប្បវេណីភាគទី២* ជំពូក៣ ផ្នែកទី៤ កថាភាគទី២ បោះពុម្ពលើកទី១ ,ភ្នំពេញ ,ឆ្នាំ២០១២។

២៣. សាស្ត្រាចារ្យ Fukuoka Fumie និង Umemoto Yumi មេរៀនស្តីអំពី *បញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី* របស់ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ។

២៤. សាស្ត្រាចារ្យច្បាប់ Uchiyama Jun *មូលដ្ឋាននៃនីតិវិធីចុះបញ្ជីអចលនវត្ថុទាក់ទងនឹងកម្មសិទ្ធិ* រៀបចំដោយការិយាល័យស្រាវជ្រាវនីតិកម្ម ផ្នែកកិច្ចសហប្រតិបត្តិការអន្តរជាតិនៃក្រសួងយុត្តិធម៌ ។

២៥. សាស្ត្រាចារ្យ UMEMOTO Yumi *ការរំលោយកិច្ចសន្យា* របស់ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅ អំពីកិច្ចការច្បាប់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

២៦. សាស្ត្រាចារ្យ Yoshie SASAKI *អំពីនីតិវិធីចុះបញ្ជីអចលវត្ថុ* )JICA Expert។(

**គ. គេហទំព័រ**

២៧. https://www.sangkumthmey.com/news/2021/12/12/

ចូលពិគ្រោះនៅម៉ោង១០៖២០នាទីព្រឹក ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២

២៨. https://lorkremlaw.files.wordpress.com//2014/09e19fa1e19fa.137pdf

ចូលពិគ្រោះនៅម៉ោង៧៖៣០នាទីយប់ ថ្ងៃទី១៥ខែ កក្កដា ឆ្នាំ២០២២

២៩. https://youtu.be/kWpxL67G-8A

ចូលពិគ្រោះនៅម៉ោង៩៖៣០នាទី ថ្ងៃទី១៤ ខែឧសភាឆ្នាំ២០២២

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

# គំរូនៃកិច្ចសន្យាលក់ទិញ

# អចលនវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យាទិញ/លក់ដី

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................... ភេទ.......... អាយុ.......... ឆ្នាំ មានទីលំនៅសព្វថ្ងៃភូមិ.................... ឃុំ.................... ស្រុក/ខណ្ឌ.................... ខេត្ត/រាជធានី.................... កាន់អត្តសញ្ញាណបណ្ណលេខ....................
និងឈ្មោះ.................... ភេទ.......... អាយុ.......... ឆ្នាំ មានទីលំនៅសព្វថ្ងៃភូមិ.................... ឃុំ.................... ស្រុក/ខណ្ឌ.................... ខេត្ត/រាជធានី.................... កាន់អត្តសញ្ញាណបណ្ណលេខ.................... (ជាភាគីលក់)

**បានព្រមព្រៀងគ្នាលក់ដី** ......កន្លែង ទីតាំងស្ថិតនៅភូមិ.................... ឃុំ.................... ស្រុក/ខណ្ឌ.................... ខេត្ត/រាជធានី.................... មានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ.................... មានបណ្តោយប្រវែង.......... ម៉ែត្រ ទទឹងប្រវែង.......... ម៉ែត្រ និងគិតជាផ្ទៃក្រឡាសរុបស្មើនឹង.......... ម៉ែត្រការ៉េ ដែលប្លង់ដីនេះ មានព្រំប្រទល់៖

- ខាងជើងទល់នឹង ៖ .................... ខាងត្បូងទល់នឹង ៖ ....................
- ខាងលិចទល់នឹង ៖ .................... ខាងកើតទល់នឹង ៖ ....................

**ទៅឲ្យទៅឈ្មោះ**.................... ភេទ.......... អាយុ.......... ឆ្នាំ មានទីលំនៅសព្វថ្ងៃភូមិ.................... ឃុំ.................... ស្រុក/ខណ្ឌ.................... ខេត្ត/រាជធានី.................... កាន់អត្តសញ្ញាណបណ្ណលេខ.................... (ជាភាគីទិញ) ចាប់ពីថ្ងៃធ្វើកិច្ចសន្យានេះតទៅ។

យើងខ្ញុំទាំងពីរ (ភាគីលក់ និងភាគីទិញ) បានព្រមព្រៀងគ្នាក្នុងតម្លៃ ..................../ម៉ែត្រការ៉េ ឬគិតជាតម្លៃសរុបស្មើនឹង ....................

ភាគីទិញបានប្រគល់ប្រាក់កក់ចំនួន .................... នៅថ្ងៃទី.......... ខែ.......... ឆ្នាំ..........
ហើយបានសន្យាប្រគល់ប្រាក់ចំនួន .................... នៅថ្ងៃទី.......... ខែ.......... ឆ្នាំ..........
ឬសន្យាប្រគល់ប្រាក់គ្រប់ចំនួននៅពេល....................

ភាគី លក់ បានព្រមប្រគល់ទ្រព្យនៅលើដី និងក្រោមដី ដល់ភាគី ទិញ ប្រសិនបើថ្ងៃក្រោយមានជនណាមកទាមទា ឬតវ៉ាពីដីខាងលើនេះ ខ្ញុំបាទភាគី លក់ សូមទទួលចេញមុខដោះស្រាយទាំងស្រុងចំពោះមុខច្បាប់ជាធរមាន និងជានាសងប្រាក់ភាគី ទិញ នូវទឹកប្រាក់ មួយគុណនឹង .......... នៃតម្លៃសរុប។

ភាគី ទិញ ដល់ពេលកំណត់កិច្ចសន្យា ពុំបានប្រគល់ប្រាក់ នោះប្រាក់កក់ និងត្រូវទុកជាអាសាបង់។

យើងខ្ញុំទាំងពីរសុខចិត្តទទួលដឹងឮ ឬធ្វើជាសាក្សីចំពោះការទិញ-លក់ដីខាងលើនេះ។

ខ្ញុំឈ្មោះ.................... ភេទ.......... អាយុ.......... ឆ្នាំ មានទីលំនៅសព្វថ្ងៃភូមិ.................... ឃុំ.................... ស្រុក/ខណ្ឌ.................... ខេត្ត/រាជធានី....................
ខ្ញុំឈ្មោះ.................... ភេទ.......... អាយុ.......... ឆ្នាំ មានទីលំនៅសព្វថ្ងៃភូមិ.................... ឃុំ.................... ស្រុក/ខណ្ឌ.................... ខេត្ត/រាជធានី....................

ក្រែពុំប្រាកដ យើងខ្ញុំទាំងអស់គ្នាសូមផ្តិតមេដៃស្តាំទុកធ្វើជាភស្តុតាងលើក្រដាសកិច្ចសន្យានេះ ដើម្បីបញ្ជាក់ការពិត

ធ្វើនៅ.................... ថ្ងៃទី.......... ខែ.......... ឆ្នាំ..........

| | | | | |
|---|---|---|---|---|
| បានឃើញ និងដឹងឮ<br>ថ្ងៃទី.......... ខែ.......... ឆ្នាំ២០.....<br>**មេភូមិ** | **សាក្សីដឹងឮ** | **ស្នាមមេដៃ<br>អ្នកទិញ** | **សាក្សីដឹងឮ** | **ស្នាមមេដៃ<br>អ្នកលក់** |
| | .......... | .......... | .......... | .......... |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យាលក់ដីផ្ទាល់

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ..................................អាយុ..........ឆ្នាំ សញ្ជាតិ............មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ..........ផ្លូវលេខ...........ភូមិ.........................ឃុំ/សង្កាត់............................ក្រុង/ស្រុក/ខណ្ឌ............. រាជធានី/ខេត្ត..............................អត្តសញ្ញាណប័ណ្ណលេខ........................ និងឈ្មោះ.......................... ភេទ.........អាយុ........ឆ្នាំ សញ្ជាតិ.........ត្រូវជា.................... មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.........ផ្លូវលេខ......... ភូមិ..........................ឃុំ/សង្កាត់.....................................ក្រុង/ស្រុក/ខណ្ឌ.........................រាជធានី/ខេត្ត ............................អត្តសញ្ញាណប័ណ្ណលេខ........................។

បានព្រមព្រៀងគ្នាលក់ដី............កន្លែងប្រភេទ........................ គឺក្បាលដីលេខ........................ ដែលមានបណ្ដោយ.........................ម៉ែត្រ និង ទទឹង.........................ម៉ែត្រ ទំហំ..........................ម²

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹង................................
- ខាងត្បូងទល់នឹង................................
- ខាងកើតទល់នឹង................................
- ខាងលិចទល់នឹង................................

ដែលស្ថិតនៅក្នុងភូមិ.........................ឃុំ....................ស្រុកវាំស្រួច ខេត្តកំពង់ស្ពឺ

អោយទៅឈ្មោះ.........................................អាយុ..........ឆ្នាំ សញ្ជាតិ...........មានទីលំនៅបច្ចុប្បន្នផ្ទះ លេខ..........ផ្លូវលេខ...........ភូមិ.........................ឃុំ/សង្កាត់............................ក្រុង/ស្រុក/ខណ្ឌ................ រាជធានី/ខេត្ត..............................អត្តសញ្ញាណប័ណ្ណលេខ....................... និងឈ្មោះ.......................... ភេទ.........អាយុ........ឆ្នាំ សញ្ជាតិ.........ត្រូវជា.................... មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.........ផ្លូវលេខ......... ភូមិ..........................ឃុំ/សង្កាត់..................................... ក្រុង/ស្រុក/ខណ្ឌ.........................រាជធានី/ខេត្ត ..........................អត្តសញ្ញាណប័ណ្ណលេខ.........................ដើម្បីកាន់កាប់បន្តចាប់ពីថ្ងៃទី.....ខែ...........ឆ្នាំ ២០១.. នេះតទៅ ។

យើងទាំងពីរភាគីបានឯកភាពគ្នា (លក់ ទិញ) ក្នុងតម្លៃព្រមព្រៀងមួយគិតចំនួនសរុបស្មើនឹង....................... (ជាអក្សរ................................................)។

បើថ្ងៃក្រោយមានជនណាមកប្ដឹងទាមទារ ឬតវ៉ាខាងលើដីខាងលើនេះ យើងខ្ញុំភាគីលក់ សូមទទួលខុសត្រូវចំពោះមុខច្បាប់។ ក្រែងពុំពិតប្រាកដ យើងខ្ញុំសូមផ្ដិតមេដៃស្ដាំទុកជាភស្តុតាងស្រាប់។

.............ថ្ងៃទី...... ខែ........ ឆ្នាំ ២០១.....

**ស្នាមមេដៃសាក្សី**

**ទី១** **ទី២**

**ស្នាមមេដៃ**

**អ្នកទិញ** **អ្នកលក់**

លេខ៖..............................

បានឃើញ និងឯកភាព

អ្នកទិញ និងអ្នកលក់ ពិតជាបានព្រមព្រៀងគ្នា

និង ផ្ដិតស្នាមមេដៃនៅចំពោះមុខយើងពិតប្រាកដមែន ។

ថ្ងៃ..............ខែ...........ឆ្នាំចរ សំរឹទ្ធិស័ក ព.ស២៥៦..

ធ្វើនៅ.................,ថ្ងៃទី.....ខែ.........ឆ្នាំ២០.....

**មេឃុំ**

## ព្រះរាជាណាចក្រកម្ពុជា

### ជាតិ សាសនា ព្រះមហាក្សត្រ

## <u>កិច្ចព្រមព្រៀងលក់ផ្ដាច់ (អចលនវត្ថុ)</u>

### <u>រវាងភាគីខាង</u>

លោក.................................អាយុ..........ឆ្នាំ មានទីលំនៅ ភូមិ.............ឃុំ-សង្កាត់.......................
ស្រុក-ខណ្ឌ........................ខេត្ត-ក្រុង.................... លេខទូរស័ព្ទលេខ....................... កាន់អត្តសញ្ញាណប័ណ្ណ
សញ្ជាតិខ្មែរលេខ.......................... ទូរស័ព្ទលេខ:.................................. ជាអ្នកទិញដី ( ហៅកាត់ថា **ភាគី "ក"** ) ។

**និង**

លោក.................................អាយុ..........ឆ្នាំ មានទីលំនៅ ភូមិ.............ឃុំ-សង្កាត់.......................
ស្រុក-ខណ្ឌ........................ខេត្ត-ក្រុង.................... លេខទូរស័ព្ទលេខ....................... កាន់អត្តសញ្ញាណប័ណ្ណ
សញ្ជាតិខ្មែរលេខ.......................... ទូរស័ព្ទលេខ:.................................. ជាអ្នកទិញដី ( ហៅកាត់ថា **ភាគី "ខ"** ) ។

### <u>*ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម:*</u>

**<u>ប្រការ១:</u>** **ភាគី "ក"** មានដីទំហំ...................ស្ថិតនៅក្នុងភូមិ .................ស្រុក............. ខេត្ត...............
ក្នុងតម្លៃ ......... = .........ដុល្លារ ( .............ដុល្លារអាមេរិក) ( ក្នុងចំនួនដី .............ហិកតា) ។
រួមទាំងដើមឈើដែលមានដុះលើដី មានព្រំប្រទល់:

- ខាងជើងទល់នឹង.............................. - ខាងត្បូងទល់នឹង..............................
- ខាងកើតទល់នឹង.............................. - ខាងលិចទល់នឹង..............................

**<u>ប្រការ២:</u>** **ភាគី "ខ"** យល់ព្រមប្រគល់ប្រាក់កក់ចំនួន ៣០% ស្មើនឹង ..................................................
ជាប្រាក់កក់បណ្ដោះអាសន្នលើចំណែកលើកទី១ នៃសរុបប្រាក់.................................................
នៅថ្ងៃទី...........ខែ............ឆ្នាំ............ដើម្បីយកទៅដោះស្រាយការងារផ្សេងៗដែលពាក់ព័ន្ធជាមួយ
**ភាគី "ក"** ។

**<u>ប្រការ៣:</u>** **ភាគី "ខ"** យល់ព្រមប្រគល់ប្រាក់កក់ចំនួន ៥០% លើកទី២ ស្មើនឹង ....................................
នៅថ្ងៃទី...........ខែ............ឆ្នាំ............ ដើម្បីអោយកាត់ឈ្មោះផ្ទេរសិទ្ធិជូនភាគី "ខ" រួចរាល់ ។

**<u>ប្រការ៣:</u>** **ភាគី "ខ"** ត្រូវប្រគល់ប្រាក់គ្រប់ចំនួននៅពេលដែល **ភាគី "ក"** កាត់ឈ្មោះរួចរាល់ហើយ ត្រូវប្រាក់ដែល
នៅចំនួន ២០%ស្មើនឹង...................................... នៃទឹកប្រាក់សរុបទាំង ។

**<u>ប្រការ៤:</u>** **ភាគី "ក"** ក្រោយពីចុះកិច្ចព្រមព្រៀងនេះ និងទទួលប្រាក់កក់ថ្លៃដីរួចហើយ ត្រូវមានភារកិច្ចដូច
ខាងក្រោម :

**ប្រការ៤:** យោងកិច្ចសន្យានេះ ដើម្បីធានាដល់ការបំពេញកាតព្វកិច្ចភាគី "ខ" បានដាក់អចលនទ្រព្យធានាមានដូចជា៖

| ល.រ | រាយមុខទ្រព្យសម្បត្តិដាក់បញ្ចាំ | ចំនួនច្បាប់ | ផ្សេងៗ |
|---|---|---|---|
| ១ | ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព្យ:......................................<br>ចុះថ្ងៃទី......ខែ.........ឆ្នាំ........( ក្រុម/ភូមិ..........ឃុំ/សង្កាត់............)<br>ស្រុក/ខណ្ឌ......................ខេត្ត/ក្រុង.............................. ។ | | |
| ២ | ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព្យ:......................................<br>ចុះថ្ងៃទី......ខែ.........ឆ្នាំ........( ក្រុម/ភូមិ..........ឃុំ/សង្កាត់............)<br>ស្រុក/ខណ្ឌ......................ខេត្ត/ក្រុង.............................. ។ | | |
| ៣ | ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព្យ:......................................<br>ចុះថ្ងៃទី......ខែ.........ឆ្នាំ........( ក្រុម/ភូមិ..........ឃុំ/សង្កាត់............)<br>ស្រុក/ខណ្ឌ......................ខេត្ត/ក្រុង.............................. ។ | | |

**ប្រការ៥:** កិច្ចសន្យានេះធ្វើឡើងជាភាសាខ្មែរចំនួន ០៣ច្បាប់ សម្រាប់ភាគី "ក" និងភាគី "ខ" រក្សាទុកចំនួន ០១ច្បាប់ម្នាក់ មេធាវី ០១ច្បាប់ ។

**ប្រការ៦:** កិច្ចសន្យានេះធ្វើឡើងរវាងភាគី "ក" និងភាគី "ខ" ដោយគ្មានការបង្ខិតបង្ខំពីភាគីណាមួយឡើយ ហើយកិច្ចសន្យានេះមានសុពលភាពនៅពេលដែលចុះហត្ថលេខា និងផ្តិតស្នាមមេដៃស្តាំ ជាភស្តុតាង ។

ធ្វើនៅ............... ថ្ងៃទី.........ខែ..........ឆ្នាំ...........

**ភាគី "ខ"** **សាក្សីភាគី "ខ"** **សាក្សីភាគី "ក"** **ភាគី "ក"**

ឈ្មោះ...................... ឈ្មោះ...................... ឈ្មោះ...................... ឈ្មោះ......................

បានឃើញ និង បញ្ជាក់ថា

ភាគីទាំងពីរបានផ្តិតមេដៃស្តាំ ចំពោះមុខមេធាវី

ប្រាកដមែន ។

ធ្វើនៅ............ថ្ងៃទី.........ខែ..........ឆ្នាំ.........

**មេធាវី**

...លិខិត..........................

**លក់ផ្តាច់**

...ឈ្មោះ..........................

..........................

ក..........................

..........................

..........................

..........................

...ឈ្មោះ..........................

..........................

ក..........................

...ប្រាក់..........................

..........................

---

អ្នកតែងលិខិត

លេខ......................

# លក់ផ្តាច់

## VENTE DEFINITIVE

ក្រដាសពុម្ពលេខ 6
ពិធុកឯកសារ

អ្នកលក់-ឈ្មោះ.................................. អាយុ.................ឆ្នាំ ជាតិ............ទីលំនៅភូមិ......................

ឃុំ.................................. ស្រុក.................................. ខេត្ត..................................

សុខចិត្តព្រមលក់ផ្តាច់ឥតមានសញ្ញាអ្វីឡើយ

អ្នកទិញ-ឈ្មោះ.................................. អាយុ.................ឆ្នាំ ជាតិ............ទីលំនៅភូមិ......................

ឃុំ.................................. ស្រុក.................................. ខេត្ត..................................

<u>អត្រានុកូលដ្ឋាន</u>

| | ប្តី | ប្រពន្ធ |
|---|---|---|
| ឆ្នាំកំណើត | ............ | ............ |
| ឃុំ | ............ | ............ |
| ឪពុក | ............ | ............ |
| ម្តាយ | ............ | ............ |

សំបុត្រអាពាហ៍ពិពាហ៍លេខ..................

ចុះថ្ងៃ..................ឃុំ..................

..................ស្រុក..................

**គំរូថ្មី**

សុខចិត្តព្រមទិញជាស្រេចឥតមានលក្ខខណ្ឌអ្វីឡើយ

តម្លៃជាប្រាក់..........................................................................................

..........................................................................................

តែមប្រើ..........................

ប្រថាប់ត្រា....................បង្កាន់ដៃលេខ............ចុះថ្ងៃ............

រង្វាន់លិខិត..........................ដ......................ដ..............

ប.ស.អ..........................ដ......................ដ..............

បូករួម..........................

បានទទួលសំបុត្រដើម

នៅថ្ងៃ..........................

ឈ្មោះ..........................

ផ្តិតមេដៃស្តាំ

អ្នកតែងលិខិត.........................

## លក់ផ្តាច់

អ្នកលក់ឈ្មោះ.........................

.........................

ទីលំនៅ.........................

ដីលេខ.........................

.........................

នៅឃុំ.........................

អ្នកទិញឈ្មោះ.........................

.........................

ទីលំនៅ.........................

តម្លៃជាប្រាក់.........................

.........................

---

អ្នកតែងលិខិត

# លក់ផ្តាច់

## VENTE DEFINITIVE

លេខ.........................

ក្រដាសពុម្ពលេខ **6**

ទីទុកឯកសារ

អ្នកលក់-ឈ្មោះ.........................អាយុ...............ឆ្នាំ ជាតិ............ទីលំនៅ១ភូមិ.........................

ឃុំ.........................ស្រុក.........................ខេត្ត.........................

សុខចិត្តព្រមលក់ផ្តាច់ឥតមានសញ្ញាអ្វីឡើយ

អ្នកទិញ-ឈ្មោះ.........................អាយុ...............ឆ្នាំ ជាតិ............ទីលំនៅ១ភូមិ.........................

ឃុំ.........................ស្រុក.........................ខេត្ត.........................

អត្រានុកូលដ្ឋាន

| | ប្តី | ប្រពន្ធ |
|---|---|---|
| ឆ្នាំកំណើត | ............ | ............ |
| ឃុំ | ............ | ............ |
| ឪពុក | ............ | ............ |
| ម្តាយ | ............ | ............ |

សំបុត្រអាពាហ៍ពិពាហ៍លេខ.........................

ចុះថ្ងៃ...............ឃុំ...............

...............ស្រុក...............

**គំរូចាស់**

សុខចិត្តព្រមទិញជាស្រេចឥតមានលក្ខខ័ណ្ឌអ្វីឡើយ

តម្លៃជាប្រាក់.................................................................................

.................................................................................

តែមប្រិ.........................

ប្រថាប់ត្រា...............បង្កាន់ដៃលេខ............ចុះថ្ងៃ...........

រង្វាន់លិខិត...............ជ...............ជ...............

ប.ស.អ...............ជ...............ជ...............

បូករួម.........................

បានទទួលសំបុត្រដើម

នៅថ្ងៃ.........................

ឈ្មោះ.........................

ផ្តិតមេដៃស្តាំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៚៚៚●៚៚៚

## កិច្ចសន្យាទិញ-លក់ផ្ទះ

**រវាង**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................................ភេទ..............អាយុ....................

អត្តសញ្ញាណប័ណ្ណលេខ..........................អាសយដ្ឋានផ្ទះលេខ............ផ្លូវ...........ភូមិ....................

សង្កាត់.........................ខណ្ឌ..........................ក្រុង..........................មុខរបរ...................

·ត្រូវជាម្ចាស់កម្មសិទ្ធិករលើផ្ទះទំហំ.............................................ធ្វើពី...........................

·មានទីតាំងស្ថិតនៅភូមិ......................ឃុំ.......................ស្រុក....................ខេត្ត......................។

ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ.................ចេញដោយ.................................

ចាប់ពីពេលនេះទៅហៅថា **ភាគី-ក-** ។ ទូរស័ព្ទលេខ.........................................................................។

**និង**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................................ភេទ..............អាយុ....................

អត្តសញ្ញាណប័ណ្ណលេខ..........................អាសយដ្ឋានផ្ទះលេខ............ផ្លូវ...........ភូមិ....................

សង្កាត់.........................ខណ្ឌ..........................ក្រុង..........................មុខរបរ...................

ពេលនេះទៅហៅថា **ភាគី-ខ-** ។ ទូរស័ព្ទលេខ.........................................................................។

**គូភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម ៖**

ប្រការ ១ **ភាគី-ក-** យល់ព្រមលក់ផ្ទះលេខ...............មានទីតាំងស្ថិតនៅផ្លូវ..............ភូមិ....................
សង្កាត់..............................ខណ្ឌ..............................រាជធានី/ខេត្ត..............................
ដែលមានប័ណ្ណសម្គាល់កម្មសិទ្ធិកាន់កាប់អចលនវត្ថុលេខ..................................ចុះថ្ងៃទី...........
ខែ.............ឆ្នាំ.............ចេញដោយ................................................................អោយទៅ**ភាគី-ខ-**
ក្នុងតម្លៃ.............................$ (.................................................ដុល្លារអាមេរិក)ហើយ **ភាគី-ខ-** ក៏
យល់ព្រមទិញ ។

ប្រការ ២ **ការប្រគល់ប្រាក់ត្រូវធ្វើឡើងក្នុង០៣ដំណាក់កាលគឺ:**

**-លើកទី១** នៅថ្ងៃទី..............................**ភាគី-ខ-** បានប្រគល់ប្រាក់ចំនួន....................$
(..............................ដុល្លារអាមេរិក) ជូនទៅអោយ **ភាគី-ក-** ។

**-លើកទី២** នៅថ្ងៃទី..............................**ភាគី-ខ-** បានប្រគល់ប្រាក់ចំនួន....................$
(..............................ដុល្លារអាមេរិក) ជូនទៅអោយ **ភាគី-ក-** ។

ប្រការ ៣ ក្រោយពីទទួលបានប្រាក់ចំនួន..............................$ (..............................ដុល្លារអាមេរិក)
ពី **ភាគី-ខ-** រួចហើយ **ភាគី-ក-** ត្រូវយកប្រាក់ចំនួន....................(....................ដុល្លារអាមេរិក)
នេះទៅលោះប័ណ្ណកម្មសិទ្ធិពីឈ្មោះ................................................ដែល **ភាគី-ក-** បានបញ្ចាំ។

**សូមបញ្ជាក់ថា:**

ការលោះប័ណ្ណកម្មសិទ្ធិនេះត្រូវមានការចូលរួម ពី **ភាគី-ខ-** ដែរ។

**ប្រការ ៤** ក្រោយពីបានលោះប័ណ្ណកម្មសិទ្ធិរួចហើយ **ភាគី-ក-** ត្រូវយកប័ណ្ណកម្មសិទ្ធិនេះព្រមជាមួយឯកសារពាក់ព័ន្ធដទៃទៀតដាក់ទៅសង្កាត់.......................... ខណ្ឌ.......................... រាជធានី/ខេត្ត .......................... ដើម្បីធ្វើលិខិតផ្ទេរសិទ្ធិជូនទៅ **ភាគី-ខ-** ។

**ប្រការ ៥** ក្រោយពីបានទទួលលិខិតផ្ទេរសិទ្ធិកាន់កាប់ផ្ទះហើយ **ភាគី-ក-** ត្រូវយកលិខិតផ្ទេរសិទ្ធិកាន់កាប់ផ្ទះនេះព្រមជាមួយឯកសារពាក់ព័ន្ធដទៃទៀតដាក់ទៅមន្ទីររៀបចំដែនដី និង នគរូបនីយកម្ម និង សំណង់ .......................... ដើម្បីធ្វើប័ណ្ណកម្មសិទ្ធិថ្មីដោយដូរឈ្មោះ **ភាគី-ក-** មក **ភាគី-ខ-** នៅក្នុងរយៈពេល.......................... យ៉ាងយូរ។

**ប្រការ ៦** រាល់ការចំណាយទៅលើសេវាកម្មនៅក្នុងការធ្វើលិខិត និងបែបបទផ្សេងៗមានដូចជា ធ្វើលិខិតផ្ទេរសិទ្ធិនៅ.......................... និងធ្វើប័ណ្ណកម្មសិទ្ធិថ្មីនៅ មន្ទីររៀបចំដែនដី និង នគរូបនីយកម្ម និងសំណង់ .......................... ជាបន្ទុករបស់ **ភាគី-ក-** ។

**ប្រការ ៧** ការប្រគល់ប្រាក់លើកទី៣ គឺ **ភាគី-ខ-** នឹងប្រគល់អោយទៅ **ភាគី-ក-** នៅពេលដែល **ភាគី-ខ-** បានទទួលប័ណ្ណកម្មសិទ្ធិដែលចេញដោយ មន្ទីររៀបចំដែនដី និងនគរូបនីយកម្ម និង សំណង់.......................... រួចរាល់ហើយ។

**ប្រការ ៨** ករណីដេល **ភាគី-ក-** បានទទួលប្រាក់ចំនួនពីរលើកសរុប..........................$

(.......................... ដុល្លារអាមេរិក) ពី **ភាគី-ខ-** រួចហើយ តែមិនព្រមអនុវត្តតាមប្រការដូចដែលបានចែងខាងលើនេះទេ **ភាគី-ក-** ត្រូវសងប្រាក់ចំនួន..........................$

(.......................... ដុល្លារអាមេរិក) អោយទៅ **ភាគី-ខ-** ។

ភាគីទាំងពីរ ត្រូវអនុវត្តកាតព្វកិច្ច តាមប្រការដូចដែលបានចែងក្នុងកិច្ចសន្យាខាងលើដោយសុចរិត និង ស្មើភាព ។

ករណីដែលភាគីណា មួយមានចេតនាទុច្ចរិតដោយបំពានទៅលើប្រការណាមួយ ដូចដែលមានចែងនៅក្នុងកិច្ចសន្យាខាងលើនេះ នឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។

កិច្ចសន្យានេះ បានធ្វើឡើងដោយការព្រមព្រៀងពិតប្រាកដ និងដោយសេរីមិនមានការបង្ខិតបង្ខំ និង ការគំរាមកំហែង ឬការប្រើអំពើហិង្សា ឡើយ។ ម្យ៉ាងទៀត កិច្ចសន្យា បានបង្កើតឡើងនៅពេលដែលគូភាគីទាំងពីរមានសតិ និងស្មារតីគ្រប់គ្រាន់ ហើយបានពិនិត្យយ៉ាងត្រឹមត្រូវ ។

កិច្ចសន្យា មានសុពលភាពអនុវត្ត បន្ទាប់ពីគូភាគីទាំងពីរបានផ្តិតមេដៃ ទទួលយល់ព្រមនៅលើកិច្ចសន្យានេះតទៅ ។

ធ្វើនៅ.................... ថ្ងៃទី......... ខែ.............. ឆ្នាំ ២០.....

សាក្សីទី១ សាក្សីទី២ ស្នាមមេដៃស្តាំភាគី-ខ- ស្នាមមេដៃស្តាំភាគី-ក-

ឈ្មោះ.................. ឈ្មោះ................ ឈ្មោះ....................... ឈ្មោះ.........................

**បានឃើញ និង ឯកភាព**

ថ្ងៃទី.......... ខែ.................. ឆ្នាំ ២០.....

មេឃុំ

ឈ្មោះ.........................

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យាលក់ដីឡូតិ៍

កិច្ចសន្យានេះធ្វើឡើង

**រវាង**

ឈ្មោះ.................................... ភេទ............. ថ្ងៃខែឆ្នាំកំណើត................................
សញ្ជាតិ.......... កាន់អត្តសញ្ញាណប័ណ្ណលេខ..........................ចុះថ្ងៃទី...... ខែ ....... ឆ្នាំ ..............
ដែលមានអាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ: ...................... ផ្លូវ................ ភូមិ...................................
ឃុំ/សង្កាត់..............................ស្រុក/ខណ្ឌ...........................................ខេត្ត/ក្រុង
...................... ដែលមានលេខទូរសព្ទទំនាក់ទំនង .................................. ដែលតទៅហៅកាត់ថា **ភាគី** «ក» ។

**និង**

ឈ្មោះ.......................................ភេទ.............ថ្ងៃខែឆ្នាំកំណើត................................
សញ្ជាតិ..........កាន់អត្តសញ្ញាណប័ណ្ណលេខ..........................ចុះថ្ងៃទី...... ខែ ...... ឆ្នាំ ..............
ដែលមានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ: ...................... ផ្លូវ...................... ភូមិ..........................ឃុំ/
សង្កាត់.........................ស្រុក/ខណ្ឌ.............................ខេត្ត/ក្រុង..........................ដែលមាន
លេខទូរសព្ទទំនាក់ទំនង ................................ហៅ កាត់ថា **ភាគី**«ខ» ។

**ភាគីទាំងពីរបានព្រមព្រៀងគ្នាតាមប្រការ និងលក្ខខ័ណ្ឌដូចខាងក្រោមនេះ ៖**

**ប្រការ ១: សំណើរនៃការបង្កើតកិច្ចសន្យា**

**ភាគី**«ក»បានស្នើបង្កើតសំណើរកិច្ចសន្យាឲ្យកម្រៃជើងសារដល់**ភាគី**«ខ»ក្នុងការរក អតិថិជន ដើម្បីទិញដីឡូតិ៍របស់ **ភាគី**«ក» ដែរមាន**គម្រោងទីតាំងស្ថិតនៅ ភូមិប្រកបានសុខ និងសង្កែជ្រុំ ឃុំខ្នុំក្រាំង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ** ។

**ប្រការ ២: ស្ទីការ( ការយល់ព្រម )**

២-១ **ភាគី**«ក»យល់ព្រមផ្តល់កម្រៃជើងសារចំនួន ..........................**ដុល្លារ ក្នុងមួយឡូតិ៍** ជាអក្សរ(...................................................) ជូនដល់**ភាគី**«ខ»ដើម្បីរកអតិថិជនទិញដី ក្នុងប្រការ ០១ ខាងលើ ។

២-២ **ភាគី**«ក» ផ្តល់សិទ្ធជូន **ភាគី**«ខ» ក្នុងការប្រើប្រាស់ការិយាល័យរបស់ខ្លួន ក្នុងការប្រជុំ និង ការបង្ហាញគម្រោងដល់អតិថិន និងផ្តល់សេវាកម្មនាំភ្ញៀវចុះមើលគម្រោងទីតាំងផ្ទាល់ ដោយគិត

ថ្លៃសេវារថយន្ត ............**ដុល្លារ** និង អ្នកនាំអតិថិជនទៅមើលគម្រោង ( Close Sale ) ចំនួន ...............ដុល្លារ ក្នុងមួយឡូតិ៍ ដោយត្រូវដកចេញពី កម្រៃជើងសារសរុបខាងលើ ។

២-៣ **ភាគី**«ខ» បានឯកភាពលើតម្លៃដីឡូតិ៍នីមួយៗ **ពី ភាគី** «ក» យោងតាមតារាងតម្លៃដីឡូតិ៍ ដែលចុះហត្ថលេខាដោយ**ភាគី**«ក» មានកាលបរិច្ឆេទច្បាស់លាស់ ។

២-៤ ការទូទាត់ប្រាក់ពីអតិថិជន ភាគី«ខ» មានសិទ្ធិត្រឹមតែទទួលប្រាក់កក់ទ្រនាប់ដៃពីអតិថិជនតែប៉ុណ្ណោះ និងអាចរក្សាទុកបានយ៉ាងយូរបានរយៈពេល .............ថ្ងៃគិតចាប់ពីថ្ងៃដែលទទួលបានលុយ ។

២-៥ **ភាគី**«ខ»មិនត្រូវទាញភ្ញៀវ ឬកូនក្រុមលក់ពីភ្នាក់ងារដ៏ទៃទៀតបានឡើយដែលនាំអោយមានទំនាស់ផលប្រយោជន៍និងគ្នា បើពុំនោះទេនិងត្រូវទទួលការពិន័យ ដោយតម្រូវអោយបង់សងជំងឺចិត្តដល់ភ្នាក់ងារម្ខាងទៀត ។

២-៦ **ភាគី**«ក» ស្នើរសុំបញ្ជីឈ្មោះកូនក្រុមពី**ភាគី**«ខ»ក្នុងករណី**ភាគី**«ខ»ជាក្រុមភ្នាក់ងារធំ ឬមានកូនក្រុមដើម្បីកុំអោយមានការធ្វើកិច្ចសន្យាជាន់កូនក្រុមរបស់**ភាគី**«ខ» បើមិនមានបញ្ជីឈ្មោះកូនក្រុមទេហើយមានការជាន់កូនក្រុមគ្នា គឺជាកំហុសអចេតនា ។

## ប្រការ ៣ : រយៈពេលនៃការចុះកិច្ចសន្យាលក់ដីឡូតិ៍

៣-១ ការចុះកិច្ចសន្យាលក់ដីឡូតិ៍នេះ មានរយៈពេល **០៦ខែ** គិតចាប់ពីថ្ងៃផ្តិតមេដៃស្នាំលើកិច្ចសន្យានេះ តទៅ ហើយសំរាប់តែទីតាំងគម្រោងត្រង់ប្រការ ០១ តែប៉ុណ្ណោះ ។

## ប្រការ ៤: ការបង់កម្រៃសារជើងសារ និងភារកិច្ចរបស់គូភាគី

៤-១ នៅពេលដែលអតិថិជន បានបង់ប្រាក់ថ្លៃទិញដីបាន **៣០% (សាមសិបភាគរយ)** នៃតម្លៃដីសរុបក្នុងមួយឡូតិ៍ ចំពោះដីប្រការ ០១ ខាងលើនេះ នោះ**ភាគី**«ក» ត្រូវដកប្រាក់កម្រៃជើងសារជូន**ភាគី**«ខ» **៥០% (ហាសិបភាគរយ)** នៃប្រាក់កម្រៃជើងសារ ។

៤-២ នៅពេលដែលអតិថិជន បានបង់ប្រាក់ថ្លៃទិញដីបាន **៥០% (ហាសិបភាគរយ)** នៃតម្លៃដីសរុបក្នុងមួយឡូតិ៍ ចំពោះដីប្រការ ០១ ខាងលើនេះ នោះ**ភាគី**«ក» ត្រូវដកប្រាក់កម្រៃជើងសារជូន**ភាគី**«ខ» **១០០% (មួយរយភាគរយ)** នៃប្រាក់កម្រៃជើងសារ ។

៤-២ **ក្នុងករណីបង់រំលស់សុទ្ធ ភាគី**«ក» ត្រូវដកប្រាក់កម្រៃជើងសារជូន**ភាគី**«ខ» **ដូចតទៅនេះ៖**

- ដក ៣០% (សាមសិប) នៃប្រាក់បង់ទិញដំបូងនៅក្នុងកិច្ចសន្យាទិញលក់ និង ចំនួនទឹកប្រាក់នៃអតិថិជនបង់ប្រចាំខែរហូតគ្រប់ចំនួននៃកម្រៃជើងសារសរុបតាមការព្រមព្រៀង។

៤-៣ **ភាគី**«ក»ត្រូវរៀបចំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធដូចជាបង្គោលភ្លើង ប្រព័ន្ធលូផ្លូវក្នុងដីឡូតិ៍ ។

៤-៤ **ភាគី**«ក»ត្រូវរៀបចំបែបបទរដ្ឋបាលជាមួយស្ថាប័នមានសមត្ថកិច្ច ជូនអតិថិជនតាមច្បាប់រដ្ឋ

និង ត្រូវរ៉ាប់រងរាល់ការបង់សេវាកម្មផ្សេងៗក្នុងការផ្ទេរសិទ្ធិស្របច្បាប់១០០% (ដីគម្រោង) ជូនដល់អតិថិជន ដោយយោងទៅតាមឯកសារទិញលក់ជាមួយ អតិថិជន ។

៤-៥ **ភាគី**«ក»ត្រូវទទួលខុសត្រូវដោះស្រាយចំពោះមុខច្បាប់ ប្រសិនបើដីក្នុងគម្រោងមានបញ្ហាពាក់ព័ន្ធ នឹងការជាប់បន្ទុកដីសាធារណៈរបស់រដ្ឋ ឬ ដីឯកជនរបស់រដ្ឋ ឬតតីយជនណាមួយជាអាទិ៍។

៤-៦ ក្នុងករណីមានបញ្ហាដូចមាននៅចំណុចខាងលើ **ភាគី**«ក» ត្រូវទទួលខុសត្រូវទាំងស្រុងលើសំណង និងការខូតខាតដល់ **ភាគី**«ខ» និងអតិថិជន ។

៤-៧ ក្នុងករណី**ភាគី**«ខ» មានគំនិតទុច្ចរិត ដោយយកដីរបស់**ភាគី**«ក» លក់ទៅឲ្យអតិថិជនហើយបានទទួលប្រាក់កក់ និងបានទទួលការបង់ប្រចាំខែពីអតិថិជន ដោយ**ភាគី** «ក » មិនបានដឹង នោះ**ភាគី**«ខ»នឹងទទួលខុសត្រូវចំពោះមុខនៃច្បាប់ព្រហ្មទណ្ឌ និងសង សំណងការខូចខាតទៅអតិថិជន និងសងសំណងការខូចខាតទៅ**ភាគី**«ក» ទាំងស្រុងជាសាច់ប្រាក់គុណនិងពីរដងនៃតម្លៃដីឡូត៍ជាក់ស្តែងដូចមានចែងក្នុងតារាងតម្លៃតាមព្រមព្រៀង។

៤-៨ **ភាគី**«ខ» មិនអាចនិយាយអំពីការងារសំងាត់ផ្ទៃក្នុងរបស់**ភាគី**«ក» និង មិនត្រូវនិយាយប្រាប់អំពីប្រាក់កម្រៃជើងសារដែល **ភាគី**«ក»ផ្តល់ជូន**ភាគី**«ខ»ប្រាប់អ្នកដទៃ ឬ ក្រុមហ៊ុនផ្សេងឡើយ ។ ករណីមានការបំពាននោះ**ភាគី**«ខ» នឹងទទួលខុសត្រូវលើ ការខូចខាត់របស់**ភាគី** «ក» ព្រមទាំងទទួលទោសតាមច្បាប់ព្រហ្មទណ្ឌ ។

៤-៩ **ភាគី**«ខ» ត្រូវទំនាក់ទំនង និងសម្របសម្រួលភ្ញៀវទៅតាមតម្លៃ និង លក្ខខណ្ឌដែល**ភាគី**«ក» បានកំណត់ និងត្រូវរៀបចំការផ្សព្វផ្សាយពាណិជ្ជកម្មដោយខ្លួនឯង ។

៤-១០ **ភាគី**«ខ» ត្រូវទទួលខុសត្រូវដោះស្រាយចំពោះមុខច្បាប់ ប្រសិនបើធ្វើអោយខូចខាត ឬ បាត់បង់លុយកាក់របស់អតិថិជនជាអាទិ៍ ។

## ប្រការ ៥: ករណីកែប្រែ

៥-១ ក្នុងករណី**ភាគី**«ក»កែប្រែមិនឲ្យកម្រៃជើងសារវិញ នោះ**ភាគី**«ក» ត្រូវសងគុណនឹង ២ ដងនៃចំនួន **កម្រៃជើងសារ** ទៅឲ្យ **ភាគី**«ខ» ។

៥-២ **ភាគី**«ក»មានសិទ្ធិការកែប្រែក្នុងករណីចាំបាច់ដោយមិនចាំបាច់ជូនដំណឹងទៅ**ភាគី**«ខ»ជាមុន ។

## ប្រការ ៦: ករណីមានវិវាទកើតឡើង

ក្នុងករណីមានវិវាទកើតឡើង គូភាគីទាំងពីរត្រូវខិតខំដោះស្រាយដោយសន្តិវិធី ក្នុងករណីពុំអាចដោះស្រាយដោយសន្តិវិធីបានទេ ភាគីណាមួយក្នុងចំណោម ភាគីទាំងពីរមានសិទ្ធិ ប្តឹងទៅតុលាការនៃព្រះរាជណាចក្រកម្ពុជា ដែលមានសមត្ថកិច្ចក្នុងការដោះស្រាយ ។

**ប្រការ ៧: ការបញ្ចប់កិច្ចសន្យា**

- កិច្ចសន្យាអស់សុពលភាព
- ក្នុងករណីគេឃើញថា**ភាគី** «ខ»គឺជាកូនក្រុមរបស់ភ្នាក់ងារណាមួយហើយមានចេតនាក្លុតកុហក**ភាគី**«ក»
- **ភាគី**«ក» ពុំមានការងារសម្រាប់ផ្តល់អោយ**ភាគី** «ខ» ធ្វើបន្ត
- **ភាគី**«ខ» ពុំមានសកម្មភាពលក់ និងពុំមានទំនាក់ទំនងជាមួយ**ភាគី**«ក» រយៈពេល ៦០ថ្ងៃជាប់ៗគ្នា
- ករណីមានចលាចលក្នុងសង្គម សង្គ្រាម និងប្រធានស័ក្តិជាអាទិ៍
- ភាគីទាំងពីរបានយល់ព្រម (ព្រមព្រៀងគ្នា) បញ្ចប់ ។

**ប្រការ ៨: សុពលភាពនៃកិច្ចសន្យា**

៨-១ កិច្ចសន្យានេះមានសុពលភាពសម្រាប់ លក់គម្រោងគ្រង់ប្រការ ០១ ចាប់ពីថ្ងៃផ្តិតមេដៃស្នាំនៃ **ភាគី**«ក» និង **ភាគី** «ខ» តទៅ ភាគីទាំងពីរ បានអាននិងយល់ព្រមគ្រប់ប្រការទាំងអស់ដោយគ្មានការបង្ខិតបង្ខំឡើយ ក្នុងករណីមានការអនុវត្តផ្ទុយ ឬដោយរំលោភលើលក្ខខណ្ឌណាមួយនៃកិច្ចសន្យានេះ ភាគីដែលល្មើសត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។

៨-២ កិច្ចសន្យាការងារត្រូវបានធ្វើឡើង ដោយមានការព្រមព្រៀងពិតប្រាកដ និងដោយសេរី គ្មានការបង្ខិតបង្ខំពីភាគីណាមួយឡើយ ហើយមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃផ្តិតមេដៃនេះតទៅ។

៨-៣ កិច្ចសន្យានេះត្រូវបានធ្វើឡើង ជាភាសាខ្មែរ មានចំនួន **០២(ពីរ)** ច្បាប់ដើម តម្កល់ទុកនៅ:

**ភាគី** «ក»........................................០១( មួយ )ច្បាប់ដើម

**ភាគី**«ខ»........................................០១(មួយ)ច្បាប់ដើម។

ថ្ងៃ.....................ខែ.............. ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ........ខែ............. ឆ្នាំ ២០.......

| **ភាគី «ខ»**<br>**ស្នាមមេដៃស្តាំ និងឈ្មោះ** | **សាក្សីដឹងឮ** | **ភាគី «ក»**<br>**ស្នាមមេដៃស្តាំ និងឈ្មោះ** |
|---|---|---|
| ............................ | ................................. | ............................ |

## លិខិតអនុញ្ញាត ឬប្រគល់សិទ្ធិ

- *យោងកិច្ចសន្យាស្តីពីការលក់ដីឡូត៍ រវាង* **អ្នកតំណាងស្របច្បាប់** *និង* **អ្នកទទួលសិទ្ធិលក់** *ចុះថ្ងៃទី ..............ខែ............ឆ្នាំ២០..........។*

*ឈ្មោះ.........................................ភេទប្រុស កាន់អត្តសញ្ញាណបណ្ណខ្មែរលេខ:............................... មានអាសយដ្ឋានផ្ទះលេខ..............ផ្លូវលេខ..................សង្កាត់......................ខណ្ឌ......................ភ្នំពេញជាតំណាងម្ចាស់ដីឡូត៍ ឬម្ចាស់ដីឡូត៍នៅភូមិ ............................ ឃុំ.........................ស្រុក.........................ខេត្ត .........................................។*

### ព្រមព្រៀងប្រគល់សិទ្ធិ

**ប្រការ០១៖** *ប្រគល់សិទ្ធិស្របច្បាប់ជូនសាមីជនខាងក្រោមនេះ៖*

*ឈ្មោះ...........................................ភេទ..............កាន់អត្តសញ្ញាណបណ្ណខ្មែរលេខ: ................................ ឬលេខទូរសព្ទ៖.............................................................. ។*

***ជា អ្នកទទួលសិទ្ធិលក់ស្របច្បាប់** ដែលអាចប្រើប្រាស់ឯកសារដីឡូត៍ ផ្សព្វផ្សាយលក់ ទទួលប្រាក់កក់ទ្រនាប់ដៃ បង្កើតក្រុមលក់ និងសម្របសម្រួលរវាងអតិថិជនជាមួយម្ចាស់ដី ដោយអនុវត្តស្របតាមកិច្ចសន្យាស្តីពីការលក់ដីឡូត៍។*

**ប្រការ០២៖** *លិខិតប្រគល់សិទ្ធិនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃផ្តិតស្នាមមេដៃនេះតទៅ។ ហើយមានសុពលភាពរយៈពេល ០៤ខែចាប់ពីថ្ងៃទី.........ខែ............ឆ្នាំ................រហូតដល់ ថ្ងៃទី.........ខែ ............ឆ្នាំ................។*

***ស្នាមមេដៃអ្នកប្រគល់សិទ្ធិ***

***បានឃើញ និងទទួលយកការប្រគល់សិទ្ធិនេះ***

*ស្នាមមេដៃខាងស្តាំរបស់អ្នកទទួលសិទ្ធិ*

............................................................ ..........................................

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## កិច្ចសន្យាកក់ប្រាក់

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ.........................អាយុ.......ឆ្នាំ ភេទ..........កាន់អត្តសញ្ញាណប័ណ្ណលេខ/លិខិតឆ្លងដែនលេខ............................ចុះថ្ងៃទី........ខែ..........ឆ្នាំ..........មានទីលំនៅផ្ទះលេខ...............ផ្លូវលេខ...........ក្រុមទី..........ភូមិ..................ឃុំ/សង្កាត់.....................ស្រុក/ខណ្ឌ.....................ខេត្ត/ក្រុង......................។

បានព្រមព្រៀងលកក់ដី/ផ្ទះ ដី និងផ្ទះ មួយកន្លែងដែលមានទំហំ......................ស្ថិតនៅផ្ទះលេខ...............ផ្លូវលេខ............ក្រុមទី............ភូមិ...................ឃុំ/សង្កាត....................ស្រុក/ខណ្ឌ..................ខេត្ត/ក្រុង....................ក្នុងតម្លៃសរុបចំនួន.......................ដុល្លារ( .......................................) សម្ភារៈផ្តល់ជូនរួមមាន..................................................ហើយសោរហ៊ុយរត់ការផ្ទេរកម្មសិទ្ធិជាបន្ទុករបស់ភាគី............។

ឱ្យទៅអ្នកទិញឈ្មោះ.......................អាយុ.......ឆ្នាំ ភេទ..........កាន់អត្តសញ្ញាណប័ណ្ណលេខ/លិខិតឆ្លងដែនលេខ............................ចុះថ្ងៃទី........ខែ..........ឆ្នាំ..........មានទីលំនៅផ្ទះលេខ...............ផ្លូវលេខ...........ក្រុមទី..........ភូមិ..................ឃុំ/សង្កាត់.....................ស្រុក/ខណ្ឌ.....................ខេត្ត/ក្រុង......................។

នៅថ្ងៃទីចុះកិច្ចសន្យាកក់ប្រាក់នេះ ភាគីអ្នកទិញបានកក់ប្រាក់លើកទី១ចំនួន..................................ដុល្លារ(................................................) និង បានព្រមព្រៀងគ្នាទូទាត់ប្រាក់លើកទី២យ៉ាងយូរបំផុតត្រឹមថ្ងៃទី..........ខែ.............ឆ្នាំ............ចំនួន...............................ដុល្លារ(...............................................................) និង លើកទី៣ចំនួន...........................ដុល្លារ(...................................................................)ក្នុងករណីភាគីអ្នកលក់កែប្រែមិនព្រមលក់អចលនវត្ថុខាងលើនេះតាមតម្លៃដែលបានព្រមព្រៀង ឬមិនអាចផ្ទេរកម្មសិទ្ធិកាន់កាប់ស្របច្បាប់អ្នកទិញបាន ភាគីអ្នកលក់ត្រូវបង់ជំងឺចិត្តចំនួន............ដងនៃប្រាក់កក់។ ប៉ុន្តែប្រសិនបើអ្នកទិញកែប្រែចិត្តមិនទិញ ឬមិនបានបង់ប្រាក់តាមកាលកំណត់ខាងលើ ប្រាក់កក់នេះត្រូវប្រគល់ឱ្យភាគីអ្នកលក់ដោយគ្មានការតវ៉ាអ្វីទាំងអស់ ។

ថ្ងៃទី..........ខែ.............ឆ្នាំ២០.....

| | | | |
|---|---|---|---|
| **សាក្សីទី១** | **សាក្សីទី២** | **អ្នកទិញ** | **អ្នកលក់** |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតប្រគល់-ទទួលប្រាក់

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ...........................ភេទ............អាយុ..........ឆ្នាំ មានទីលំនៅសព្វថ្ងៃភូមិ............................ ឃុំ.........................ស្រុក/ខណ្ឌ.....................ខេត្ត/រាជធានី.......................កាន់អត្តសញ្ញាណបណ្ណលេខ.......................... ជាភាគីលក់.....................បានទទួលប្រាក់......................ចំនួន........................ជាប្រភេទ ☐សាច់ប្រាក់សុទ្ធ ☐មូលប្បទានបត្រ/សែក ☐ផ្សេងៗ.......................... នៃថ្លៃ......................... ពីឈ្មោះ..............................ភេទ............ អាយុ..........ឆ្នាំ មានទីលំនៅសព្វថ្ងៃភូមិ.....................ឃុំ.........................ស្រុក/ខណ្ឌ.............................ខេត្ត/រាជធានី ..........................កាន់អត្តសញ្ញាណបណ្ណលេខ.........................ជាភាគីទិញ....................។

ក្រែពុំប្រាកដ យើងខ្ញុំទាំងអស់គ្នា សូមផ្តិតមេដៃស្តាំ ទុកធ្វើជាភស្តុតាងលើការគល់-ទទួលប្រាក់នេះ។

ធ្វើនៅ.........................ថ្ងៃទី.................ខែ.................ឆ្នាំ................

| **សាក្សីដឹងឮ** | **ស្នាមមេដៃ**<br>**អ្នកប្រគល់ប្រាក់** | **ស្នាមមេដៃ**<br>**អ្នកទទួលប្រាក់** |
|---|---|---|
| ................ | ...................... | ...................... |

បានឃើញ និងដឹងឮ
ធ្វើនៅ........................, ថ្ងៃទី.................ខែ............ ឆ្នាំ...........
(**អាជ្ញាធរមូលដ្ឋាន**)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតធានាអះអាង

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................អាយុ........ឆ្នាំសញ្ជាតិ..........អត្តសញ្ញាណប័ណ្ណលេខ..........................និងឈ្មោះ..........................ភេទ.........អាយុ.........ឆ្នាំសញ្ជាតិ..........ត្រូវជា......................អត្តសញ្ញាណប័ណ្ណលេខ......................រស់នៅភូមិ..............................ឃុំ/សង្កាត់......................ក្រុង/ស្រុក/ខណ្ឌ......................រាជធានី/ខេត្ត............................។

ខ្ញុំបាទ/នាងខ្ញុំសូមធ្វើការអះអាងជាឱឡារិកថា ដី០១កន្លែង ជាប្រភេទដី..................ដែលមានបណ្ដោយ............ម៉ែត្រ ទទឹង............ម៉ែត្រមានទំហំ........................ម៉ែត្រការ៉េ ដែលជាដីស្ថិតក្នុងភូមិ.....................ឃុំ......................ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ហើយមានព្រំប្រទល់៖

- ខាងជើងទល់និងដី............................. - ខាងត្បូងទល់នឹងដី..............................
